# ជំនួយសតិ

## ភាគទី ២០



# សិក្សាព្រះសូត្រ ភាគទី៦

រៀបរៀងដោយ

ខ្ញុំព្រះករុណា

ខ្ញុំបាទ **ប៊ុត សាវង្ស**

# បំណួយសតិភាគទី២០

# សិក្សាព្រះសូត្រ ភាគទី៦

សុ.

ទិ.  អ.

ធម្មទានឈ្នះអស់ទានទាំងពួង


រៀបរៀងដោយ

ខ្ញុំព្រះករុណា

ខ្ញុំបាទ **ប៊ុត សាវង្ស**


សម្រាប់ធម្មទាន

# ពាក្យប្រារព្ធ

សៀវភៅជំនួយសតិភាគទី ២០ នេះ ក៏ជាឆ្នាំទី ២០ នៃការសរសេរសៀវភៅរបស់ខ្ញុំព្រះករុណាខ្ញុំបាទដែរ ដោយចាប់ផ្តើមពីសៀវភៅជំនួយសតិភាគទី ១ មក ។ ក្នុង ២០ ឆ្នាំនេះ មានសៀវភៅផ្សេងៗទៀត រហូតមកដល់ចុងក្រោយនេះឯងគឺសៀវភៅសិក្សាព្រះសូត្រភាគទី ៦ ។ ដើម្បីកុំឲ្យរំលងឆ្នាំនៃការសរសេរសៀវភៅជំនួយសតិ ទើបដាក់ឈ្មោះសៀវភៅជំនួយសតិតភាគគ្នា នាពេលបិទវគ្គសិក្សាប្រចាំឆ្នាំនៅភ្នំពេញ ដូច្នេះហើយទើបសៀវភៅជំនួយសតិភាគទី ២០ នេះ គឺជាសៀវភៅសិក្សាព្រះសូត្រភាគទី ៦ ។

នៅក្នុងសៀវភៅនេះ មានការរំលឹកដោយសង្ខេបអំពីព្រះសូត្រចំនួនដប់ ក្នុងបិដកលេខ ២២ មហាយមកវគ្គ ព្រមទាំងដកស្រង់អដ្ឋកថាខ្លះៗផង ទៅតាមទំព័រដូចខាងក្រោមនេះ គឺ


| | | |
|---|---|---|
| ១-ចូឡគោសិង្គសាលសូត្រ | ទំព័រ | ២ |
| ២-មហាគោសិង្គសាលសូត្រ | - | ១១ |
| ៣-មហាគោបាលសូត្រ | - | ២៨ |
| ៤-ចូឡគោបាលសូត្រ | - | ៣៧ |
| ៥-ចូឡសច្ចកសូត្រ | - | ៤៨ |

| | | |
|---|---|---|
| ៦-មហាសច្ចកសូត្រ | - | ៥៥ |
| ៧-ចូឡតណ្ហាសង្ខយសូត្រ | - | ៦៨ |
| ៨-មហាតណ្ហាសង្ខយសូត្រ | - | ៧៥ |
| ៩-មហាអស្សបុរសូត្រ | - | ៨៨ |
| ១០-ចូឡអស្សបុរសូត្រ | - | ៩១ |


នៅចន្លោះនៃព្រះសូត្រមួយទៅព្រះសូត្រមួយទៀត មានពាក្យរំលឹកផ្សេងៗសម្រាប់ពិចារណាអប់រំចិត្ត ជាជំនួយនៃគំនិត ។ គំនិតមនុស្សយើងសំខាន់ខ្លាំងណាស់ ព្រោះជាតួរៀបចំដំណើរជីវិត និងអាចដូរផ្លាស់សេចក្តីទុក្ខផ្លូវចិត្ត មកជាសេចក្តីសុខបាន ដោយសារការដូរគំនិតនេះឯង ។ ដូច្នេះសូមពុទ្ធបរិស័ទរីករាយក្នុងការអាន ឬស្តាប់តាមសមគួរដល់អធ្យាស្រ័យ រៀងៗព្រះអង្គ រៀងៗខ្លួន ។

**ភ្នំពេញ ថ្ងៃ ១៥ កើត ខែ ទុតិយាសាឍ ព.ស.២៥៥៩**
**ខ្ញុំព្រះករុណា ខ្ញុំបាទ ប៊ុត សាវង្ស**

# ព្រះសុត្តន្តបិដកខ្មែរលេខ ២២

## មជ្ឈិមនិកាយ មូលបណ្ណាសក

## មហាយមកវគ្គ

## មាន ១០ ព្រះសូត្រ គឺ


១ - ចូឡគោសិង្គសាលសូត្រ ២ - មហាគោសិង្គសាលសូត្រ

៣ - មហាគោបាលសូត្រ ៤ - ចូឡគោបាលសូត្រ

៥ - ចូឡសច្ចកសូត្រ ៦ - មហាសច្ចកសូត្រ

៧ - ចូឡតណ្ហាសង្ខយសូត្រ ៨ - មហាតណ្ហាសង្ខយសូត្រ

៩ - មហាអស្សបុរសូត្រ ១០ - ចូឡអស្សបុរសូត្រ

# ១.ចូឡគោសិង្គសាលសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅនាព្រះពន្លាឥដ្ឋ ក្នុងនាទិកគ្រាម ដែនវជ្ជី ។ នាទិកគ្រាមនេះនៅរវាង កោដិគ្រាមនិងក្រុងវេសាលី ក្នុងដំណើរធម្មយាត្រានៃពុទ្ធបរិស័ទយើង ចេញពីក្រុងរាជគ្រឹះ ដល់នាឡន្ទា ចេញពីនាឡន្ទាដល់ក្រុងបាដលីបុត្រអសោការាម ហើយបានឆ្លងទន្លេគង្គាដល់កោដិគ្រាម បន្តទៀតដល់នាទិកគ្រាម រួចបានដល់ក្រុងវេសាលី ។

ក្នុងព្រះសូត្រនេះ ព្រះដ៏មានព្រះភាគ ទ្រង់ស្តេចយាងអំពីនាទិកគ្រាម ចូលទៅកាន់គោសិង្គសាលវ័នក្នុងដែនវជ្ជីនោះឯង។ ក្នុងព្រៃគោសិង្គសាលវ័ន កាលនោះមានព្រះអរហន្តបីអង្គគង់អាស្រ័យនៅ គឺព្រះអនុរុទ្ធ ព្រះនន្ទិយៈ និងព្រះកិមិលៈ សុទ្ធតែចេញពីសក្យត្រកូលមកបួស ។ ក្នុងកិមិលត្ថេរគាថា ទុកនិបាត គឺបានដល់ ព្រះកិមិលៈ ដែលបានចេញបួសជាមួយនឹងព្រះអនុរុទ្ធហ្នឹងឯង ចំណែកព្រះនន្ទិយៈ ចេញបួសតាមក្រោយ ( នន្ទិយត្ថេរគាថា ឯកនិបាត ) ។

កាលដែលព្រះដ៏មានព្រះភាគ ទ្រង់យាងទៅដល់ហើយ

ព្រះអង្គពុំបានប្រទានសាធុការ អំពីរឿងមិនលំបាកដោយបិណ្ឌបាត នោះឡើយ ព្រោះការបរិភោគអាហារ គឺជារឿងទូទៅចំពោះសត្វទាំងឡាយ ហើយវាមិនសំខាន់អ្វីដោយគ្រាន់តែបានការរស់នៅនោះទេ ប៉ុន្តែព្រះអង្គទ្រង់ប្រទានសាធុការចំពោះការព្រមព្រៀងស្រុះស្រួល មិនទាស់ទែងគ្នា ដូចជាទឹកដោះលាយទឹក រមិលមើលគ្នាទៅវិញទៅមក ដោយចក្ខុគួរឲ្យស្រឡាញ់ ព្រោះក្នុងលោកសន្និវាសនេះ ពួកសត្វមានការទាស់ទែងគ្នាដោយច្រើន ទាំងក្នុងអបាយលោក ទាំងក្នុងមនុស្សលោក និងទាំងក្នុងទេវលោក ឯការដែលសត្វលោកទាំងនោះព្រមព្រៀងគ្នា រកបានដោយក្រ ។

ជាបន្ត ព្រះអង្គទ្រង់ត្រាស់សួរអំពីសេចក្ដីមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្ដៅនូវកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ ជាបន្តទៀត គឺព្រះអង្គត្រាស់សាកសួរនូវផាសុវិហារធម៌ ៩ បានដល់រូបជ្ឈាន ៤ អរូបជ្ឈាន ៤ និងនិរោធសមាបត្តិ ១ រួចហើយទើបព្រះដ៏មានព្រះភាគ ទ្រង់សម្ដែងនូវអានិសង្សនៃការព្រមព្រៀងគ្នាក្នុងទីនោះ ទ្រង់ក្រោកចាកអំពីអាសនៈ ចេញទៅ ដោយព្រះភិក្ខុទាំងបីអង្គតាមហែព្រះដ៏មានព្រះភាគ ដល់ទីដ៏សមគួរហើយ ទើបត្រឡប់មកវិញ ។

ក្នុងកាលនោះ មានសេនាបតីយក្សមួយអង្គឈ្មោះទីឃបរជន

មានបំណងដើម្បីប្រកាសគុណនៃព្រះភិក្ខុទាំងបីអង្គនោះ ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ ហើយក្រាបទូលថា ព្រះតថាគតជាព្រះអរហន្តសម្មាសម្ពុទ្ធ និងកុលបុត្រទាំងបីអង្គនោះ គឺព្រះអនុរុទ្ធ ព្រះនន្ទិយៈ ព្រះកិមិលៈ គង់នៅក្នុងប្រទេសណា បពិត្រព្រះអង្គ-ដ៏ចម្រើន ប្រទេសនោះជាលាភរបស់ពួកអ្នកដែនវជ្ជី បពិត្រព្រះអង្គ-ដ៏ចម្រើន ប្រទេសនោះជាលាភដែលប្រជាជនអ្នកដែនវជ្ជីបានល្អហើយ ។ ពួកទេវតា និងពួកព្រហ្ម បានប្រកាសនូវពាក្យរបស់ទីឃបរជនយក្សនេះ ឲ្យឮកងរំពងរហូតដល់អកនិដ្ឋកព្រហ្ម ក្នុងមួយរំពេចតែប៉ុណ្ណោះ ។

ខាងចុងនៃព្រះសូត្រនេះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីកុលបុត្រទាំងបីអង្គនោះ ប្រតិបត្តិដើម្បីប្រយោជន៍ដល់ជនច្រើន បើអ្នកណាៗ ដែលមានចិត្តជ្រះថ្លារលឹកដល់កុលបុត្រទាំងបីអង្គនោះ ការរលឹកនោះ តែងនាំមកនូវប្រយោជន៍ និងសេចក្ដីសុខដល់អ្នកនោះៗ អស់កាលជាអង្វែង ។

សូមអនុមោទនា !

# ពាក្យរំលឹក

ក្នុងលោកនេះ មិនមានអ្វីដែលល្អចំពោះយើង ឲ្យដូចជាខ្លួនយើងជាមនុស្សល្អនោះឡើយ ។

បើយើងមិនមែនជាមនុស្សល្អហើយ ប្រាកដជាមិនមានអ្នកណាមួយ មកជួយឲ្យយើងរួចផុតចាកទុក្ខបានឡើយ ។

កាលបើពិចារណា ឃើញមានបុគ្គលជាទីស្រឡាញ់របស់យើង នៅជុំវិញខ្លួនយើង ដូច្នេះហើយ គប្បីត្រូវចេះស្រឡាញ់ខ្លួនឯង ។

កាលបើពិចារណា ឃើញខ្លួនយើងជាទីស្រឡាញ់នៃអ្នកដទៃ ដូច្នេះហើយ គប្បីត្រូវចេះស្រឡាញ់ខ្លួនឯង ។

កាលបើពិចារណា ឃើញថាខ្លួនជាទីស្រឡាញ់របស់ខ្លួន គប្បី

រក្សាខ្លួនឲ្យល្អ ។

ការរក្សាខ្លួនឲ្យល្អ ដើម្បីបានជួយខ្លួនឯងផង បាននៅជាមួយនឹងអ្នកដែលយើងស្រឡាញ់ផង និងដើម្បីកុំឲ្យអ្នកដែលស្រឡាញ់យើងទាំងប៉ុន្មាននោះ ខកចិត្ត កើតទុក្ខ ។

កុំមើលងាយថា បាបតិចតួច ហើយចេះតែធ្វើចេះតែសន្សំនោះ ទាំងកុំមើលងាយថា បុណ្យតិចតួច ហើយមិនធ្វើ មិនសន្សំ រឿងទាំងពីរនេះ បើយើងសន្សំរឿយៗ គឺដូចជាទឹកភ្លោតស្រក់តក់ៗពេញបំពង់ដូច្នោះឯង ។

មិនមានអ្នកណាមួយ មកជួយសន្សំទុកដាក់បុណ្យឲ្យយើងទេ ដូច្នេះត្រូវតែចេះសន្សំបុណ្យ ទុកដាក់ថែរក្សាបុណ្យដោយខ្លួនឯង ។

យើងធ្វើបុណ្យ ដោយមិនចាំបាច់មានអ្នកណាមកធានាផលបុណ្យឲ្យយើងឡើយ ប៉ុន្តែកាលដែលយើងធ្វើបុណ្យ ស្តាប់ធម៌ទេសនារឿយៗហើយ អ្វីៗចេះតែល្អមករកយើងច្រើនឡើងៗ អ្វីៗដែលអាក្រក់មិនមានទេ ព្រោះមកអំពីបុណ្យផ្សេងៗដែលបុគ្គលបាន

សន្សំហើយ និងស្តាប់ព្រះធម៌ សិក្សាព្រះធម៌ នាំឲ្យសម្បូណ៌ដោយយោនិសោមនសិការ ។

យោនិសោមនសិការ គឺជាការធ្វើទុកក្នុងចិត្តត្រឹមត្រូវទៅតាមហេតុផល ធ្វើឲ្យអារម្មណ៍ទាំងពួង ជាបច្ច័យនៃសេចក្តីសុខក្នុងកុសលចិត្ត ប្រៀបដូចជាពូជផ្អែមក្នុងដើមអំពៅ ដូច្នោះឯង ។

អារម្មណ៍ទាំងពួង ប្រៀបដូចជាផែនដី ចំណែកយោនិសោ-មនសិការ ប្រៀបដូចជាពូជផ្អែមក្នុងដើមអំពៅ ក្នុងសេចក្តីដែលថា យោនិសោមនសិការ ជាបទដ្ឋាននៃគ្រប់កុសលធម៌ទាំងអស់ ។

ក្នុងចូឡគោសិង្គសាលសូត្រ ខ្លឹមសារនៅត្រង់ការព្រមព្រៀងគ្នា ការព្រមព្រៀងគ្នាគោរពធម៌វិន័យ គឺជាការគោរពព្រះបរមសាស្តាដ៏ក្រៃលែង ។

ដើម្បីការព្រមព្រៀងគ្នា យើងត្រូវចេះឲ្យសេចក្តីសំខាន់ដល់អ្នកដទៃ ព្រោះទឹកចិត្តមនុស្សយើងមិនអាចមើលរំលងបានទេ ត្រូវចេះផ្តល់កម្លាំងចិត្តឲ្យដល់គ្នា ។

មានមេត្តាចិត្ត មកអំពីមាននូវមេត្តានិមិត្ត គ្រឿងកំណត់ដែលនាំឲ្យមានមេត្តា គឺស្រឡាញ់អ្វីស្មើនឹងស្រឡាញ់ខ្លួនឯងមិនមានឡើយ ត្រូវយកខ្លួនឯងជាឧបមា គ្រប់គ្នាប្រាថ្នាសុខ ។ ត្រូវរៀនឲ្យអភ័យដល់អ្នកដទៃ ដើម្បីឲ្យអភ័យទៅបាន ត្រូវ ពិចារណាគុណអ្នកដទៃផង ហើយពិចារណានូវការខ្វះខាត ដែលជា ទោសរបស់ខ្លួនឯងផង ហើយត្រូវកុំភ្លេចគិតថា មិនមានអ្នកណាធ្វើលោភៈ ទោសៈ មោហៈ ឲ្យខ្លួនឯងទេ ។

ការឲ្យអភ័យ គឺជាតួសីលដ៏ប្រសើរ ប្រកបដោយសេចក្តីអត់ធន់ មេត្តាករុណា និងបញ្ញាចាក់ធ្លុះនូវការពិតក្នុងគ្រប់រឿងរ៉ាវផ្សេងៗ ។

សំខាន់បំផុតក្នុងជីវិត គឺមិនមានទុក្ខផ្លូវចិត្ត មិនមែននៅត្រង់មានលុយច្រើននោះទេ ដើម្បីមិនកើតទុក្ខផ្លូវចិត្ត គឺចិត្តត្រូវមានសតិជាទីពឹង ។

ត្រូវប្រយ័ត្នបិសាចក្នុងគំនិតរបស់ខ្លួនឯង បិសាចកិលេសវាឲ្យគិតថា អ្នកនេះជេរយើង មាក់ងាយយើង ប្រហារយើង ផ្ចាញ់ផ្ចាល

យើង យករបស់យើង ។ល។ ដូច្នេះ ពៀរវេរាមែងមិនស្ងប់រំងាប់ឡើយ ។ តាមសច្ចធម៌ ក្នុងលោកនេះអត់មានអ្នកណាម្នាក់ឡើយ បើអ៊ីចឹង សុខចិត្តទេ គឺមិនចាញ់ប្រៀបអ្នកណាៗ ហើយក៏មិនឈ្នះអ្នកណាៗដែរ មានតែឈ្នះទុក្ខក្នុងចិត្តរបស់ខ្លួនប៉ុណ្ណោះ ។

គួរមានស្មារតី រស់នៅក្នុងអារម្មណ៍របស់វិបស្សនាឲ្យបានរឿយៗ ព្រោះនេះជាលោកដែលមិនមានអភិជ្ឈានិងទោមនស្ស ។

អារម្មណ៍របស់វិបស្សនា ជាលោកនៃការរស់នៅដោយនេក្ខម្មសុខ ។

យើងគិតតែពីស្វែងរកលាភ រកយស... តើយើងមានគិតស្វែងរកខ្លួនឯងទេ តើខ្លួនយើងជាអ្វីទៅដែលជាអ្នកបានលាភ បានយសនោះ ក្រៅអំពីចិត្តចេតសិកដឹងអារម្មណ៍ ។

ព្រោះតែប្រាថ្នារកសេចក្ដីសុខក្នុងលាភ ក្នុងយស ក្នុងការសរសើរ ទើបធ្វើឲ្យការរស់នៅមិនបានសេចក្ដីសុខពិតប្រាកដ ។ សេចក្ដីសុខពិតប្រាកដ គឺប្រាសចាកសេចក្ដីប្រាថ្នា រស់នៅជាមួយនឹង

បញ្ញាឃើញធម្មតាធម៌តាមពិត ការពិតគ្រប់យ៉ាង សុទ្ធតែត្រឹមត្រូវស្រេចហើយ ។

## ផ្កាឈូកក្រហមរីកពេលព្រឹក

ផ្កាឈូកក្រហមរីកពេលព្រឹក     រីកច្រើនសន្ធឹកសុគន្ធា
រស្មីព្រះពុទ្ធចាកអង្គា     រុងរឿងដូចជាព្រះសុរិយា ។
ផ្ការីកហើយរោយរសាយក្លិន     ស្រីល្អមាសឆ្អិនគង់មរណា
រីឯចិត្តល្អដោយកុសលា     មិនរោយឡើយណារស់រឿងរះ ។
លះបាបធ្វើបុណ្យចិត្តបរិសុទ្ធ     ឱវាទព្រះពុទ្ធទ្រង់តេជះ
សម្ដែងប្រាប់ផ្លូវជ័យជម្នះ     បានដល់ផ្លូវលះលាលោកា ។
សូមតម្កល់គុណរតនត្រៃ     ដោយដួងហឫទ័យលើសិរសា
ទានសីលភាវនាស្ដាប់ទេស្នា     លះវដ្ដសង្សារនិព្វានហោង ៕

ដោយ **ប.ស.ច.**

# ២-មហាគោសិង្គសាលសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាគោសិង្គសាលវ័ន ជាមួយនឹងព្រះថេរៈជាសាវ័ក សុទ្ធតែមានព្រះនាមល្បីល្បាញ ជាច្រើនព្រះអង្គ គឺព្រះសារីបុត្ត ព្រះមហាមោគ្គល្លាន ព្រះមហាកស្សបៈ ព្រះអនុរុទ្ធ ព្រះកង្ខារេវតៈ និងព្រះអានន្ទ ព្រមមួយអន្លើ ដោយភិក្ខុសង្ឃដែលមានកេរ្តិ៍ឈ្មោះប្រមាណជាបីម៉ឺនអង្គ ។

**ព្រះសារីបុត្ត** មានព្រះនាមល្បីល្បាញនៅក្នុងព្រះពុទ្ធសាសនា ដោយគុណមានសីលជាដើម គឺដូចជាព្រះអាទិត្យ ឬព្រះចន្ទនៅកណ្ដាលមេឃ ប្រាកដដល់អ្នកមានភ្នែក ពុំនោះសោតគឺដូចមហាសាគរ បានប្រាកដដល់បុគ្គលដែលឈរនៅនឹង មាត់ច្រាំងនោះឯង ។ គប្បីជ្រាបនូវគុណដ៏ធំរបស់ព្រះមហាថេរ ដែលមាននៅក្នុងព្រះសូត្រផ្សេងៗទៀត គឺ

-ធម្មទាយាទសូត្រ បិដកលេខ ២០ ទំព័រ ៣៩ ព្រះសារីបុត្តសម្ដែងធម៌បន្តអំពីព្រះដ៏មានព្រះភាគ ។

-អនង្គណសូត្រ បិដកលេខ ២០ ទំព័រ ៧៨ ព្រះសារីបុត្ត

សម្តែង ព្រះមហាមោគ្គល្លានសាកសួររឿយៗ ។

-សម្មាទិដ្ឋិសូត្រ បិដកលេខ ២០ ទំព័រ ១៥២ ព្រះសារីបុត្ត សម្តែង ភិក្ខុទាំងឡាយសាកសួរអំពីសម្មាទិដ្ឋិ ដោយបរិយាយ ដទៃៗ ។

-មហាសីហនាទសូត្រ បិដកលេខ ២០ ទំព័រ ២៥៨ ព្រះសារីបុត្ត ក្រាបទូលព្រះដ៏មានព្រះភាគ អំពីពាក្យរបស់ សុនក្ខត្តលិច្ឆវិបុត្ត ។

-រថវិនីតសូត្រ បិដកលេខ ២១ ទំព័រ ៨០ ព្រះសារីបុត្ត សាកសួរព្រះបុណ្ណមន្តាណីបុត្ត អំពីវិសុទ្ធិ ៧ ។

-មហាហត្ថិបទោបមសូត្រ បិដកលេខ ២១ ទំព័រ ១៩៣ ព្រះ-សារីបុត្តសម្តែងដល់ភិក្ខុទាំងឡាយ អំពីអរិយសច្ចតាមទ្វារទាំង ៦ ។

-មហាវេទល្លសូត្រ បិដកលេខ ២២ ទំព័រ ២៦៨ ព្រះសារីបុត្ត ឆ្លើយបញ្ហាដែលព្រះមហាកោដ្ឋិកៈសាកសួររឿយៗ ជាបន្តបន្ទាប់ ។

-ចាតុមសូត្រ បិដកលេខ ២៣ ទំព័រ ៣៣០ ព្រះសារីបុត្ត និងព្រះមហាមោគ្គល្លាន នាំភិក្ខុសង្ឃ ៥០០អង្គ ចូលគាល់ ព្រះដ៏មានព្រះភាគ នៅស្រុកចាតុមា ។ ព្រះអង្គទ្រង់ត្រាស់សម្តែង-

ធម៌អំពីភ័យ ៤ យ៉ាង ។

-ទីឃនខសូត្រ បិដកលេខ ២៤ ទំព័រ ៤៨ ព្រះសារីបុត្ត ស្តាប់ព្រះសូត្រនេះហើយ បានសម្រេចព្រះអរហត្ត នៅថ្ងៃ ១៥ កើត ខែ មាឃ ព្រះដ៏មានព្រះភាគទើបតែគង់នៅវត្តវេឡុវ័នបាន ១ ខែ ប៉ុណ្ណោះ ។

-អនុបទសូត្រ បិដកលេខ ២៦ ទំព័រ ២១៤ ព្រះដ៏មានព្រះ-ភាគ សម្តែងសរសើរគុណព្រះសារីបុត្ត ពេញមួយព្រះសូត្រនេះ ។

-សេវិតព្វាសេវិតព្វសូត្រ បិដកលេខ ២៦ ទំព័រ ២៦៨ ព្រះសារីបុត្ត សម្តែងចែកសេចក្តីនៃព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងដោយសង្ខេប ។

-សច្ចវិភង្គសូត្រ បិដកលេខ ២៨ ទំព័រ ២០១ ព្រះដ៏មានព្រះ-ភាគ ទ្រង់ត្រាស់សរសើរព្រះសារីបុត្ត ក្នុងការសម្តែងនូវអរិយសច្ច ទាំង ៤ ហើយព្រះសារីបុត្តក៏បានសម្តែងអំពីអរិយសច្ចទាំង ៤ នេះ ផងដែរ ។

-បិណ្ឌបាតបារិសុទ្ធិសូត្រ បិដកលេខ ២៨ ទំព័រ ៣៥៦ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សរសើរព្រះសារីបុត្ត ដែលច្រើនប្រព្រឹត្ត ទៅដោយសុញ្ញតាវិហារធម៌ ជាវិហារធម៌នៃមហាបុរស ។

-សម្បសាទនីយសូត្រ បិដកលេខ ១៨ ទំព័រ ១៩៩ ព្រះសារីបុត្តសម្តែងសរសើរគុណព្រះដ៏មានព្រះភាគ ។

-សង្គីតិសូត្រ បិដកលេខ ១៩ ទំព័រ ១២៣ ព្រះសារីបុត្តសម្តែងធម៌ចាប់ពីពួកមួយៗ ដល់ពួកដប់ៗ រាប់រាយទាំងអស់មាន ១០១៤ ធម៌ ។

-ទសុត្តរសូត្រ បិដកលេខ ១៩ ទំព័រ ២៥៤ ព្រះសារីបុត្តសម្តែងធម៌ដប់ៗ ចាប់ពីពួកមួយដល់ពួកដប់ រាប់រាយមានធម៌ទាំងអស់ ៥៥០ ធម៌ ។

-បវារណាសូត្រ បិដកលេខ ៣០ ទំព័រ ១៦៤ ព្រះអង្គទ្រង់សរសើរព្រះសារីបុត្ត ដែលបានពោលពាក្យបវារណា ក្នុងរាត្រីថ្ងៃ ១៥ កើត ។

-សុសិមសូត្រ បិដកលេខ ២៩ ទំព័រ ១៧២ ព្រះដ៏មានព្រះ-ភាគ ព្រះអានន្ទ និងសុសិមទេវបុត្ត សរសើរគុណព្រះសារីបុត្ត ។

-ថេរបញ្ហសូត្រ ព្រះសូត្រផ្សេងៗ ដែលមានបញ្ហាធម៌សាកសួរព្រះសារីបុត្ត គឺព្រះដ៏មានព្រះភាគក៏បានសួរ ភិក្ខុទាំងឡាយក៏បានសួរ ដូចក្នុងបិដកលេខ ៤៩ ទំព័រ ៦០ ជាដើម។

-មហានិទ្ទេស បិដកលេខ ៦៤ ដល់ ៦៦ (ចូឡនិទ្ទេស) បិដក

លេខ ៦៧ ដល់ ៦៨ គឺសម្តែងចែកសេចក្តីនៃព្រះពុទ្ធដីកា ។

-បដិសម្ភិទាមគ្គ បិដកលេខ ៦៩ ដល់ ៧១ ព្រះសារីបុត្ត សម្តែង ៣ វគ្គ គឺមហាវគ្គ មានញាណកថា ៧៣ ជាដើម យុគនទ្ធវគ្គ មានយុគនទ្ធកថាជាដើម និងបញ្ញាវគ្គ មានមហាបញ្ញាកថាជាដើម ។

-ថេរសីហនាទសូត្រ ព្រះសូត្រផ្សេងៗដែលព្រះសារីបុត្តបន្លឺសីហនាទ មានជាអាទិ៍ដូចជានៅបិដកលេខ៤៩ ទំព័រ ៤៤ ព្រះ-មហាថេរបានប្រារព្ធកាយគតាសតិ បន្លឺសីហនាទចំពោះព្រះភក្ត្រនៃព្រះដ៏មានព្រះភាគ ៩ មុខ ។

-ប្រវត្តិនៃការចូលកាន់ផ្នួស ប្រវត្តិនៃអគ្គសាវ័ក ប្រវត្តិនៃឯតទគ្គៈ ប្រវត្តិក្នុងការចូលកាន់ព្រះនិព្វាន ជាដើម ។

**ព្រះមហាមោគ្គល្លាន** មានព្រះនាមល្បីល្បាញនៅក្នុងព្រះពុទ្ធសាសនា ដោយគុណមានសីលគុណជាដើម និងជាបុគ្គលដ៏សំខាន់មួយព្រះអង្គ ប្រាកដនៅក្នុងព្រះសូត្រផ្សេងៗ មានជាអាទិ៍គឺ

-អនុមានសូត្រ បិដកលេខ ២០ ទំព័រ ៣៥៤ ព្រះមហា-មោគ្គល្លាន សម្តែងអំពីធម៌ដែលធ្វើឲ្យគេលំបាកទូន្មាន ១៦ ប្រការ ។

-ចូឡតណ្ហាសង្ខយសូត្រ បិដកលេខ ២២ ទំព័រ ១៣៤ ព្រះមហាមោគ្គល្លាន និមន្តតាមទៅសួរធម៌អំពីព្រះឥន្ទ្រ នៅនាឋាន

តាវត្តិង្ស ដែលព្រះឥន្ទទើបតែបានស្តាប់អំពីព្រះដ៏មានព្រះភាគហើយថ្មីៗ ។

-មារតជ្ជនីយសូត្រ បិដកលេខ ២២ ទំព័រ ៣៧៨ ព្រះមហាមោគ្គល្លាន បណ្តេញមារឲ្យចេញពីពោះរបស់លោក ទាំងបានសម្តែងអតីតជាតិរបស់លោក ធ្លាប់កើតជាទូសីមារ បៀតបៀនព្រះវិធុរៈ ដែលជាអគ្គសាវ័កស្តាំនៃព្រះកកុសន្ធោសម្មាសម្ពុទ្ធ ។

-វិមានវត្ថុ បិដកលេខ ៥៥ ។

-បេតវត្ថុ បិដកលេខ ៥៦ ។

-ការញ៉ាំងប្រាសាទឲ្យញាប់ញ័រ ការទូន្មាននន្ទោបនន្ទនាគរាជប្រកបដោយឥទ្ធិបាទទាំងអស់ ។

-ការនិមន្តទៅកាន់យមលោកទេវលោក និងប្រវត្តិនៃការបួសប្រវត្តិនៃអគ្គសាវ័ក ប្រវត្តិនៃឯតទគ្គៈ ប្រវត្តិក្នុងការចូលកាន់ព្រះនិព្វានជាដើម ។

**ព្រះមហាកស្សបៈ** ជាព្រះអង្គធំមួយព្រះអង្គបន្ទាប់ពីព្រះអគ្គសាវ័កមក ប្រសើរដោយសីលគុណជាដើម និងល្បីល្បាញព្រះនាមដោយអំណាចព្រះសូត្រមានជាអាទិ៍គឺ

-ចីវរសូត្រ បិដកលេខ ៣២ ទំព័រ ១៦៤ ព្រះសម្មាសម្ពុទ្ធទើប

តែបរិនិព្វានថ្មីៗ ព្រះមហាកស្សបៈ ទូន្មានព្រះអានន្ទដោយវោហារថា ព្រះអានន្ទជាកុមារមិនដឹងប្រមាណ ។

-ចន្ទោបមសូត្រ បិដកលេខ ៣២ ទំព័រ ១២០ ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់សរសើរព្រះមហាកស្សបៈថាដូចជាព្រះចន្ទ ។

-កស្សបសំយុត្តទាំងអស់ បិដកលេខ ៣២ ចាប់ពីទំព័រ ១១១ ដល់ទំព័រ ១៨០ មាន ១៣ ព្រះសូត្រ ។

-មហាអរិយវង្សសូត្រ បិដកលេខ ៤២ ទំព័រ ៦៧ ព្រះអង្គទ្រង់ត្រាស់អំពីសេចក្ដីសន្ដោស និងការសរសើរគុណនៃសេចក្ដីសន្ដោសក្នុងចីវរជាដើម ដែលត្រូវនឹងឯតទគ្គៈរបស់ព្រះមហាកស្សបត្ថេរ ។

-ប្រវត្តិនៃការបួស ។ល។ ប្រវត្តិក្នុងបឋមសង្គាយនារហូតដល់បរិនិព្វាននៅភ្នំកុក្កុដបាទ ។

**ព្រះអនុរុទ្ធ** ក៏ជាព្រះថេរៈធំមួយអង្គ ដែលមានព្រះនាមល្បីល្បាញ ដោយសីលាទិគុណ កំពូលលើភិក្ខុទាំងឡាយ ខាងមានទិព្វចក្ខុ និងល្បីល្បាញព្រះនាមដោយព្រះសូត្រមានជាអាទិ៍គឺ

-ចូឡគោសិង្គសាលសូត្រ បិដកលេខ ២២ ទំព័រដើមគេ មានសេចក្ដីនៅក្នុងព្រះសូត្រទី ១ នៃសៀវភៅនេះ ។

-នឡកបានសូត្រ បិដកលេខ ២៣ ទំព័រ ៣៤៧

ព្រះដ៏មានព្រះភាគត្រាស់សួរព្រះអនុរុទ្ធជាដំបូងគេ អំពីការត្រេកអរក្នុងព្រហ្មចរិយធម៌ ។

-អនុត្តរិយសូត្រ បិដកលេខ ៤៦ ទំព័រ ៩៣ ព្រះអនុរុទ្ធមានទិព្វចក្ខុ ប្រសើរលើសអស់ភិក្ខុទាំងឡាយ លោកអាចឃើញព្រះសម្មាសម្ពុទ្ធជាដើម ក្នុងទីឆ្ងាយបាន ដែលជាកំពូលនៃទស្សនានុត្តរិយៈ ។

-ឧបក្កិលេសសូត្រ បិដកលេខ ២៧ ទំព័រ ១២៩ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីឧបក្កិលេសទាំងឡាយ ឲ្យព្រះអនុរុទ្ធជាដើម បានស្តាប់នៅនាបាចីនវំសៈ ។

-អនុរុទ្ធសូត្រ បិដកលេខ ២៧ ទំព័រ ១០៨ ព្រះអនុរុទ្ធឆ្លើយបញ្ហា ដែលជាងឈើបានក្រាបទូលសួរអំពី អប្បមាណចេតោវិមុត្តិនិងមហគ្គតចេតោវិមុត្តិ ។

-មហាបុរិសវិតក្កសូត្រ បិដកលេខ ៤៨ ទំព័រ ១៤៤ ព្រះអនុរុទ្ធមានសេចក្តីត្រិះរិះតាមបែបមហាបុរសបាន ៧ ប្រការ ព្រះដ៏មានព្រះភាគ ទ្រង់យាងទៅដល់ហើយ ត្រាស់ឲ្យព្រះអនុរុទ្ធត្រិះរិះនូវមហាបុរិសវិតក្កមួយទៀត ជាគម្រប់ ៨ ។

-អនុរុទ្ធសូត្រ បិដកលេខ ៤៨ ទំព័រ ២១០ ព្រះអនុរុទ្ធក្រាប

ទូលព្រះដ៏មានព្រះភាគ អំពីពួកទេវតាដែលនាំគ្នាចូលមករកលោក ព្រោះពួកទេវតាទាំងនោះ រលឹកនឹកគុណព្រះអនុរុទ្ធ កាលដែលព្រះអនុរុទ្ធនៅជាស្ដេចចក្រពីជាតិមុន បានណែនាំឲ្យពួកគេរក្សាសីល ទើបពួកគេបានកើតជាទេវតា ។

-ប្រវត្តិនៃការចេញបួស ប្រវត្តិឯតទគ្គៈ និងប្រវត្តិរឿងរ៉ាវក្នុងពេលដែលព្រះដ៏មានព្រះភាគបរិនិព្វានជាដើម ។

**ព្រះរេវតត្ថេរ** ជាព្រះថេរៈល្បីល្បាញព្រះនាម ជាព្រះអរហន្តកំពូលលើភិក្ខុទាំងឡាយ ផ្នែកខាងមានឈាន គឺលោកច្រើនដោយការចូលសមាបត្តិ ទាំងយប់ទាំងថ្ងៃ ។

**ព្រះអានន្ទត្ថេរ** ជាអង្គដ៏សំខាន់ ល្បីល្បាញព្រះនាមក្នុងការបម្រើព្រះដ៏មានព្រះភាគ និងជាភិក្ខុកំពូលខាងពហុស្សូត នៅក្នុងព្រះសូត្រមានជាអាទិ៍គឺ

-សេក្ខប្បដិបទាសូត្រ បិដកលេខ ២៣ ទំព័រ ៤0 ព្រះអានន្ទ-ត្ថេរ ទទួលព្រះពុទ្ធដីកា សម្ដែងព្រះធម៌បន្តអំពីព្រះដ៏មានព្រះភាគ ។

-ពាហិតិយសូត្រ បិដកលេខ ២៤ ទំព័រ ៤៥៦ ព្រះអានន្ទឆ្លើយបញ្ហាដែលព្រះបាទបសេនទិកោសលទូលសួរ នៅមាត់ស្ទឹងអចិរវតី ព្រះរាជាជ្រះថ្លាបូជាសំពត់ពាហិតិកា ។

-អានេញ្ជសប្បាយសូត្រ បិដកលេខ ២៦ ទំព័រ ១៣៩ ព្រះ-អានន្ទ ទូលសួរបញ្ហាធម៌ដ៏មានជម្រៅ ចំពោះព្រះដ៏មានព្រះភាគ ។

-គោបកមោគ្គល្លានសូត្រ បិដកលេខ ២៦ ទំព័រ ១៦៨ ព្រះអានន្ទ ឆ្លើយបញ្ហាធម៌ដែលគោបកមោគ្គល្លានព្រាហ្មណ៍ និង វស្សការព្រាហ្មណ៍ទូលសួរ ក្នុងកាលដែលព្រះដ៏មានព្រះភាគទើបតែបរិនិព្វានថ្មីៗ ។

-ពហុធាតុកសូត្រ បិដកលេខ ២៦ ទំព័រ ៣១១ ព្រះអានន្ទ ទូលសួរព្រះដ៏មានព្រះភាគអំពីភិក្ខុជាបណ្ឌិត ។

-ចូឡសុញ្ញតសូត្រ បិដកលេខ ២៧ ទំព័រ ១ ព្រះអានន្ទ ទូលសួរព្រះដ៏មានព្រះភាគអំពីពាក្យដែលធ្លាប់បានស្តាប់មក ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងអំពីសុញ្ញតាវិហារធម៌ ។

-មហាសុញ្ញតសូត្រ បិដកលេខ ២៧ ទំព័រ ១៧ ព្រះដ៏មាន-ព្រះភាគត្រាស់សួរព្រះអានន្ទ អំពីភិក្ខុទាំងឡាយដែលនៅជុំគ្នា ហើយព្រះអង្គទ្រង់ទូន្មានឲ្យភិក្ខុមានការនៅដោយស្ងប់ស្ងាត់ នឹងបានដោយមិនលំបាក នូវនេក្ខម្មសុខ វិវេកសុខ ឧបសមសុខ សម្ពោធិសុខ ។

-អច្ឆរិយព្ភូតធម្មសូត្រ បិដកលេខ ២៧ ទំព័រ ៤០ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ឲ្យព្រះអានន្ទសម្តែងធម៌ អំពីសេចក្តី

អស្ចារ្យចម្លែករបស់ព្រះតថាគត ។

-អានន្ទភទ្ទេករត្តសូត្រ បិដកលេខ ២៨ ទំព័រ ៩ ព្រះអានន្ទ ពន្យល់ណែនាំ ពួកភិក្ខុទាំងឡាយ អំពីបុគ្គលមានរាត្រីមួយដ៏ចម្រើន ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សរសើរព្រះអានន្ទ ។

-មហានិទានសូត្រ បិដកលេខ ១៦ ទំព័រ ១១៧ ព្រះអានន្ទ ប្រកាសអំពីបដិច្ចសមុប្បាទធម៌ដ៏មានជម្រៅ បានប្រាកដដល់បញ្ញានៃ ព្រះអានន្ទនោះឯង ហាក់ដូចជារាក់ ទើបព្រះពុទ្ធអង្គទ្រង់ត្រាស់អំពី ជម្រៅនៃធម៌នោះ ។

-មហាបរិនិព្វានសូត្រ បិដកលេខ ១៦ ទំព័រ ១៥៤ ដល់ ៣៥០ ព្រះអានន្ទ និមន្តជាប់តាមព្រះតថាគត តាមបម្រើព្រះអង្គ ហូរហែរហូត មានរឿងរ៉ាវព្រះអានន្ទច្រើន ។

-សុភសូត្រ បិដកលេខ ១៥ ទំព័រ ១៦០ ព្រះដ៏មានព្រះភាគ ទើបតែបរិនិព្វាន ព្រះអានន្ទនិមន្តមកក្រុងសាវត្ថី សម្តែងឆ្លើយ បញ្ហាធម៌ដែលសុភមាណពបានទូលសួរ អំពីគោលការណ៍ ព្រះពុទ្ធសាសនា ។

-នៅក្នុងមហាគោសិង្គសាលសូត្រនេះ ក៏បានប្រាកដនូវគុណ នៃព្រះមហាថេរទាំង ៦ អង្គ ដែលបានប្រកាសអំពីព្រៃគោសិង្គ-

សាលវ័ននេះឯង រុងរឿងដោយភិក្ខុអង្គណានោះ គឺព្រះមហាថេរមួយអង្គៗ មានព្រះហឫទ័យអនុគ្រោះដល់សព្រហ្មចារីហើយ ទើបបានប្រកាសឡើង ។

**ព្រះអានន្ទ** ជាពហុស្សូតដោយខ្លួនឯងហើយ ទាំងអធ្យាស្រ័យរបស់លោកក៏មានដូច្នេះថា ឱហ្ន៎ ពួកសព្រហ្មចារីក្នុងព្រះសាសនា គប្បីជាពហុស្សូតដូច្នេះឯង ។ ព្រោះហេតុអ្វី ព្រោះថាអ្វីដែលគួរ អ្វីដែលមិនគួរ អ្វីដែលមានទោស អ្វីដែលមិនមានទោស ទោសធ្ងន់ឬស្រាល កែខៃបានឬមិនបាន រមែងប្រាកដដល់ភិក្ខុដែលជាពហុស្សូត ។ ភិក្ខុជាពហុស្សូត ពិចារណានូវព្រះពុទ្ធវចនៈ ដែលខ្លួនរៀនហើយ គិតថា សីលលោកពោលទុកហើយក្នុងទីនេះ សមាធិលោកពោលទុកហើយក្នុងទីនេះ វិបស្សនាលោកពោលទុកហើយក្នុងទីនេះ មគ្គផលនិព្វានលោកពោលទុកហើយក្នុងទីនេះ ហើយបំពេញសីលសមាធិបញ្ញា ចម្រើនមគ្គ ជាក់ច្បាស់នូវផល បានដល់នូវព្រះនិព្វាន ។

**ព្រះរេវតៈ** កំពូលជាអ្នកមានឈានលើភិក្ខុទាំងឡាយត្រេកអរហើយក្នុងឈាន ព្រោះហេតុដូច្នោះ ទើបលោកគិតយ៉ាងនេះថា ឱហ្ន៎ ពួកសព្រហ្មចារីរបស់យើង អង្គុយម្នាក់ឯង ធ្វើកសិណបរិកម្មញ៉ាំងសមាបត្តិ ៨ ឲ្យកើត ចម្រើនវិបស្សនាមានឈានជាបទដ្ឋាន

សម្រេចនូវលោកុត្តរធម៌ ។

**ព្រះអនុរុទ្ធ** កំពូលខាងទិព្វចក្ខុ ទាំងអធ្យាស្រ័យរបស់លោក ក៏បានតាំងនៅដូច្នេះថា ឱហ្ន៎ ពួកសព្រហ្មចារី គប្បីចម្រើននូវអាលោកកសិណ ឃើញសត្វទាំងឡាយ កំពុងចុតិ កំពុងបដិសន្ធិក្នុងចក្កវាឡច្រើនពាន់ ដោយទិព្វចក្ខុ ញុំាងចិត្តឲ្យសង្វេគព្រោះវដ្តភ័យ ចម្រើនវិបស្សនាសម្រេចនូវលោកុត្តរធម៌ ។

**ព្រះមហាកស្សបៈ** ជាអង្គកំពូលខាងធុតង្គ លោកមានអធ្យាស្រ័យដូច្នេះថា ឱហ្ន៎ ពួកសព្រហ្មចារីជាធុតវាទ គប្បីញុំាងតណ្ហាព្រមទាំងបច្ច័យឲ្យស្ងួតហួតហែង ដោយអានុភាពនៃធុតង្គ ហើយ កម្ចាត់កិលេសមានប្រការផ្សេងៗដោយវិបស្សនាញាណ និងមគ្គញ្ញាណ ជាក់ច្បាស់នូវព្រះនិព្វាន ។

**ព្រះមហាមោគ្គល្លាន** ដល់នូវទីបំផុតនៃសមាធិបារមី ជាកំពូលលើភិក្ខុទាំងឡាយ ផ្នែកខាងមានឫទ្ធិ ប៉ុន្តែព្រះមហាថេរ បានលើកឡើងនូវអភិធម្មកថា ដោយមានអធ្យាស្រ័យដូច្នេះថា ឱហ្ន៎ ពួកសព្រហ្មចារី គប្បីជាអ្នករៀនអភិធម្ម ជាធម្មកថិក ជាអ្នកពោលធម៌ត្រឹមត្រូវ និងជាអ្នកមានឈានចម្រើនវិបស្សនា ធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌ ។

**ព្រះសារីបុត្ត** ដល់នូវទីបំផុតនៃបញ្ញាបារមី អាចញុំាងចិត្តឲ្យ

ប្រព្រឹត្តទៅនៅក្នុងអំណាចរបស់ខ្លួនបានដោយបញ្ញា បុគ្គលដែលមានបញ្ញាអន់ថយ គឺមិនអាចឡើយ ។ ពិតណាស់ ភិក្ខុដែលមានបញ្ញាអន់ថយ រមែងប្រព្រឹត្តទៅនៅក្នុងអំណាចរបស់ចិត្តដែលកើតឡើង ញាប់ញ័រទៅខាងនេះ ញាប់ញ័រទៅខាងនោះ ពីរបីថ្ងៃក៏ទៅជាគ្រហស្ថ បានជួបនូវវិបត្តិនិងរឿងដែលមិនជាប្រយោជន៍ ព្រោះហេតុដូច្នោះ ព្រះ-មហាថេរ ទើបមានព្រះហឫទ័យដូច្នេះថា ឱហ្ន៎ ពួកសព្រហ្មចារី មិនគប្បីប្រព្រឹត្តទៅក្នុងអំណាចនៃចិត្តឡើយ គប្បីញុំាងចិត្តឲ្យប្រព្រឹត្តទៅក្នុងអំណាចនៃខ្លួនវិញ កម្ចាត់បង់នូវភាពស្រវឹង ការញាប់ញ័រ និងធម៌ជាសត្រូវចេញពីចិត្ត គ្រប់គ្រងចិត្តមិនឲ្យរាយមាយទៅខាងក្រៅ ចម្រើនវិបស្សនា ធ្វើឲ្យសម្រេចនូវលោកុត្តរធម៌ ។

**ព្រះតថាគត** ទ្រង់លើកយកសេចក្ដីព្យាយាមរបស់ព្រះអង្គនៅនាគល់ព្រះពោធិព្រឹក្ស បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ មកជាតួយ៉ាង ដើម្បីអនុគ្រោះដល់ពួកជនជំនាន់ក្រោយ ឲ្យប្រារព្ធសេចក្ដីព្យាយាមដើម្បីការអស់ទៅនៃទុក្ខទាំងពួង គឺព្រះអង្គទ្រង់សម្ដែងចំណុចសំខាន់ ដែលជាខ្លឹមសារសម្រាប់កល្យាណបុថុជ្ជន ។

សូមអនុមោទនា !

# ពាក្យរំលឹក

បើចេះតែចង់ឲ្យអ្វីៗដូចចិត្តខ្លួនឯង យើងមិនអាចរកការពិតឃើញឡើយ ។

សប្បាយព្រោះបានដូចចិត្ត វាជាធម្មតារបស់សត្វលោក សូម្បីតែសត្វតិរច្ឆាន ប៉ុន្តែសប្បាយព្រោះបានដឹងថា អ្វីៗមិនមែនចេះតែបានដូចចិត្ត នេះទើបជាក្តីសប្បាយរបស់អ្នកមានបញ្ញារកឃើញសច្ចៈក្នុងលោក ។

សច្ចៈក្នុងលោក គឺលោកនេះ មានការពិតខ្លួនឯងស្រេចស្រាប់ទៅហើយ ។

ពាក្យថា ការពិត គឺសំដៅយកលក្ខណៈនៃអ្វីៗដែលកើតឡើងត្រឹមត្រូវតាមហេតុ មិនមែនតាមការទាមទារ មិនមែនតាមការបង្គាប់បញ្ជា មិនមែនតាមការអង្វរករ មិនមែនខុសហេតុ និងមិនមែនអត់

ហេតុឡើយ ទាំងដែលកើតឡើងហើយ រមែងរលត់ទៅវិញ មិនតាំងនៅក្នុងទីណានោះទេ ។

## បទរំលឹកអំពីចិត្ត

នឿយកាយគួរសម្រាក ចិត្តលំបាកគួរលះបង់
គឺលះនូវចំណង់ រលឹកត្រង់ត្រឹមតែចិត្ត ។
តណ្ហាមិនចេះស្កប់ ជាប់នឹងទ្រព្យមួយជីវិត
តើអ្វីជាខ្លួនពិត ក្រៅពីចិត្តដឹងអារម្មណ៍ ។
រៀនរស់នៅជាសុខ រឿងគ្រប់មុខចិត្តរៀបចំ
សិក្សាក្នុងអារម្មណ៍ ចិត្តអប់រំអារម្មណ៍ល្អ ។
រឿងល្អក្នុងជីវិត ស្ថិតលើចិត្តសុទ្ធបវរ
មិនមែនរឿងល្អៗ ត្រូវទៅរក៍ពីគេទេ ។
សុខព្រោះបានដូចចិត្ត សុខនេះពិតជាខ្ញុំគេ
រវល់ឥតទំនេរ ប្រឹងរិះរេតាមតណ្ហា ។
សុខស្ងប់គ្រប់អារម្មណ៍ សុខនេះចំផ្លូវសាស្តា
សុខព្រោះមានបញ្ញា លះតណ្ហាសិក្សាលោក ។
មិនបាច់បានដូចចិត្ត ឃើញការពិតឥតក្តីសោក
មិនបាច់ដេញតាមលោក បានជ័យជោគព្រោះអស់ចង់ ។

ចិត្តអ្វីក៏ចិត្តដែរ គឺឲ្យតែរលឹកត្រង់
មិនបាច់បានដូចចង់ រលឹកត្រង់ត្រឹមតែចិត្ត ។
ឥឡូវចិត្តមានហើយ មិនបាច់ឡើយទៅខ្វល់គិត
ចិត្តអ្វីក៏ជាចិត្ត បរមត្ថពិតមិនមែនខ្លួន ។
លោកនេះជាសាលា ត្រូវសិក្សាឲ្យមាំមួន
បរិញ្ញាទៅតាមក្បួន បានរួចខ្លួនដល់និព្វាន ៕

ដោយ **ប.ស.វ.**

## ប្រយ័ត្នបីយ៉ាង

បើយើងស្រឡាញ់អ្នកដទៃ សូមលៃឲ្យសព្វកុំស្អប់ខ្លួន
ប្រយ័ត្នរាគៈកម្មលាក់ពួន មិនអាចរួចខ្លួនក្លាយជាទុក្ខ។
បើយើងនោះស្អប់អ្នកណាហើយ កុំឡើយយើងនោះប្រទូស្តសុខ
ប្រយ័ត្នទោសៈឲ្យកើតទុក្ខ ជីវិតស្មាញស្មុគព្រោះវេរា។
បើយើងស្រឡាញ់ខ្លួនឯងពិត សូមកុំអាណិតអវិជ្ជា
ប្រយ័ត្នមោហៈខ្លួនក្លាយជា សត្រូវផ្តន្ទាឲ្យខ្លួនឯង ៕

ដោយ **ប.ស.វ.**

# ៣. មហាគោបាលសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាមហាវិហារព្រះជេតពន ។ ព្រះអង្គទ្រង់សម្តែងអំពីអង្គ ១១ នៃអ្នកឃ្វាលគោ ដែលមិនអាចដើម្បីរក្សាហ្វូងគោឲ្យចម្រើនឡើងបានឡើយ រួចហើយព្រះអង្គទ្រង់សម្តែងអំពីអង្គ១១ ផ្ទុយគ្នា ដែលគង្វាលគោគួរដើម្បីរក្សានូវហ្វូងគោ គួរដើម្បីញ៉ាំងហ្វូងគោឲ្យចម្រើនឡើងបាន ។ អង្គ ១១ នៃសេចក្តីចម្រើនគឺ

១- **រូបញ្ញូ ហោតិ** ស្គាល់រូបគោ

២- **លក្ខណកុសលោ ហោតិ** ឈ្លាសក្នុងលក្ខណៈ

៣- **អាសាដិកំ សាដេតា ហោតិ** ឆ្កឹះពងរុយ

៤- **វណំ បដិច្ឆាទេតា ហោតិ** បិទដំបៅ

៥- **ធូមំ កត្តា ហោតិ** បំពក់ភ្នក់

៦- **តិត្ថំ ជានាតិ** ស្គាល់កំពង់ទឹក

៧- **បីតំ ជានាតិ** ដឹងថាគោបានផឹកទឹកហើយ

៨- **វីថឹ ជានាតិ** ស្គាល់ផ្លូវ

៩- **គោចរកុសលោ ហោតិ** ឈ្លាសក្នុងទីគោចរ

១០- **សាវសេសទោហី ច ហោតិ** រីតទឹកដោះឲ្យនៅសល់

១១- **យេ តេ ឧសភា គោបិតរោ គោបរិណាយកា តេ អតិរេកបូជាយ បូជេតា ហោតិ** គោឧសភទាំងឡាយណា ជាបិតារបស់គោ ជាបរិនាយករបស់គោ រមែងបូជានូវគោឧសភទាំងនោះ ដោយគ្រឿងបូជាដ៏ក្រៃលែង ។

អង្គ ១១ នៃគង្វាលគោនេះ យ៉ាងណា ភិក្ខុប្រកបព្រមដោយអង្គទាំង ១១ ទើបគួរដល់នូវសេចក្តីចម្រើន លូតលាស់ ពេញទូលាយ ក្នុងធម្មវិន័យនេះ ក៏យ៉ាងនោះដែរ ។ អង្គ ១១ របស់ភិក្ខុគឺ

១- ស្គាល់រូប គឺស្គាល់មហាភូតរូប ៤ និងឧបាទាយរូប ។ ការស្គាល់នេះ គឺស្គាល់ព្រោះបាននូវរូបកម្មដ្ឋាន រួចហើយបាននូវអរូបកម្មដ្ឋានទៀត ដោយអំណាចនៃវិបស្សនា រហូតដល់បានសម្រេចមគ្គផល ។

២- ឈ្លាសក្នុងលក្ខណៈ គឺដឹងលក្ខណៈនៃបុគ្គលពាល និងបណ្ឌិត ត្រង់ដែលមានកម្មជាលក្ខណៈ ។ លុះដឹងហើយក៏បានសេពគប់ជាមួយនឹងបណ្ឌិត បានជាអ្នកមានសីលល្អ មានទិដ្ឋិត្រង់សម្រេចនូវព្រះកម្មដ្ឋាន បានលុះមគ្គផល ។

៣- ឆ្កឹះពងរុយ គឺលះបង់នូវអកុសលវិតក្ក ។ លុះដល់លះបង់នូវអកុសលវិតក្កបានហើយ ក៏សម្រេចនូវព្រះកម្មដ្ឋាន បានជាក់-ច្បាស់នូវព្រះនិញ្វាន ។

៤- បិទដំបៅ គឺសង្រួមឥន្ទ្រិយទាំង៦ មានចក្ខុន្ទ្រិយជាដើម ។ លុះតែសង្រួមនូវឥន្ទ្រិយ ទើបអាចសម្រេចនូវព្រះកម្មដ្ឋានបាន ។

៥- បំពក់ភ្នក់ គឺសម្តែងធម៌ឲ្យអ្នកដទៃបានស្តាប់ ។ ភិក្ខុមានធម្មទាន គ្រហស្ថមានបច្ច័យ ៤ ជាអាមិសទាន ដែលនាំឲ្យចម្រើនព្រះសាសនា ភិក្ខុក៏បានគង់នៅប្រព្រឹត្តធម៌ សម្រេចមគ្គផល ។

៦- ស្គាល់កំពង់ទឹក គឺចូលទៅរកពហុស្សូត អ្នកទ្រទ្រង់ធម៌វិន័យ សាកសួរ ស្តាប់ រៀន ។ សេចក្តីសំខាន់ក្នុងចំណុចទី ៦ នេះ គឺអស់ការសង្ស័យហើយ ទើបបាននូវព្រះកម្មដ្ឋាន ។

៧- ដឹងថាបានផឹកទឹកហើយ គឺស្តាប់ធម៌ដោយគោរព រហូតដល់បាននូវបីតិបាមោជ្ជ ព្រោះបានយល់ដឹងអត្ថនៃធម៌ ហើយបាននូវកម្មដ្ឋានអប់រំចិត្ត ចម្រើនបញ្ញាសម្រេចមគ្គផល ។

៨- ស្គាល់ផ្លូវ គឺស្គាល់អរិយមគ្គ ប្រកបដោយអង្គ ៨ ប្រការ ។ ស្គាល់ផ្លូវទើបមិនវង្វេង ដើរតាមផ្លូវត្រង់ ទៅទីបំផុតទុក្ខ ។

៩- ឈ្លាសក្នុងទីគោចរ គឺឈ្លាសក្នុងសតិប្បដ្ឋាន ៤ ។

លោកុត្តរកុសលកើតបាន ព្រោះលោកិយកុសល ចេះដឹងក្នុងកាយ វេទនា ចិត្ត ធម៌ ។ សតិប្បដ្ឋាន ៤ គឺជាទីគោចររបស់ព្រះពុទ្ធជាបិតា ឯកាមគុណ ៥ ជាទីគោចររបស់មារ ។

១០- រីតទឹកដោះឲ្យនៅសល់ គឺស្គាល់ប្រមាណក្នុងការទទួលបច្ច័យ ។ ការស្គាល់ប្រមាណដូច្នេះ ធ្វើឲ្យគេងាយចិញ្ចឹម និងញុំាងសេចក្តីជ្រះថ្លាដល់អ្នកបវារណាថែមទៀតផង ជាហេតុនាំឲ្យបានប្រព្រឹត្តនូវព្រហ្មចរិយធម៌សម្រេចមគ្គផល ។

១១- បូជាបិតាសង្ឃ ដោយការបូជាដ៏ក្រៃលែង ។ ការបូជាបិតាសង្ឃដោយការប្រព្រឹត្តនូវមេត្តាកាយកម្ម មេត្តាវចីកម្ម និងមេត្តាមនោកម្ម ទាំងទីកំបាំងមុខ ទាំងទីចំពោះមុខ ។ ការបូជានេះនាំឲ្យបាននូវការសង្គ្រោះអំពីបិតាសង្ឃ ទាំងធម្មទាន ទាំងអាមិសទានដល់នវកភិក្ខុ សេចក្តីចម្រើនរមែងមានដោយការសង្គ្រោះអំពីបិតាសង្ឃនេះឯង ។

សូមអនុមោទនា !

# ពាក្យរំលឹក

សេចក្ដីសុខ មិនមែននៅត្រង់បានធ្វើជាអ្នកមាននោះទេ បុគ្គលណា បានស្វែងរកឃើញខ្លឹមសារពិតនៃជីវិត ហើយរស់នៅជាមួយនឹងខ្លឹមសារពិតនោះ ដោយសេចក្ដីស្រឡាញ់ បុគ្គលនោះឯងជាអ្នកមានសេចក្ដីសុខ មានទីពឹង ។

លោក ៦ មានលោកភ្នែកជាដើម គឺជាសាលារៀន អារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម គឺជាមេរៀន បរិញ្ញា ៣ គឺជាការរៀនចប់ចូលព្រះនិព្វាន ។

កាលណា ដែលបានឃើញលោកនេះ សុទ្ធតែជាមេរៀន គឺកាលនោះ មិនមានបញ្ហាសម្រាប់ជីវិតឡើយ ។ អ្វីៗទាំងអស់ក្នុងលោក ហាក់ដូចកំពុងតែសម្ដែងធម៌ប្រាប់យើង បញ្ញាគឺជាខ្លឹមសារដ៏សំខាន់ក្នុងជីវិត ។

មិនចាំបាច់ធ្វើខ្លួនដើម្បីឲ្យគេសរសើរថាល្អ ថាវិសេសអស្ចារ្យអ្វីទៅនោះឡើយ ព្រោះវាជារឿងញាប់ញ័រនៃចិត្ត ។ បើយើងគ្រាន់តែ

បាននូវសេចក្តីសុខស្ងប់ចិត្ត ក្នុងអ្វីដែលយើងធ្វើប្រចាំថ្ងៃនោះ គឺវាក្រៃលែងជាងការបាននូវពាក្យសរសើរពីអ្នកដទៃនោះទៅទៀត ទាំងលាភ យសអ្វីៗក៏ដោយគឺមិនមែនជាខ្លឹមសារនៃជីវិតទេ សេចក្តីស្ងប់ចិត្តតែម្យ៉ាងទើបជាខ្លឹម ជាជោគជ័យពិតប្រាកដនៃជីវិត ទាំងដែល ជាទីបញ្ចប់នៃសេចក្តីប្រាថ្នា សេចក្តីញាប់ញ័រក្នុងលោក ។

ការប្រៀបធៀបខ្លួននឹងអ្នកដទៃ គិតទៅក្នុងការបានលាភ បានយសជាដើម គឺដូចជាកំពុងតែរត់ប្រណាំងគ្នា ចិត្តរមែងញាប់ញ័រ ។ ចិត្តដែលបានអប់រំក្នុងធម៌របស់ព្រះអរិយៈ រមែងត្រេកអរក្នុងអារម្មណ៍របស់ខ្លួន មិនមានការប្រណាំងប្រជែងដោយការប្រៀបធៀបខ្លួននឹងអ្នកដទៃឡើយ ។

ធម្មតានៃចិត្តដែលមិនទាន់មានការអប់រំ រមែងត្រេកអរក្នុងអារម្មណ៍តាមអំណាចនៃរាគៈ គឺជាការសប្បាយរបស់សត្វលោកទូទៅ មនុស្ស ទេវតា ព្រមទាំងតិរច្ឆានផងដែរ ។ ចំណែកការអប់រំចិត្តឲ្យចេះត្រេកអរក្នុងអារម្មណ៍នៃព្រះកម្មដ្ឋាន ជាសេចក្តីត្រេកអរដែលប្រាសចាកតណ្ហា មានះ និងទិដ្ឋិ នេះជាសេចក្តីត្រេកអរសប្បាយរបស់ព្រះអរិយបុគ្គល សុខស្ងប់ត្រជាក់ក្នុងអារម្មណ៍ ភ្លឺស្វាងដូចពន្លឺ

ព្រះចន្ទក្នុងវេលារាត្រី ថ្ងៃពេញបូណ៌មី ។

អ្វីណាដែលចិត្តដឹង អ្វីនោះហៅថា អារម្មណ៍ ។ អារម្មណ៍គឺជាលោកនៃការរស់នៅ ឯការរស់នៅក្នុងលោកគឺ

-មិនត្រូវចិត្ត នាំឲ្យកើតទុក្ខ

-បើត្រូវចិត្ត នាំឲ្យសប្បាយ

-ចំណែកឧបេក្ខាញាណ បានស្ងប់ ។

ចំពោះកល្យាណបុថុជ្ជន ដែលមានវិបស្សនាដឹងនាមរូប ព្រមដោយបច្ច័យ គឺមានការធានាថា ក្រោយពីចុតិ មានតែបដិសន្ធិក្នុងសុគតិភពប៉ុណ្ណោះ ។ នាមរូបជាផលនៃបច្ច័យ ប្រៀបបីដូចជាស្រមោល ដែលមិនមានអ្វីគួរឲ្យរវល់ខ្វល់ជាមួយឡើយ តែបើមិនបានដឹងតាមពិតហើយ ទិដ្ឋិក៏ចាប់ប្រកាន់នាមរូបនោះថាជាតួខ្លួន ក៏មានការរវល់ខ្វល់ឯងៗ ដូចមនុស្សឆ្កួតដែលប្រកាន់ស្រមោលថាជាតួខ្លួនដូច្នោះឯង ។

ស្អប់គេ គឺស្អប់ខ្លួនឯងជាង ព្រោះសាងទុក្ខនិងសាងភាព

សៅហ្មងឲ្យខ្លួនឯង ។ ចិត្តយើងគួរតែមិនមែនជាធុងសំរាម ដូច្នេះចូរកុំប្រមូលគ្រឿងស្មោកគ្រោកដាក់ចូលមកក្នុងចិត្តរបស់ខ្លួន គួរតែទុកដាក់របស់ល្អៗ ដូចជាសទ្ធា សីលជាដើម ។

ជីវិតដែលមានតម្លៃ មិនមែនព្រោះត្រកូលខ្ពង់ខ្ពស់ ព្រោះទ្រព្យ ឬព្រោះមានអាយុវែងនោះទេ ។ ជីវិតមានតម្លៃដោយចំណេះដឹងនិងគុណធម៌ ។ សីលល្អ ទិដ្ឋិត្រង់ ធ្វើឲ្យជីវិតបរិសុទ្ធ ហើយជួយឲ្យអ្នកដទៃមានការចេះដឹង និងរស់នៅបានសុខស្ងប់ផង នេះជាជីវិតដ៏ឧត្តម ។

## ថ្វាយបង្គំគុណព្រះភគវា

អង្គព្រះភគវាជាសាស្តា មានព្រះករុណាប្រាជ្ញាមាំ
មិនមានមោហៈថ្នាក់ដឹកនាំ ទ្រង់តែងអត់ទ្រាំដឹកនាំសត្វ ។
ចេតោខីលៈបាក់បែកហើយ ឥតមានទុក្ខឡើយរហើយស្ងាត់
ទ្រង់បានឈ្នះមារជាសម្បត្តិ ឱកាសស្ងប់ស្ងាត់សោយវិមុត្តិ ។
ព្រះហឫទ័យស្មើស្មគ្រណែនាំ សីលខ្ពស់ឧត្តមសមបំផុត

ទ្រង់ជាសារថីវៃមោះមុត ប្រាជ្ញាបរិសុទ្ធផុតលោកា ។
លោកាមិសៈខ្ទាក់ចោលហើយ គ្មានមន្ទិលឡើយលះកាមា
ហឫទ័យស្រស់ស្រាយស្រង់លោកា ដាក់ដល់ត្រើយមហាព្រះនិព្វាន ។
ឥតមានសង្ស័យអ្វីបន្តិច បំពេញពុទ្ធកិច្ចកបពុទ្ធញ្ញាណ
បុគ្គលក្នុងលោកមកប្រៀបគ្មាន សត្វច្រើនកោដិលានមានទីពឹង ។
សមណធម៌ធំបន្ទុំស្រេច វដ្តៈត្រូវផ្តាច់ស្រេចត្រឹមហ្នឹង
ទ្រង់វិជ្ជាបីថ្លៃហួសថ្លឹង ទ្រង់ញាណទ្រង់ដឹងថ្លឹងមិនបាន ។
ទ្រង់ញ៉ាំងពន្លឺបំភ្លឺផ្លូវ ឲ្យសត្វដើរទៅត្រូវលំអាន
មាគ៌ាព្រះពុទ្ធបរិសុទ្ធដាន ដល់ទីក្សេមក្សាន្តបានសុខា ។
ទ្រង់ផ្តាច់មានះតេជះខ្លាំង ព្យាយាមទ្រង់តាំងដ៏ខ្លាំងក្លា
ទ្រង់កាត់នន្ទិអភិសង្ខារ ទ្រង់ជាសាស្តាប្រាជ្ញាល្អិត ។
ម្ភៃបួនសែនកោដិសមាបត្តិ និរោធស្ងប់ស្ងាត់បាត់ទាំងចិត្ត
ទ្រង់ញាណដ៏ជ្រៅគុណនៅស្ថិត ប្រាជ្ញាគ្រងចិត្តពិតពណ្ណរាយ ។
ហឫទ័យទ្រង់ស្ងប់រំងាប់ហើយ ពុំមានសោះឡើយចិត្តរាយមាយ
ចូលឈានសមាបត្តិនិព្វាននាយ ចិត្តខ្ញុំរីករាយថ្វាយបង្គំ ៕ ០៚

សាធុ ! សាធុ !

ដោយ **ប.ស.ទ.**

# ៤-ចូឡគោបាលសូត្រ

ព្រះមានព្រះភាគ ទ្រង់គង់នៅក្បែរឆ្នេរទន្លេគង្គា ជិតក្រុងឧក្កចេលា ក្នុងដែនវជ្ជី ។ ព្រះអង្គទ្រង់ត្រាស់សម្តែងអំពីរឿងធ្លាប់មានមកហើយថា គង្វាលគោជាអ្នកនៅក្នុងដែនមគធៈ ជាមនុស្សអប្បប្រាជ្ញា ល្ងង់ខ្លៅ មិនបានពិចារណានូវត្រើយខាងអាយ ទាំងមិនបានពិចារណានូវត្រើយខាងនាយ នៃទន្លេគង្គា ក៏នាំគោទាំងឡាយឲ្យឆ្លងទៅកាន់ត្រើយខាងជើង ក្នុងដែនវិទេហៈ ត្រង់ទីដែលមិនមែនជាកំពង់ ក្នុងសរទសម័យ នាខែជាខាងចុងនៃរដូវភ្លៀង ។ ម្នាលភិក្ខុទាំងឡាយ គ្រានោះឯង ពួកគោក៏ធ្វើនូវការវិលវល់ ក្នុងកណ្តាលខ្សែទឹកទន្លេគង្គា ហើយក៏ដល់នូវសេចក្តីវិនាសបាត់បង់ក្នុងទឹកទន្លេនោះឯង ។

ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយណានីមួយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី មិនឈ្លាសក្នុងលោកនេះ មិនឈ្លាសក្នុងលោកខាងមុខ មិនឈ្លាសក្នុងទីនៅនៃមារ មិនឈ្លាសក្នុងទីដែលមិនមែនជាទីនៅនៃមារ មិនឈ្លាសក្នុងទីនៅនៃមច្ចុ មិនឈ្លាសក្នុងទីដែលមិនមែន

ជាទីនៅនៃមច្ចុ ពួកជនណា សម្គាល់នូវពាក្យរបស់សមណព្រាហ្មណ៍ទាំងអម្បាលនោះ ថាជាពាក្យគួរស្តាប់ គួរជឿ សេចក្តីសម្គាល់របស់ជនទាំងនោះ នឹងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ អស់កាលជាអង្វែង ។

ពាក្យថា សមណព្រាហ្មណ៍ដែលមិនឈ្លាស បានដល់ពួកគ្រូមានបូរណកស្សបៈ មក្ខលិគោសាលជាដើម ។

ពាក្យថា លោកនេះក្តី លោកខាងមុខក្តី គឺខន្ធ ធាតុ អាយតនៈ ។

ពាក្យថា ទីនៅនៃមារក្តី ទីនៅនៃមច្ចុក្តី បានដល់តេភូមិកធម៌ ( កាមភូមិ រូបភូមិ និងអរូបភូមិ ) ។

ពាក្យថា ទីដែលមិនមែនជាទីនៅនៃមារក្តី ទីដែលមិនមែនជាទីនៅនៃមច្ចុក្តី គឺនវលោកុត្តរធម៌ ( មគ្គ៤ ផល៤ និព្វាន១ ) ។

ជាបន្ត ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងអំពីគង្វាលគោជាមនុស្សមានប្រាជ្ញា ជាអ្នកចម្លងគោពីដែនមគធៈទៅដែនវិទេហៈ ឲ្យគោហែលឆ្លងកាត់ទន្លេគង្គា យ៉ាងមានសុវត្ថិភាព ។

នៅខាងចុងនៃព្រះសូត្រ ព្រះពុទ្ធអង្គទ្រង់ត្រាស់សម្តែងបីព្រះគាថា ៖

**អយំ លោកោ បរលោកោ ជានតា សុប្បកាសិតោ**
**យញ្ច មារេន សម្បត្តំ អបត្តំ យញ្ច មច្ចុនា ។**

លោកនេះ និងលោកខាងមុខ តថាគតដឹងច្បាស់ បានប្រកាសហើយដោយប្រពៃចំពោះទីណា ដែលមច្ចុមារទៅដល់ និងទីណាដែលមច្ចុរាជទៅមិនដល់ ។

**សព្វំ លោកំ អភិញ្ញាយ សម្ពុទ្ធេន បជានតា**
**វិវដំ អមតទ្វារំ ខេមំ និព្វានបត្តិយា ។**

ព្រះសម្មាសម្ពុទ្ធ ទ្រង់ដឹងច្បាស់ បានត្រាស់ដឹងនូវលោកទាំងពួង ហើយបើកទ្វារព្រះនិព្វាន គឺអរិយមគ្គដើម្បីជាប្រយោជន៍ឲ្យសត្វលោកបានដល់នូវព្រះនិព្វានជាទីក្សេមក្សាន្ត ។

**ឆន្នំ បាបិមតោ សោតំ វិទ្ធស្តំ វិនឡីកតំ**
**បាមោជ្ជពហុលា ហោថ ខេមំ បត្ថេថ ភិក្ខវោតិ។**

( ការដែលបានដល់នូវព្រះនិព្វានគឺ ) បានលះកាត់នូវខ្សែរបស់មារមានចិត្តបាប ហើយធ្វើឲ្យប្រាសចាកនូវដើមបបុសគឺមានះ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរជាអ្នកច្រើនទៅដោយបាមោជ្ជ ហើយចូរប្រាថ្នានូវព្រះនិព្វានដ៏ជាទីក្សេមក្សាន្តចុះ ។

សូមអនុមោទនា !

# ពាក្យរំលឹក

សត្វលោក ខ្វល់នឹងជីវិតខ្លួនឯងគ្រប់តែជាតិកំណើត ឥឡូវបានកើតជួបព្រះសម្មាសម្ពុទ្ធតាមរយៈព្រះត្រៃបិដកហើយ នៅតែលើកយកបញ្ហាជីវិតមកខ្វល់ មករវល់ មកឲ្យជាប់ជំពាក់ ហាក់ដូចជាមិនធ្លាប់បានរស់នៅក្នុងលោកនេះអីចឹងឯង ឯចំណែកជាមួយនឹងព្រះសម្មាសម្ពុទ្ធវិញ ហាក់ដូចជាមិនសំខាន់អ្វីសម្រាប់ជីវិតរបស់ខ្លួនឡើយ ទាំងឱវាទរបស់ព្រះអង្គក៏មិនអើពើក្នុងការគោរពដែរ ចង់ស្រឡាញ់ ចង់ស្អប់អ្នកណាៗ ស្រេចតែចិត្តខ្លួនឯង មិនមានកោតក្រែងព្រះសទ្ធម្មអ្វីបន្តិចសោះឡើយ ។

មនុស្សយើង តែងតែមានការសោកសៅ ចំពោះការបាត់បង់នូវអ្វីជាទីហួងហែង ។ តាមពិត អ្វីដែលបាត់បង់នោះ វាជា **អតីតា ធម្មា** ដូចព្រះពុទ្ធអង្គទ្រង់ត្រាស់ក្នុងភទ្ទេករត្តសូត្រថា **យទតីតម្បហីនន្តំ** ប្រែថា អ្វីណាដែលជាអតីត អ្វីនោះបានលះបង់ទៅហើយ ។ ការព្រមលះបង់ គឺជាការត្រូវគ្នានឹង **អតីតា ធម្មា**

បើមិនព្រមលះបង់ទេ វាមានតែកើតទុក្ខកន្ទក់កន្ទេញតែប៉ុណ្ណោះ ព្រោះក្នុងលោកនេះ មិនមានអ្នកណា មកប្រឆាំងជាមួយនឹង **អនិច្ចា ធម្មា** នេះបានឡើយ ដូច្នេះ ការព្រមលះបង់គឺជាមធ្យោបាយ ដែលអាចលះបង់បាននូវគ្រប់បញ្ហាទាំងអស់ ។

សេចក្ដីទុក្ខផ្លូវចិត្ត វាទាក់ទងនឹងគំនិត ព្រោះដោយបរមត្ថ រឿងដែលនាំឲ្យកើតទុក្ខនោះ វាមិនមានទេ គឺមានត្រឹមតែចិត្តគិតប៉ុណ្ណោះ ដូច្នេះ សេចក្ដីទុក្ខផ្លូវចិត្តនោះ ត្រូវបានបញ្ចប់អស់ទៅភ្លាមដោយគ្រាន់តែដូរគំនិត មកគិតឲ្យបានត្រឹមត្រូវវិញប៉ុណ្ណឹងឯង ។

ព្រមចាញ់ដោយចិត្តគិតប្រកបដោយមេត្តា ដូចមាតាសុខចិត្តចាញ់កូនតូចរបស់ខ្លួន គឺប្រសើរជាងការចង់ឈ្នះដោយចិត្តចងពៀរ ដូចរឿងរ៉ាវរបស់ព្រះបាទអជាតសត្តុ និងរឿងរ៉ាវនាងយក្ខិនីចូលក្នុងមេគោកូនខ្ចីជាដើម ។

មួយថ្ងៃនៃជីវិតដែលបានមកដល់ គឺជារង្វាន់ដ៏សំខាន់សម្រាប់យើងធ្វើអ្វីដែលល្អ ជាប្រយោជន៍ក្នុងការដែលបានកើតមកជាមនុស្សជួបនឹងព្រះពុទ្ធសាសនា ។ អាយុគឺជាពរទី១ ដូច្នេះ នៅ

ពេលដែលយើងភ្ញាក់ពីដំណេកក្រោកឡើងមក គឺយើងបានទទួលនូវពរដ៏ប្រសើរហើយ មិនបាច់សូមអ្វីពីអ្វីទៀតទេ មានតែសូមពីខ្លួនឯងតែប៉ុណ្ណោះ ដោយការមិនបណ្តោយឲ្យជីវិត១ថ្ងៃនោះ កន្លងទៅឥតប្រយោជន៍ហ្នឹងឯង ។

មិនសំខាន់នៅត្រង់ផ្ទះធំ មានតម្លៃថ្លៃច្រើនទៅប៉ុនណានោះទេ សំខាន់នៅត្រង់ផ្ទះនោះមានសេចក្តីសុខដែរឬអត់ ឬមានតែតម្លៃថ្លៃ ដោយមិនមានសេចក្តីសុខឲ្យដល់ម្ចាស់ផ្ទះ ។

មិនថាមានអ្វីៗច្រើនទៅប៉ុនណានោះឡើយ បើមិនពេញចិត្តហើយ វាទៅជាអផ្សុក កើតទុក្ខទៅវិញ ដូចព្រះបាទមន្ធាតុអីចឹង ដូច្នេះសេចក្តីសុខរបស់សត្វលោកទូទៅ គឺនៅត្រង់ពេញចិត្ត ដែលគេតែងតែពោលថាសប្បាយ ឬសប្បាយណាស់ ។

ការពេញចិត្តមានពីរយ៉ាង ម្យ៉ាងពេញចិត្តទៅតាមទំនើងនៃរាគៈ ការពេញចិត្តបែបនេះ រមែងប្រព្រឹត្តទៅតាមទីគោចររបស់មារគេចមិនរួចពីការទាស់ចិត្ត និងការភ័យព្រួយទេ ។ ការពេញចិត្តម្យ៉ាង-ទៀត គឺពេញចិត្តក្នុងអារម្មណ៍ដែលគ្រប់គ្រងដោយសតិសម្បជញ្ញៈ

ការពេញចិត្តនេះប្រព្រឹត្តទៅក្នុងទីគោចររបស់ព្រះពុទ្ធជាបិតា ជាឆន្ទិទ្ធិបាទប្រកបដោយនេក្ខម្មសុខ ។

មិនចាំបាច់មានបានរបស់ក្នុងលោកនេះច្រើនឡើយ បើចិត្តមានសតិសម្បជញ្ញៈ ប្រព្រឹត្តទៅជាសុខក្នុងអារម្មណ៍របស់ខ្លួនឯង ហើយនោះ ទាំងអារម្មណ៍នៃសេចក្តីសុខនេះទៀតសោត ក៏រមែងមានគ្រប់វេលា ។

បើយើងមិនឲ្យអភ័យដល់គេទេ ក៏យើងកែរឿងអតីតមិនបានដែរ ទោះបីជាយើងឲ្យអភ័យ ក៏នៅតែកែរឿងដែលកន្លងទៅហើយមិនបានដូចគ្នា ប៉ុន្តែកែបានត្រង់ចំណុចសំខាន់គឺចិត្តរបស់យើង ។

បើយើងគិតថា កំហុសអ្នកដទៃ យើងមិនអាចឲ្យអភ័យបាន យើងត្រូវគិតឲ្យអភ័យខ្លួនឯង កុំធ្វើជាសត្រូវនឹងខ្លួនឯងឡើយ ។

បើយើងមានចិត្តស្ងប់ ព្រោះមានបញ្ញាទទួលដឹងការពិតមួយគ្រាៗហើយ យើងរមែងឃើញតម្លៃនៃសេចក្តីស្ងប់ចិត្តនេះប្រសើរជាងសម្បត្តិទ្រព្យក្នុងលោក ។

តើត្រូវការអ្វីទៀត បើចិត្តមិនកើតទុក្ខទៅហើយនោះ តាមពិត មកពីសេចក្តីប្រាថ្នាហ្នឹងឯង ដែលនាំឲ្យកើតទុក្ខរឿយៗ ។

ដោយសាមញ្ញលក្ខណៈរបស់ចិត្ត គឺចិត្តអត់ត្រូវការអ្វីទាំងអស់ពីអារម្មណ៍ មានតែការរលត់សូន្យទៅប៉ុណ្ណោះ ។

កាលបើបានដឹងថា ចិត្តទាំងពួងមានតែការកើតហើយរលត់ទៅវិញ អត់ត្រូវការអ្វីពីលោកនេះ ប្រៀបដូចជាពន្លឺថ្ងៃ ឬផ្លេកបន្ទោរ ដូច្នេះគឺរមែងមិនស្វែងរកផ្លូវដទៃ ក្រៅអំពីរលើកដឹងរឿយៗនូវលក្ខណៈពិតរបស់ចិត្ត ឬលក្ខណៈពិតនៃរូបធម៌ និងនាមធម៌តែប៉ុណ្ណោះ ព្រោះបានដឹងថា នេះជាផ្លូវនៃសេចក្តីស្ងប់ពិត ។

ចំណេះដឹងអ្វីក៏ដោយ ដែលនាំមកនូវបញ្ហាទុក្ខកង្វល់ ឲ្យដល់ខ្លួនឯង និងអ្នកដទៃ ចំណេះដឹងនេះ មិនហៅថាឆ្លាតទេ លុះត្រាតែចំណេះដឹងណា ដែលនាំឲ្យសុខចិត្ត ស្ងប់ មិនមានបញ្ហាទុក្ខកង្វល់ ដោយស្រទន់ ដោយស្អប់ ចំណេះដឹងនោះ ទើបហៅថាឆ្លាត ជាព្រះសទ្ធម្ម ។

ព្រះសម្មាសម្ពុទ្ធ ទូន្មានដូចម្ដេច ? គឺដាក់ចុះនូវរបស់ធ្ងន់ឥត ប្រយោជន៍ ។ ព្រះពុទ្ធសាសនា ដោះស្រាយបញ្ហា ស្ងប់និងភ្លឺស្វាង មិនមែនសាងបញ្ហាទុក្ខកង្វល់ឲ្យដល់ខ្លួនឯង និងអ្នកដទៃទេ ។

ត្រូវប្រយ័ត្នការសម្លឹងទោសអ្នកដទៃហើយ កើតទុក្ខខ្លួនឯង ហើយក៏ត្រូវប្រយ័ត្នការមិនសម្លឹងទោសអ្នកដទៃ ព្រោះអគតិ និងរួម បាបកម្មជាមួយគ្នាផងដែរ ។

បើយើងមានមេត្តាកាយកម្ម មេត្តាវចីកម្ម មេត្តាមនោកម្ម ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខ ទៅរកគេហើយ គេនៅទទួល មិនបាន គឺវាជាកិលេសរបស់គេដោយឡែក មិនមែនយើងជាអ្នក បៀតបៀនគេទេ ។

បើយើងកើតទុក្ខមិនសុខចិត្ត តើអ្នកណា កើតទុក្ខជំនួស យើង ហើយបើពេលនេះ យើងមិនសុខស្ងប់ទេ តើចាំដល់ពេលអស់ ព្រះពុទ្ធសាសនាទៅឬ ទើបយើងបានសេចក្ដីសុខស្ងប់នោះ ឬក៏ចាំ ឲ្យអ្នកណាមកសុខស្ងប់ជំនួសយើង ។

ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា គប្បីលះបង់នូវគ្រឿងជាប់ជំពាក់ក្នុងលោក ហើយសម្លឹងសេចក្ដីស្ងប់ ។

មនុស្សយើងបានជីវិតមួយថ្ងៃៗហើយ នៅកើតទុក្ខរឿងនេះរឿងនោះ ព្រោះមិនចេះប្រើប្រាស់របស់ដែលមានឲ្យជាប្រយោជន៍ រវល់តែចង់បានរបស់ដែលអត់ហ្នឹងឯង ។

យើងមិនសុខចិត្ត ត្រង់ដែលថា គេយករបស់យើង ចុះជីវិតនេះ ព្រមទាំងអ្វីៗដែលនៅមានទៀតនោះ អ្នកណាគេឲ្យយើង ការដែលចេះតែទទួល មិនចេះលែង ហៅថាប្រកាន់គឺឧបាទាន នាំឲ្យកើតទុក្ខ ។

បើមិនទទួលយកអ្វីជារបស់យើងទេ ដូច្នោះ យើងក៏មិនមានអ្វីត្រូវបាត់បង់ដែរ ។

តណ្ហាដូចជាចោរអឺចឹង ចាប់យករបស់ក្នុងលោកមកប្រកាន់ថា នោះជារបស់អញ លទ្ធផលគឺជាអ្នកទោស ជាប់គុកមច្ចុរាជ ។

ព្រះពុទ្ធអង្គទ្រង់ឆ្លងរួចហើយ   ព្រះអង្គទ្រង់ត្រាស់សម្តែងធម៌
ឲ្យសត្វលោកបានឆ្លងរួចផង   គឺឆ្លងស្ទឹងតណ្ហាហ្នឹងឯង ។

## ល្អមបានហើយ

គិតល្អល្អមគិតមានសិរី   ពោលពាក្យអ្វីៗល្អមប្រយោជន៍
ធ្វើការងារល្អមមិនអសោច   ទានល្អមយ៉ាងហោចត្រឹមញញឹម ។
មានទ្រព្យល្អមមានកបដោយធម៌   ដឹងល្អមត្រូវល្អស្រស់ប៉ប្រិម
ល្អល្អមខ្លួនឯងមានសង្ឃឹម   មិនបាច់តម្រឹមប្រៀបនឹងគេ ។
គិតពោលធ្វើទានមានដឹងល្អ   ល្អមប្រាំពីរខល្អមទំនេរ
ល្អមតាមការពិតគ្មានយើងគេ   គឺហេតុផលទេល្អមបានហើយ ។

ដោយ **ម.ស.ទ.**

# ៥-ចូឡសច្ចកសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាកូដាគារសាលា ជាព្រះ-មហាគន្ធកុដិ ក្នុងមហាវ័នជិតក្រុងវេសាលី ។

សម័យនោះឯង និគន្ថបុត្រឈ្មោះសច្ចកៈ នៅក្នុងក្រុង-វេសាលី ជាអ្នកពោលនូវតិរច្ឆានកថា អួតខ្លួនថាជាអ្នកប្រាជ្ញ គេថាខ្លាចបែកពោះព្រោះខ្លួនមានបញ្ញាច្រើន គេបានយកបន្ទះដែកមករុំព័ទ្ធពោះរបស់គេ ស្តែងដល់មហាជន ទាំងពួកមហាជនក៏សន្មតគេថា ជាអ្នកមានលទ្ធិល្អ ។ សច្ចកនិគន្ថបុត្រ មានបងស្រី ៤ នាក់បួសជាភិក្ខុនី ព្រោះអាស្រ័យព្រះសារីបុត្តឆ្លើយឆ្លងបញ្ហាទៅវិញទៅមក កាលដែលឆ្លើយបញ្ហាព្រះសារីបុត្តមិនរួច ក៏ចូលបួសក្នុងសម្នាក់ភិក្ខុនី ហើយសម្រេចព្រះអរហត្តអស់ទៅ ។ ឪពុកម្តាយរបស់ពួកគេជានិគ្រន្ថប្រុសស្រី មកជួបគ្នានៅក្រុងវេសាលីក៏បានគ្នាជាប្តីប្រពន្ធ មានកូន ៥ នាក់ ប្រុសពៅឈ្មោះសច្ចកៈនេះឯង ។ សច្ចកនិគន្ថបុត្រ តែងពោលវាចា នាកណ្តាលបរិស័ទ ក្នុងក្រុងវេសាលីយ៉ាងនេះថា បុគ្គលណាដែលអាត្មាអញលើកឡើងនូវទោសដោយសម្តី ហើយមិនកក្រើក មិន

រំភើប មិនញាប់ញ័រ ទាំងញើសក៏មិនហូរចេញអំពីក្លៀក របស់បុគ្គល ណា អាត្មាអញមិនឃើញនូវបុគ្គលនោះឡើយ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី ជាអ្នកមានពួក មានគណៈ ជាអាចារ្យនៃគណៈ ឬពុំនោះ-សោត បានប្តេជ្ញាខ្លួនថាជាព្រះអរហន្តសម្មាសម្ពុទ្ធក៏ដោយ ឯអាត្មា-អញ បើលើកឡើងនូវទោសដោយពាក្យសម្តី សូម្បីចំពោះទៅលើ បង្គោលដែលគ្មានចេតនាសោះ ក៏បង្គោលនោះ គប្បីកក្រើក រំភើប ញាប់ញ័រទៅហើយ ចាំបាច់ពោលថ្វី ដល់មនុស្សជាតិផងគ្នា ។

សច្ចកនិគន្ថបុត្រ មានបំណងនឹងលើកវាទៈចំពោះព្រះដ៏មាន-ព្រះភាគ មុននឹងទៅលើកវាទៈ ក៏បានជួបនឹងព្រះអស្សជិត្ថេរ ដែល លោកកំពុងនិមន្តបិណ្ឌបាតក្នុងក្រុងវេសាលី ហើយបានសាកសួរពី ពាក្យទូន្មានរបស់ព្រះដ៏មានព្រះភាគ ចំពោះសាវ័កទាំងឡាយ ថាតើ ពាក្យប្រៀនប្រដៅរបស់ព្រះសមណគោតម តែងប្រព្រឹត្តទៅដោយ ច្រើន ក្នុងពួកសាវ័កទាំងឡាយ មានចំណែកដូចម្តេច ។

ព្រះអស្សជិត្ថេរ បានលើកយកបញ្ចក្ខន្ធមិនទៀង ជាអនត្តា សង្ខារទាំងពួងមិនទៀង ធម៌ទាំងពួងជាអនត្តា មកបញ្ជាក់ថា ពាក្យ ប្រៀនប្រដៅរបស់ព្រះដ៏មានព្រះភាគ តែងប្រព្រឹត្តទៅដោយច្រើន ក្នុងពួកសាវ័ក យ៉ាងនេះឯង ។ ព្រះថេរៈមិនបានលើកយកបញ្ចក្ខន្ធ

ជាទុក្ខ ព្រោះចំណុចនេះ នាំឲ្យសច្ចកនិគន្ថបុត្រដេញដោលច្រើនដល់ទៅមគ្គផលក៏ជាទុក្ខ បួសដើម្បីបានមគ្គផល គឺដើម្បីបានទុក្ខ ដូច្នេះជាដើម ។

សច្ចកនិគន្ថបុត្រ ប្រកាន់យកតួខ្លួន ដើម្បីនឹងឆ្លើយឆ្លងជាមួយនឹងព្រះដ៏មានព្រះភាគ ហើយបានពោលទៅរកព្រះអស្សជិត្ថេរថា ធ្វើដូចម្តេចហ្ន៎ យើងនឹងទៅជួបព្រះសមណគោតមបានម្តង បានចរចាគ្នា ហើយបានដោះនូវសមណគោតម ឲ្យផុតអំពីទិដ្ឋិដ៏លាមកនោះចេញបាន ។

សេចក្តីនៃព្រះសូត្រតទៅ ពិតជាពីរោះអស្ចារ្យណាស់ ក្នុងការឆ្លើយឆ្លងដោះស្រាយបញ្ហាប្រកបដោយធម៌ ។ ពុទ្ធបរិស័ទ បានអានបានស្តាប់ហើយ ពិតជាមានសេចក្តីសុខ ចម្រើន សេចក្តីជ្រះថ្លាក្រៃលែងឡើង ក្នុងព្រះដ៏មានព្រះភាគបរមគ្រូនៃយើង បានចេះដឹងក្នុងសច្ចធម៌ថែមទៀត បានជ្រះថ្លាក្នុងព្រះសង្ឃដោយការថ្វាយបច្ច័យ៤ និងបានអប់រំសីលឲ្យបរិសុទ្ធ ស័ក្តិសមនឹងការដែលបានមកអង្គុយជិតព្រះរតនត្រ័យ ។

នៅខាងចុងនៃព្រះសូត្រ សច្ចកនិគន្ថបុត្រ បានអារាធនាព្រះដ៏មានព្រះភាគទទួលចង្ហាន់ ព្រមដោយភិក្ខុសង្ឃ ។

សូមអនុមោទនា !

# ពាក្យរំលឹក

ចង់ឲ្យខ្លួនឯងគ្រាន់បើ ខំអួតខ្លួន ព្រោះមកអំពីមិនដឹងថា នេះជាខន្ធសុទ្ធៗ ។

ការមិនដឹងថា នេះជាខន្ធ ៥ នាំឲ្យរវល់ខ្វល់សព្វបែបសព្វយ៉ាង ។

ការបានរបស់ជាទីពេញចិត្តម្ដងៗ មិនមែនជាឧបាយនាំឲ្យរួចផុតទុក្ខកង្វល់ទេ គ្រាន់តែមិនចេះគ្រប់ប៉ុណ្ណឹង យើងឃើញថាជាបញ្ហារវល់មិនចេះចប់ទៅហើយ ។

ការស្វែងរករបស់ជាទីពេញចិត្ត មកអំពីការពេញចិត្ត ការពេញចិត្តមកអំពីត្រូវការ ត្រូវការមកអំពីខ្វះខាត ឯភាពខ្វះខាតគឺតណ្ហា កើតមកអំពីការដែលមិនបានកំណត់ដឹងនូវជីវិតនេះហ្នឹងឯង ដូច្នេះដំណោះស្រាយ មិនមែននៅត្រង់ការស្វែងរករបស់ឲ្យជាទី

ពេញចិត្តនោះទេ ដំណោះស្រាយគឺត្រូវកំណត់ដឹងនូវជីវិតនេះ ជារូប ជានាម មានបច្ច័យទើបកើតឡើង ជាផលនៃបច្ច័យ អត់មានតួខ្លួនឯង ទេ ដូចថ្ងៃបណ្ដើរកូន ដូចស្រមោល អត់មានត្រូវការអ្វីពីលោកនេះ ឡើយ រលត់ទៅវិញ អត់មានឋិតនៅក្នុងទីណាទេ ។

អ្វីៗដែលកន្លងទៅ គឺបានបំពេញកិច្ចយ៉ាងត្រឹមត្រូវហើយ ទើបបានលះបង់ទៅ រលត់ទៅ ជាអតីតា ធម្មា ។

អតីតា ធម្មា នេះជាធម៌ត្រឹមត្រូវណាស់ ទើបព្រះអង្គទ្រង់ ត្រាស់ថា មិនគប្បីអាល័យអតីត ។

សុភមង្គលនៃជីវិតមួយអង្គៗ ម្នាក់ៗ គឺនៅត្រង់មានបញ្ញាបាន ស្វែងរកជួបនូវភាពត្រឹមត្រូវគ្រប់រឿងទាំងអស់ ព្រោះថា គ្រប់រឿង ទាំងអស់ សុទ្ធតែមានបរមត្ថធម៌ ប្រាកដនូវភាពត្រឹមត្រូវ តាមហេតុ តាមបច្ច័យ ។

រកឃើញការពិត ទើបមិនមានការខឹងស្អប់ និងមិនមានការ ចាប់យកដោយឧបាទាន ។

ទោះជាពេលដែលមិនសប្បាយចិត្តក៏ដោយ ក៏មិនត្រូវឲ្យកិលេសកាមបបួលទៅរកការសប្បាយចិត្តឥតប្រយោជន៍នោះដែរ គឺត្រូវរលឹកដឹងចិត្តដែលមិនសប្បាយនោះឯង វាជាសភាវៈពិតមួយដែរ មិនត្រូវស្អប់វាទេ ទោះជាចិត្តសប្បាយក៏មិនទៀង ឯចិត្តដែលមិនសប្បាយនេះក៏មិនមែនយើង ដូច្នេះមានតែការរលឹកសិក្សា ដឹងសភាវធម៌នោះៗតាមពិតទៅ ចិត្តរមែងស្ងប់ នេះទើបជាសេចក្តីសុខសម្រាប់ជាទីពឹងបានពិតប្រាកដ ។

ការខឹងក្រោធវាជាសំរាមក្នុងចិត្ត ទាំងដែលមានក្លិនស្អុយណាស់ផង ។ គ្រប់គ្នា មិនថាជាតិសាសន៍ណាៗ ចេះតែមានការខឹងក្រោធ ប៉ុន្តែហេតុអ្វីបានជាមិនខឹងក្រោធដូចគ្នា ជាមួយគ្នា គ្រប់រឿងទាំងអស់នោះទៅ ។ ព្រោះវាមិនមែនជារឿងរបស់យើង ដូច្នេះល្អណាស់ កាលណាដែលបានដឹងថា រឿងទាំងអស់ត្រឹមតែជាអារម្មណ៍នៃគំនិត កាលនោះ រមែងមិនមានការខឹងក្រោធឡើយ គឺជាការបោសសំរាមចេញពីក្នុងចិត្ត ។

# ដប់ប្រាំកុំ

កុំត្រចៀកស្រាល គឺកុំអាលជឿកុំតឿគំនិត
កុំស្រេចតែចិត្ត គឺត្រូវចេះគិតឲ្យសមប្រពៃ
កុំចេះតែថាឲ្យអ្នកដទៃ ត្រូវចេះលកលៃប្រដៅខ្លួនឯង ។
កុំទាស់នឹងការពិត គឺត្រូវសុខចិត្តដោយឥតចំបែង
កុំអួតពីខ្លួនឯង គឺត្រូវចេះក្រែងដល់អ្នកដទៃ
កុំបានលាភយសមិនចេះលកលៃ សង្គ្រោះប្រពៃតម្លៃជីវិត ។
កុំដោះស្រាយដោយសោកសៅ គឺដូចដំបៅត្រូវរកថ្នាំបិទ
កុំប្រមាទក្នុងជីវិត គឺអប់រំចិត្តឲ្យមានស្មារតី
កុំចាប់ប្រកាន់ជាមួយនឹងអ្វី ឧបាយជោគជ័យគឺលះតណ្ហា ។
កុំធ្វើអ្វីៗមិនចេះក្រែង គឺយកខ្លួនឯងជាឧបមា
កុំចងវេរានឹងអ្នកណា គឺកុំគិតថាឈ្នះគេដោយពៀរ
កុំងប់នឹងល្បែងកុំញៀនស្រាបៀរ កុំដើរសសៀរមាត់ជ្រោះសែនជ្រៅ។
កុំខឹងកុំស្អប់កុំចងគំនុំ គឺរឿងតូចធំចោលឲ្យអស់ទៅ
កុំជាប់នុយមារលោកនេះកុំនៅ គឺត្រូវចេញទៅកាន់ព្រះនិព្វាន
កុំភ្លេចចងក្បូនដែលជាព្រហ្មយាន ឆ្លងដល់និព្វានបរមសុខា ។

ដោយ **ម.ស.ទ.**

# ៦.មហាសច្ចកសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារសាលា ជាមហាគន្ធកុដិ នាមហាវ័នទៀបក្រុងវេសាលី ។

សម័យនោះ ព្រះដ៏មានព្រះភាគ ទ្រង់ប្រថាប់ឈរនៅមុខព្រះមហាគន្ធកុដិ បម្រុងនឹងយាងទៅបិណ្ឌបាត មួយអន្លើដោយព្រះភិក្ខុសង្ឃ ។ សច្ចកនិគន្ថបុត្រ មិនទាន់អស់ចិត្តក្នុងការលើកវាទៈដេញដោលបញ្ហា ដើម្បីយកឈ្នះព្រះដ៏មានព្រះភាគ គាត់គិតថាលើកមុន ចាញ់ព្រះគោតម ខ្មាសពួកស្តេចលិច្ឆវីណាស់ លើកនេះមកតែម្នាក់ឯង បើឈ្នះព្រះគោតមសឹមប្រកាសជ័យជម្នះតាមក្រោយ បើចាញ់ក៏មិនខ្មាសគេដែរ ។

ព្រះអានន្ទ បានអារាធនាព្រះដ៏មានព្រះភាគ យាងព្រះអង្គគង់ប្រថាប់អង្គុយដើម្បីសម្តែងព្រះធម៌ប្រោសសច្ចកនិគន្ថបុត្រ ដោយព្រះអានន្ទគិតថា ការបានគាល់ព្រះពុទ្ធអង្គ និងការបានស្តាប់ព្រះធម៌ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ អស់កាលជាអង្វែង ។

សច្ចកនិគន្ថបុត្រ បានលើកយកបញ្ហាអចេលក៍ មកពោលថា

ជាកាយភាវនា ប្រព្រឹត្តទៅជាទុក្ខ ជាទោស ព្រោះមិនបានខ្វាយខ្វល់ក្នុងការប្រកបរឿយៗនូវចិត្តភាវនា ហើយបានលើកយកបញ្ហារបស់ពុទ្ធសាវ័ក មកពោលថា តែងប្រកបរឿយៗនូវចិត្តភាវនា ប្រព្រឹត្តទៅជាទុក្ខ ជាទោស ព្រោះមិនបានអប់រំនូវកាយភាវនា ។ សច្ចកនិគន្ថ-បុត្រ សម្គាល់ឃើញការប្រព្រឹត្តរបស់ពួកអចេលក៍ ថាជាកាយភាវនា តែព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា កាយភាវនានេះ មិនប្រកបដោយធម៌ក្នុងអរិយវិន័យទេ ។ សច្ចកនិគន្ថបុត្រ សម្គាល់ឃើញការប្រព្រឹត្តរបស់ពួកភិក្ខុ ថាជាចិត្តភាវនា ប៉ុន្តែគាត់មិនដឹងចិត្តភាវនាតាមពិតនោះ យ៉ាងណាឡើយ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងអំពីបុថុជ្ជនមិនបានស្តាប់ធម៌ មិនមានការចេះដឹង នៅពេលសុខវេទនាកើតឡើង ក៏មានតម្រេកត្រេកអរខ្លាំងទៅក្នុងសេចក្តីសុខនោះ នេះឈ្មោះថាសុខវេទនាគ្របសង្កត់ចិត្ត ព្រោះមិនបានអប់រំកាយ គឺមិនមាននូវកាយភាវនាដែលអដ្ឋកថាអធិប្បាយកាយភាវនានេះ ថាជាវិបស្សនា ។ ព្រះពុទ្ធ-អង្គទ្រង់ត្រាស់បន្តថា បើសុខវេទនានោះ របស់បុគ្គលជាបុថុជ្ជននោះរលត់ទៅ ទុក្ខវេទនាក៏កើតឡើង ព្រោះការរលត់ទៅនៃសុខវេទនាបុគ្គលជាបុថុជ្ជននោះ លុះទុក្ខវេទនាពាល់ត្រូវហើយ តែងសៅសោកលំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេង ។

សេចក្ដីខាងក្រោយនេះ ឈ្មោះថា ទុក្ខវេទនាគ្របសង្កត់ចិត្ត ព្រោះមិនបានអប់រំចិត្ត គឺមិនមាននូវចិត្តភាវនាហ្នឹងឯង ដែលអដ្ឋកថាអធិប្បាយចិត្តភាវនានេះ ថាជាសមាធិផ្នែកសមថៈ ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្ដែងអំពីអរិយសាវ័ក ដែលសុខវេទនាកើតឡើងមិនគ្របសង្កត់ចិត្ត ព្រោះបានអប់រំកាយ លុះដល់ទុក្ខវេទនាកើតឡើងក៏មិនបានគ្របសង្កត់ចិត្តដែរ ព្រោះបានអប់រំចិត្ត ។

កាលដែលសច្ចកនិគន្ថបុត្រ ទូលសួរព្រះដ៏មានព្រះភាគអំពីសុខទុក្ខផ្ទាល់នៃព្រះអង្គ ទ្រង់ក៏បានសម្ដែងរៀបរាប់អំពីការប្រព្រឹត្តទុក្ករកិរិយារបស់ព្រះអង្គ រហូតដល់បានត្រាស់ដឹង ។ ព្រះពុទ្ធអង្គទ្រង់បញ្ជាក់អំពីទុក្ខវេទនា នៅពេលព្រះអង្គបំពេញទុក្ករកិរិយានោះ មិនបានគ្របសង្កត់ចិត្តព្រះអង្គឡើយ ហើយសុខវេទនានៅពេលដែលព្រះអង្គបានសម្រេចឈាន រហូតដល់បានសម្រេចនូវវិជ្ជាទាំងបី ក៏មិនបានគ្របសង្កត់ចិត្តព្រះអង្គដែរ ។

អដ្ឋកថា បញ្ជាក់អំពីបញ្ចវគ្គីយ៍ដែលរត់ចោលព្រះអង្គ ដោយធម្មនិយាម អធិប្បាយថាទៅតាមធម្មតា ដើម្បីឲ្យឱកាសដល់ព្រះពោធិសត្វបាននូវកាយវិវេក ក្នុងកាលដែលត្រូវបានសម្រេចនូវសម្មាសម្ពោធិញ្ញាណ ហើយក៏មិនទៅក្នុងទីដទៃណាផ្សេងឡើយ គឺ

ទៅកាន់ព្រៃជិតក្រុងពារាណសី ( ជាទីដែលព្រះពុទ្ធគ្រប់ព្រះអង្គទ្រង់ត្រាស់ព្រះធម្មចក្កប្បវត្តនសូត្រ ) ហ្នឹងឯង ។ កាលដែលបញ្ជវគ្គីយ៍ទៅហើយ ព្រះបរមពោធិសត្វបានកាយវិវេក រហូតកន្លះខែ ទ្រង់គង់ប្រថាប់អង្គុយលើអបរាជិតបល្ល័ង្ក នាគល់ព្រះពោធិព្រឹក្ស ( ពោធិ-មណ្ឌល ) បានត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ។

សច្ចកនិគន្ថបុត្រ គិតក្នុងចិត្តថា កាលដែលពួកមនុស្សទេវតាទូលសួរបញ្ហានេះ បញ្ហានោះចំពោះព្រះគោតម តើព្រះគោតមមានសេចក្តីក្រោធដែរទេ ។ ព្រះដ៏មានព្រះភាគទ្រង់ជ្រាបហើយ ទើបត្រាស់ថា អ្នកកុំគប្បីយល់ឃើញយ៉ាងនេះឡើយ តថាគតសម្តែងធម៌ដល់ជនទាំងឡាយដ៏ច្រើននោះ ដោយប្រពៃ ដើម្បីប្រយោជន៍ដល់ទីបំផុតត្រឹមការដឹងច្បាស់ ចាក់ធ្លុះប៉ុណ្ណោះ ។

សច្ចកនិគន្ថបុត្រ គិតថា ព្រះគោតមរវល់តែយាងទៅ សម្តែង-ធម៌ ញុំាងបរិស័ទឲ្យត្រេកអរ ចំណែកព្រះអង្គឯងមិនមាន ឯកគ្គតាចិត្តឡើយ ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់អំពីផលសមាបត្តិរបស់ព្រះអង្គ សូម្បីក្នុងពេលដែលបរិស័ទស្តាប់ធម៌ហើយថ្វាយសាធុការ សាធុ សាធុ ព្រះអង្គចេញពីផលសមាបត្តិហើយសម្តែងព្រះធម៌ជាបន្តទៀត ។ ព្រះតថាគត នៅដោយផលសមាបត្តិ ដែលជាសុញ្ញតៈបានរហូតអស់កាលជានិច្ច ក្នុងពេលដកដង្ហើមចូល ក្នុងពេលដកដង្ហើមចេញ ។

ផលសមាបត្តិរបស់ព្រះអង្គគឺអរហត្តផលដែលមាន ព្រះនិព្វានជាអារម្មណ៍ ។

សច្ចកនិគន្ថបុត្រ នៅពេលនោះ ដូចសុនខដែលបរិភោគបាយាសលាយដោយទឹកដោះឆ្អែតពេញពោះហើយ នៅឃើញលាមក ទោះជាបរិភោគលាមកនោះមិនបាន ក៏ចេញទៅមិនរួចដែរ នៅហិតក្លិនលាមកសិនទើបទៅ បើវាមិនបានហិតក្លិនលាមកនោះសិនទេ វាឈឺក្បាលវា យ៉ាងណា ព្រះបរមសាស្តា ទ្រង់សម្តែងធម៌ជាទីតាំងនៃសេចក្តីជ្រះថ្លា តាំងអំពីទ្រង់សាងព្រះផ្នួសរហូតដល់អស់អាសវក្កិលេស សច្ចកនិគន្ថបុត្រស្តាប់ហើយមិនមានសេចក្តីជ្រះថ្លាក្នុងព្រះបរមសាស្តាឡើយ ដូច្នេះបើគេមិនបានទូលសួរបញ្ហាអំពីព្រះអង្គផ្ទំថ្ងៃ ដើម្បីចាប់ទោសព្រះអង្គទេ គេក៏មិនអាចលាព្រះអង្គចេញទៅបានឡើយ យ៉ាងនោះឯង ។

សច្ចកនិគន្ថបុត្រ លើកឡើងអំពីការផ្ទំពេលថ្ងៃរបស់ព្រះអង្គនោះ ថាជាការវង្វេង ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អំពីការវង្វេង និងការមិនវង្វេង ដោយឡែកផ្សេង យ៉ាងពីរោះនៅក្នុងព្រះសូត្រ ។

ថីនមិទ្ធៈ ព្រះខីណាស្រពបានលះបង់ហើយដោយអរហត្តមគ្គ ។ ការក្រេវល់ក្រវាយកាយ ( កាយទរថោ ) រមែងមានក្នុងឧបាទិន្នករូប សូម្បីក្នុងអនុបាទិន្នករូប ដូចស្លឹកឈើខ្លះក្តោបតាំងពីពេល

ព្រលប់ ដល់ពេលព្រឹកក៏រីកឡើងវិញជាដើម ។ ឧបាទិន្នករូប ( រូបក្នុង មនុស្ស សត្វ ) មានការក្រវល់ក្រវាយ ចំណែកខ្សែភវង្គមានការ ប្រព្រឹត្តទៅតាមអំណាចនៃការក្រវល់ក្រវាយនៃរូបកាយនោះ នេះជា ការផ្ទំលក់របស់ព្រះអរហន្ត ។

នៅខាងចុងនៃព្រះសូត្រ សច្ចកនិគន្ថបុត្រក៏បានពោល សរសើរព្រះដ៏មានព្រះភាគផងដែរ ថាព្រះអង្គសមជាព្រះសម្មាសម្ពុទ្ធ មែនពិត ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែង ២ ព្រះសូត្រនេះ គឺ ចូឡសច្ចកសូត្រ និងមហាសច្ចកសូត្រ សច្ចកនិគន្ថបុត្រនៅមិនបាន សម្រេចមគ្គផល មិនបានបួស ទាំងដែលមិនបានដល់ព្រះត្រៃ- សរណគមន៍ផង ប៉ុន្តែព្រះអង្គទ្រង់ត្រាស់សម្តែងដើម្បីឧបនិស្ស័យទៅ អនាគត ។ ពិតណាស់ ព្រះអង្គទ្រង់ជ្រាបឧបនិស្ស័យរបស់សច្ចក- និគន្ថបុត្រ តទៅក្នុងជាងពីររយឆ្នាំ បន្ទាប់ពីព្រះអង្គទ្រង់បរិនិព្វាន ព្រះពុទ្ធសាសនាប្រតិស្ឋាននៅតម្ពបណ្ណិទ្វីប សច្ចកនិគន្ថបុត្រនេះ បានកើតនៅក្នុងទ្វីបនេះ ហើយបានបួសរៀនព្រះត្រ័យបិដក ចម្រើន វិបស្សនា សម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទា ជាព្រះមហា- ខីណាស្រព ព្រះនាម **ពុទ្ធរក្ខិត** ជាអ្នកមានបុណ្យ ព្រះរាជាទ្រង់បូជា មានពួកភិក្ខុយ៉ាងច្រើនជាបរិវារ នៅនាចេតិយបព៌តមហាវិហារ ។

ព្រះរាជាព្រះនាម **តិស្សមហារាជ** ទ្រង់រក្សាឧបោសថ គង់នៅព្រះដំណាក់របស់ព្រះអង្គនាចេតិយបព៌ត ស្តាប់ព្រះធម៌ទេសនាដែលព្រះពុទ្ធរក្ខិតត្ថេរសម្តែងរហូតបីយាមនៃរាត្រី ដោយមិនរវើរវាយបញ្ជូនចិត្តទៅក្នុងទីដទៃឡើយ សូម្បីតែមួយបទក៏មិនបាត់ ទាំងព្រះហឫទ័យគិតថា យើងជាម្ចាស់នៃតម្ពបណ្ណិទ្វីបនេះ ក៏ពុំបានកើតឡើងឡើយ ។ ព្រះរាជា ត្រាស់សួរព្រះថេរៈអំពីពុទ្ធគុណ ព្រះថេរៈសម្តែងអនន្តគុណរបស់ព្រះសម្មាសម្ពុទ្ធ ដែលមិនមានទីបំផុត ប្រៀបដូចអាកាស ។ ព្រះរាជាបូជាតម្ពបណ្ណិទ្វីបដល់ព្រះថេរៈ ព្រះថេរៈបានថ្វាយដល់ព្រះរាជាវិញ សូមឲ្យព្រះរាជាគ្រប់គ្រងប្រកបដោយធម៌តទៅទៀតចុះ ។

**សូមអនុមោទនា !**

# ពាក្យរំលឹក

អ្នកដែលមានសេចក្តីទុក្ខ និងអ្នកដែលមានសេចក្តីសុខ ខុសគ្នាត្រង់គំនិត ៖

ម្នាក់គិតទៅរកអ្វីៗដែលបាត់ទៅ ដោយសោកសៅ នឹកអាល័យ ប៉ុន្តែម្នាក់ទៀត មានសេចក្តីសុខជាមួយនឹងអ្វីៗដែលមាន ព្រោះគិតយល់ថា អ្វីៗដែលបាត់ទៅ កន្លងទៅនោះ វាត្រឹមត្រូវតាមសេចក្តីពិតនៃលោកនេះ ។

ម្នាក់កើតទុក្ខរកអ្នកដែលព្រាត់ទៅ ម្នាក់ទៀត សុខសប្បាយជាមួយនឹងអ្នកដែលនៅជុំវិញខ្លួន ធ្វើល្អរកគ្នា សន្សំបុណ្យ ។

ម្នាក់កើតទុក្ខព្រោះគេមិនស្រឡាញ់ខ្លួន ម្នាក់ទៀត មានសេចក្តីសុខគ្រប់គ្រាន់ព្រោះហេតុតែចេះស្រឡាញ់ខ្លួនឯង មានខ្លួនឯងជាទីពឹង មានបុណ្យជាមិត្តសម្លាញ់ដ៏ល្អ ។

ម្នាក់កើតទុក្ខព្រោះប្រាថ្នាអ្វីមិនបានដូចចិត្ត ម្នាក់ទៀតមានសេចក្តីសុខ ព្រោះបានដឹងថា អ្វីៗមិនមែនចេះតែបានតាមប្រាថ្នាទេ វាត្រឹមត្រូវតាមហេតុដែលមាន ។

ម្នាក់កើតទុក្ខព្រោះស្អប់គេ ម្នាក់ទៀត មានសេចក្តីសុខព្រោះ

ឲ្យអភ័យប្រកបដោយមេត្តាចិត្ត គិតឃើញថាគ្រប់គ្នាចង់បានសុខ ។

ម្នាក់កើតទុក្ខព្រោះហួងហែង ម្នាក់ទៀត មាននូវសេចក្តីសុខស្ងប់ ព្រោះចេះលះបង់ ។

ម្នាក់កើតទុក្ខព្រោះមានគេរិះគន់និន្ទា ម្នាក់ទៀត មានសេចក្តីសុខនឹងអំពើល្អរបស់ខ្លួន ។

ម្នាក់កើតទុក្ខនឹងគេធ្វើអាក្រក់ ម្នាក់ទៀត មានសេចក្តីសុខព្រោះគិតដឹងថា មិនមានអ្នកណាធ្វើកិលេសឲ្យខ្លួនឯងទេ ហើយកិលេសហ្នឹងឯងជាហេតុនៃអំពើអាក្រក់នោះ ។

ម្នាក់កើតទុក្ខក្តៅក្រហាយស្តាយក្រោយ ចំពោះបាបដែលខ្លួនបានធ្វើហើយ ម្នាក់ទៀត មានសេចក្តីសុខព្រោះបានឈប់ធ្វើបាប ឯបាបដែលបានធ្វើហើយ ព្រោះលោភៈ ទោសៈ មោហៈ ជាហេតុ ។

ម្នាក់កើតទុក្ខព្រោះប្រឆាំងនឹងការពិត ម្នាក់ទៀត មានសេចក្តី

សុខស្ងប់ ព្រោះព្រមតាមសេចក្តីពិតនៃសង្ខារធម៌ដែលប្រែប្រួល ។

ម្នាក់កើតទុក្ខ គិតដោះស្រាយជាមួយនឹងរឿងខាងក្រៅដោយកិលេសរបស់ខ្លួន មិនរួចផុតចាកទុក្ខឡើយ ម្នាក់ទៀត សិក្សាបានស្គាល់ទុក្ខ ដោះស្រាយទុក្ខក្នុងចិត្តរបស់ខ្លួនដោយបញ្ញា បានរួចផុតចាកទុក្ខ ។

គ្រប់យ៉ាង ប្រព្រឹត្តទៅតាមប្រក្រតីធម្មតា ចិត្តឯណោះទេ ដែលគិតថាយូរឬឆាប់ ដូចជាយប់យូរណាស់ សម្រាប់អ្នកដេកមិនលក់ព្រោះទន្ទឹងរង់ចាំជាដើម ឬថាមួយថ្ងៃៗលឿនណាស់ សម្រាប់អ្នករស់នៅសុខសប្បាយ ។ ម្យ៉ាងទៀត ផ្លូវដដែលសោះ គ្រាន់តែពេលទៅដូចយូរ ដល់វិលមកវិញ ដូចឆាប់ ។ នៅមានឧទាហរណ៍ផ្សេងៗទៀតដូចជាទ្រព្យរបស់ដដែលសោះ ស្មើៗមិនត្រេកអរអ្វីទេ ដល់ពេលបាត់ស្តាយ លុះដល់ពេលរកឃើញវិញត្រេកអរ , រើសបានមាសមួយដុំត្រេកអរណាស់ ដល់មានគេឆក់យកមាសមួយដុំនោះបាត់ទៅវិញ ក៏ស្រែកយំកើតទុក្ខ , ពេលធ្វើដំណើរហាលថ្ងៃ ថាថ្ងៃក្តៅអាក្រក់ណាស់ដល់ពេលហាលអុស ហាលអាវ ថាថ្ងៃក្តៅល្អ , ពេលស្រឡាញ់ថាគេស្អាត ពេលខឹងស្អប់ថាគេមិនស្អាត , ពេលសប្បាយចិត្តថាលោកនេះ

គួរឲ្យចង់រស់នៅ ពេលមិនសប្បាយចិត្តថាលោកនេះមិនគួរឲ្យចង់រស់នៅឡើយ , ពេលមិនទាន់ដឹងសច្ចធម៌ចង់ទៅផ្ចាញ់ផ្ចាលព្រះពុទ្ធអង្គ ដល់ពេលឃើញសច្ចធម៌ទើបជ្រាបអនន្តគុណនៃព្រះអង្គ។ល។ ដូច្នេះ ទើបត្រូវស្តាប់ព្រះធម៌ អប់រំចម្រើនបញ្ញា ដើម្បីគ្រប់គ្រងចិត្តកុំឲ្យលម្អៀងខុសពីការពិត ទើបបានជោគជ័យក្នុងដំណើរចេញចាកអំពីសេចក្តីទុក្ខ ។

កាលដែលមិនទាន់ដឹងការពិត ចិត្តបោកបញ្ឆោតយើងថា មានយើង មានគេ មានរបស់យើង មានរបស់គេ មានអ្នកឲ្យយើងស្រឡាញ់ មានអ្នកឲ្យយើងស្អប់ មានអ្វីៗក្នុងលោកឲ្យសប្បាយ ឲ្យកើតទុក្ខ ។ល។ គួរឲ្យរង្កៀសចំពោះការមិនដឹងនូវសច្ចធម៌នេះណាស់ ដូច្នេះត្រូវព្យាយាមអប់រំបញ្ញាឲ្យដឹងការពិតដែលជាសច្ចធម៌ ទើបចិត្តមិនអាចបោកបញ្ឆោតឲ្យយើងត្រេកអរ និងប្រកាន់ក្នុងបញ្ចក្ខន្ធតទៅទៀតបាន ។

ព្រោះយើងងងឹតភ្នែក ទើបគេបោកយើងអំពីរូបារម្មណ៍បាន គឺគេយកសំពត់កញ្ចាស់ខ្មៅកខ្វក់មកឲ្យយើងស្លៀកដណ្តប់ ដោយប្រាប់ថាសំពត់ថ្មីសល្អស្អាត លុះដល់បកភ្នែកភ្លឺឡើងវិញ ទើបដឹងថា

គេបោកប្រាស់យើង យ៉ាងណាមិញ អវិជ្ជាដូចស្បែកបាំងភ្នែកឲ្យងងឹត បញ្ចក្ខន្ធដូចសំពត់កញ្ចាស់ខ្មៅកខ្វក់ ព្រះនិព្វានដូចសំពត់ថ្មីសល្អស្អាត ចិត្តប្រកបដោយរាគៈហ្នឹងឯង ដែលបោកបញ្ឆោតឲ្យយើងត្រេកអរក្នុងបញ្ចក្ខន្ធ ទាល់តែបកស្បែកភ្នែកគឺអវិជ្ជាចេញ ទើបអាចស្គាល់បញ្ចក្ខន្ធ និងព្រះនិព្វានតាមពិត ហើយដឹងអ្នកបោកប្រាស់តាមពិតផងដែរ លុះដឹងអ្នកបោកប្រាស់តាមពិតហើយ ទើបឈប់ចាញ់បោក នឿយណាយនឹងបញ្ចក្ខន្ធ ត្រេកអរនឹងព្រះនិព្វាន រួចផុតចាកទុក្ខ។

## លាហើយលោកីយ៍

អ្វីៗមានស្រាប់សម្រាប់សិក្សា កុំឲ្យគិតថាសម្រាប់ហួងហែង
ត្រូវរៀនលះបង់ឲ្យសុខខ្លួនឯង ចេះតែហួងហែងសូន្យទទេសោះ ។
មិនព្រមលះបង់គឺចង់បានទុក្ខ រូបក្នុងហ្វេសប៊ុកឲ្យទុក្ខដល់ម្ល៉ោះ
មើលឃើញស្តាប់ឮគឺនាមរូបសោះ លោកធម៌ទាំងអស់របស់ក្នុងលោក ។
សុខស្ងប់មានពិតកើតទុក្ខធ្វើអ្វី លះបង់លោកីយ៍អស់ក្តីងុយងោក
លះកាត់ស្នេហាប្រុសស្រីក្នុងលោក កម្មដ្ឋានជារោគលាលោកឆ្ងាយហើយ។
ផ្លូវលោកុត្តរៈអរិយមគ្គ ផ្លូវមួយៗម្នាក់ស្ងប់ស្ងាត់រកត្រើយ
វិវេកផុតខ្វល់ត្រជាក់រហើយ មិនវិលវិញឡើយលាហើយលោកីយ៍៕

ដោយ **ម.ស.ទ.**

# ពេទ្យអត់ថ្នាំ

ធ្វើអ្វីពោលអ្វីប្រពៃគាប់ ជារតនៈទ្រព្យជាប់ហប្ញទ័យ
មិននាំបណ្តាលឲ្យមានភ័យ ដល់អ្នកដទៃអ្វីឡើយណា ។
មនុស្សនេះដូចផ្កាគេចូលចិត្ត ឬទឹកឃ្មុំពិតក្លិនបុប្ផា
គេចង់នែបនិត្យជិតកាយា ចង់ស្តាប់វាចាមធុរស ។
ធ្វើអ្វីពោលអ្វីគេភ័យខ្លាច មានឈ្មោះថាកាចពិសដូចពស់
គិតថាគេខ្លាចខ្លួនខ្ពង់ខ្ពស់ សប្បាយនឹងឈ្មោះថាមនុស្សហ៊ាន។
ប៉ុន្តែនៅត្រង់គេភ័យខ្លាច អំពើកោងកាចពោលបំពាន
តើគួរយល់ថាតម្លៃមាន ត្រង់គេមិនហ៊ានតបតឬ ។
មនុស្សថ្លៃនៅត្រង់គេត្រូវការ ពោលពាក្យខ្លឹមសារគេចង់ឮ
ពាក្យពិតដូចថ្នាំចាំអ្នកឈឺ អ្នកមានជំងឺត្រូវការពេទ្យ ។
មាត់ថ្លៃសម្តីមានប្រយោជន៍ ពាក្យថោកប៉ោចៗខ្វះសង្កេត
ពោលឲ្យគេសើចបានមួយភ្លែត ខកចិត្តស្រឡេតពេទ្យអត់ថ្នាំ ៕

ដោយ **ម.ស.វ.**

# ៧.ចូឡតណ្ហាសង្ខយសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅនាបុព្វារាម ក្នុងមិគារមាតុ-ប្រាសាទ ឋិតនៅខាងកើតនៃព្រះនគរសាវត្ថី ។ គ្រានោះ សក្កទេវរាជបានយាងមកទូលសួរបញ្ហាធម៌ចំពោះព្រះដ៏មានព្រះភាគ អំពីភិក្ខុជាអ្នកមានចិត្តបង្អោនទៅក្នុងព្រះនិព្វាន ដោយធម៌បដិបត្តិយ៉ាងណា សូមព្រះអង្គសម្តែងដោយសង្ខេប មានបាលីគួរសិក្សាដូចតទៅ

**កិត្តាវតា នុ ខោ ភន្តេ ភិក្ខុ សង្ខិត្តេន តណ្ហាសង្ខយ-វិមុត្តោ ហោតិ អច្ចន្តនិដ្ឋោ អច្ចន្តយោគក្ខេមី អច្ចន្ត-ព្រហ្មចារី អច្ចន្តបរិយោសានោ សេដ្ឋោ ទេវមនុស្សានន្តិ។**

មានសេចក្តីប្រែថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាអ្នកមានចិត្តបង្អោនទៅក្នុងព្រះនិព្វាន ជាទីក្ស័យទៅនៃតណ្ហា មានសេចក្តីសម្រេចតែម្យ៉ាង មានសេចក្តីក្សេមក្សាន្តចាកយោគៈតែម្យ៉ាង ជាអ្នកប្រព្រឹត្តដ៏ប្រសើរតែម្យ៉ាង មានទីបំផុតតែម្យ៉ាង ជាបុគ្គលប្រសើរជាងទេវតានិងមនុស្សទាំងឡាយ ដោយសង្ខេប តើធម៌បដិបត្តិមានប៉ុន្មាន ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា **ឥធ ទេវានមិន្ទ ភិក្ខុ-**

**នោ សុតំ ហោតិ សព្វេ ធម្មា នាលំ អភិនិវេសាយាតិ ។** បពិត្រ ទេវានមិន្ទៈ ភិក្ខុក្នុងសាសនានេះ បានស្តាប់ពាក្យថា បុគ្គលមិនគួរប្រកាន់នូវធម៌ទាំងពួងដោយអំណាចតណ្ហានិងទិដ្ឋិ ។

សម័យបច្ចុប្បន្ននេះ ពុទ្ធបរិស័ទគប្បីស្តាប់រឿយៗអំពីរូបធម៌នាមធម៌ ដែលជាធម៌មិនគួរប្រកាន់ ។ ហេតុដូចម្តេចបានជាមិនគួរប្រកាន់ ពីព្រោះប្រកាន់មិនបានដដែល ដូច្នេះកាលណាប្រកាន់មិនបានហើយ រមែងជាទុក្ខ ។ តើប្រកាន់មិនបានដូចម្តេច គឺប្រកាន់ថាទៀង វានៅតែមិនទៀង ប្រកាន់ថាជាសុខ វានៅតែជាទុក្ខ ប្រកាន់ថាជាអត្តាតួខ្លួន វានៅតែជាអនត្តា ដោយប្រការដូច្នេះឯង ។

ការស្តាប់ ការអាននូវព្រះធម៌ យល់ឡើងៗ អំពីរូបធម៌នាមធម៌ក្នុងជីវិត យោនិសោមនសិការពិចារណាធម៌ដែលកំពុងមាន កំពុងប្រាកដ ជាបច្ច័យនៃសតិថ្នាក់សតិប្បដ្ឋាន វិបស្សនាបានដឹង បានស្គាល់នូវរូបធម៌នាមធម៌ជាក់ស្តែង ដែលធម៌ទាំងនេះមានពិតៗ តែជាបរមត្ថធម៌សុទ្ធ មិនមែនសត្វបុគ្គលតួខ្លួនយើងគេណាឡើយ ។

ជាបន្ត បន្ទាប់ពីបានស្តាប់ហើយ ព្រះអង្គទ្រង់ត្រាស់វិបស្សនាកើតឡើង មកអំពីបានស្តាប់ធម៌ត្រង់ហ្នឹងឯង ។ ត្រង់ពាក្យថា **សោ សព្វំ ធម្មំ អភិជានាតិ** ដែលប្រែថា ភិក្ខុនោះ រមែងដឹងច្បាស់នូវធម៌ទាំងពួង នេះជាតួ **ញាតបរិញ្ញា** គឺវិបស្សនាដឹងនាមរូបព្រម

ដោយបច្ច័យ គឺជាការចាប់ផ្តើមឃើញបដិច្ចសមុប្បាទធម៌ ។ ត្រង់ពាក្យថា **សព្វំ ធម្មំ បរិជានាតិ** រមែងកំណត់ដឹងនូវធម៌ទាំងពួងនេះជាតួ **តីរណបរិញ្ញា** គឺវិបស្សនាដឹងនាមរូបដែលកើតរលត់តាមទ្វារទាំង ៦ មិនទៀង ជាទុក្ខ មិនមែនជាអត្តា ។

ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់អរូបកម្មដ្ឋាន បានដល់ការកំណត់វេទនា ដោយវិបស្សនាដ៏មានកម្លាំង រហូតដល់ **ន កិញ្ចិ លោកេ ឧបាទិយតិ** គឺមិនប្រកាន់អ្វីតិចតួចក្នុងលោកឡើយ ។

សូមអនុមោទនា !

## រឿងគួរសង្កេតក្នុងព្រះសូត្រនេះ

សក្កទេវរាជ សូមឲ្យព្រះដ៏មានព្រះភាគ ត្រាស់សម្តែងដោយសង្ខេប ព្រោះក្នុងកាលនោះ ព្រះឥន្ទបានរៀបចំការលេងកីឡាដ៏ធំមួយនៅឋានរបស់ព្រះអង្គ ។ មុននឹងលេងកីឡា សក្កទេវរាជ នឹកចង់ស្តាប់ធម៌អំពីព្រះដ៏មានព្រះភាគសិន ទើបព្រះអង្គទ្រង់លះចោលមហារាជទាំង៤អង្គ ព្រមទាំងពួកទេវតារាប់កោដិទុកក្នុងទីនោះ យាងមកតែមួយព្រះអង្គឯង ដោយប្រញាប់យាងត្រឡប់ទៅវិញហ្នឹងឯង ។

ព្រះមហាមោគ្គល្លាន និមន្តតាមព្រះឥន្ទទៅដល់ឋានតាវត្តិង្ស ដើម្បីសួរធម៌ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងហើយ ជាធម៌សំខាន់ណាស់ តើព្រះឥន្ទបានចាំទុកដែរឬទេ ។

តាមពិត ព្រះឥន្ទមិនគួរភ្លេចនូវព្រះពុទ្ធដីកា ដែលព្រះអង្គខំឆ្លៀតយាងទៅទូលសួរ ទាំងព្រះដ៏មានព្រះភាគក៏ទ្រង់បានប្រទានមកហើយ ដូច្នេះឡើយ ប៉ុន្តែដោយអារម្មណ៍នៃកាម និងអារម្មណ៍នៃការងារគ្របសង្កត់ ធ្វើឲ្យព្រះអង្គភ្លេច នឹកមិនឃើញ ហើយបែរជានិមន្តព្រះមហាថេរ ឲ្យទស្សនាវេជយន្តប្រាសាទរបស់ព្រះអង្គទៅវិញ ។

វេស្សវ័ណមហារាជ ជាទីជិតដិតស្និទ្ធស្នាលជាមួយនឹងព្រះឥន្ទជាងគេ បានជាក្នុងព្រះសូត្រពោលថា គ្រានោះ ព្រះឥន្ទ្រាធិរាជ និងវេស្សវ័ណមហារាជ ឲ្យព្រះមហាមោគ្គល្លានដ៏មានអាយុនិមន្តមុខហើយនាំចូលទៅរកវេជយន្តប្រាសាទ ។

គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ទេវតានេះជាបុគ្គលប្រមាទខ្លាំងមែន បើដូច្នោះគួរតែអាត្មាអញធ្វើទេវតានេះឲ្យសង្វេគ ។ ព្រះមហាថេរ បានញ៉ាំងវេជយន្តប្រាសាទឲ្យកម្រើកញាប់ញ័រ ដោយចុងមេជើងសង្កត់ទៅលើជញ្ជាំងនៃប្រាសាទ តាមសមគួរដល់ឫទ្ធិដែលព្រះមហាថេរចូលអាបោកសិណ

ធ្វើឲ្យប្រាសាទដូចជាបាត្រអណ្តែតលើទឹក ហើយត្រូវគេប៉ះឲ្យកម្រើក ដូច្នោះឯង ។

ព្រោះសេចក្តីសង្វេគ ធ្វើឲ្យព្រះឥន្ទរំងាប់នូវសេចក្តីស្រវឹងក្នុងអារម្មណ៍កាមគុណផង និងព្រោះសោមនស្សក្នុងគុណនៃព្រះមហា-មោគ្គល្លានផង ព្រះអង្គក៏បាននឹករលឹកឃើញព្រះពុទ្ធដីកា ទូលដល់ព្រះមហាថេរបានដោយសព្វគ្រប់ ។

ទេពអប្សរ ទូលសួរព្រះឥន្ទ្រាធិរាជថា បពិត្រព្រះអង្គទ្រង់និទ៌ុក្ខ អង្គនោះហើយឬ ជាព្រះដ៏មានព្រះភាគ ជាគ្រូរបស់ព្រះអង្គ ? បានសេចក្តីថា នាងទេពអប្សរទាំងនោះ មិនដែលបានស្គាល់ព្រះសម្មាសម្ពុទ្ធ មិនដែលបានស្គាល់ព្រះមហាមោគ្គល្លាន ។

សក្កទេវរាជឆ្លើយប្រាប់ថា អង្គនោះ មិនមែនជាព្រះដ៏មាន-ព្រះភាគ ជាគ្រូរបស់យើងទេ អង្គនោះ ជាព្រះមហាមោគ្គល្លានដ៏មាន-អាយុ ជាសព្រហ្មចារី ( ដោយអំណាចនៃមគ្គព្រហ្មចរិយៈ ជាសាវ័កនៃព្រះដ៏មានព្រះភាគ ) ជាមួយនឹងយើង ។

នៅក្នុងព្រះសូត្រនេះ មានការសម្តែង៣លើក អំពីធម៌បដិបត្តិដោយសង្ខេប ចំពោះភិក្ខុដែលមានចិត្តបង្អោនទៅកាន់ព្រះនិព្វានជាទីអស់ទៅនៃតណ្ហា គឺព្រះដ៏មានព្រះភាគសម្តែង២លើក ព្រះឥន្ទ

សម្តែង១លើក ដូច្នេះពុទ្ធបរិស័ទយើងគួរស្តាប់ឲ្យបានរឿយៗ អំពីនាមរូបក្នុងជីវិតរៀងៗព្រះអង្គ រៀងៗខ្លួន គ្រប់ពេលវេលា ស្តាប់ទាល់តែយល់បានជាបច្ច័យនៃសតិប្បដ្ឋានប្បដិបត្តិ ។

## ពាក្យរំលឹក

ពាក្យថា យញ្ញ ក្នុងព្រះពុទ្ធសាសនា គឺបានដល់ការលះបង់កិលេស តាំងពីកុសលថ្នាក់ទាន រហូតដល់ថ្នាក់អរិយមគ្គ ពោលគឺសម្លាប់កិលេសក្នុងខ្លួនឯង មិនមែនសម្លាប់សត្វដែលជាបាណាតិបាតនោះទេ ។

ពាក្យថា វេទ ក្នុងព្រះសាសនា គឺបានដល់មគ្គ៤ ។

ពាក្យថា សមណៈ ក្នុងព្រះពុទ្ធសាសនាគឺអ្នកស្ងប់រំងាប់នូវបាប ពោលគឺអស់បាបពីសន្តានដោយអរិយមគ្គ ។

ពាក្យថា ព្រាហ្មណ៍ ក្នុងព្រះពុទ្ធសាសនា គឺអ្នកមានបាបបានបណ្តេតចោលហើយ ។

# ទីគ្មានបញ្ហាគឺព្រះនិព្វាន

មិនអាចឲ្យពេលត្រឡប់វិញ តែទោះម្តេចមិញមិនគួរស្តាយ
សិក្សាបច្ចុប្បន្នធម៌ក្នុងកាយ មានការនឿយណាយនឹងលោកីយ៍ ។
មាសប្រាក់មិនអាចទិញជីវិត ដល់ពេលស្លាប់ពិតចូលក្នុងដី
បញ្ញាលះបង់នូវលោកីយ៍ មិនមានរឿងអ្វីឲ្យកើតទុក្ខ ។
ចិត្តមនុស្សលំបាកនឹងយល់ដឹង តែមិនបាច់ប្រឹងយកជាមុខ
ស្គាល់ចិត្តខ្លួនឯងល្មមបានសុខ អារម្មណ៍នាំស្អុកទុកចោលទៅ ។
ធ្វើត្រូវក៏នៅគេនិន្ទា នេះជាធម្មាដ៏ត្រឹមត្រូវ
គួរអប់រំចិត្តឲ្យចូលផ្លូវ ចាកលោកនេះទៅផុតលោកធម៌ ។
ព្រាត់ប្រាសមិនអាចហាមឃាត់បាន ត្រូវពឹងសន្តានសន្សំល្អ
សទ្ធាជាមិត្តសីលបវរ ទៅតាមគោចរព្រះបិតា ។
បញ្ហាទាំងអស់ដោះក្នុងចិត្ត កិលេសមែនពិតមូលបញ្ហា
ធ្វើបុណ្យលះបាបអស់ទុក្ខា ទីគ្មានបញ្ហាគឺនិព្វាន ៕

ដោយ **ប.ស.ទ.**

# ៨.មហាតណ្ហាសង្ខយសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅព្រះជេតពនមហាវិហារ ព្រះអង្គទ្រង់ប្រារព្ធភិក្ខុមួយអង្គនាមថាសាតិ ។ សាតិភិក្ខុ មាននូវសស្សតទិដ្ឋិ យល់ខុសថា វិញ្ញាណនេះរមែងស្ទុះទៅ អន្ទោលទៅមិនដាច់ មិនក្លាយទៅជាអ្វីដទៃឡើយ គឺអាត្មាអញបានដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងហើយ យ៉ាងនេះឯង ។

ព្រះអង្គត្រាស់សួរសាតិភិក្ខុថា វិញ្ញាណនោះ តើដូចម្តេច ?

សាតិភិក្ខុឆ្លើយថា សភាវៈណា ដែលនិយាយបាន អាចទទួលអារម្មណ៍បាន បុគ្គលរមែងសោយនូវវិបាកនៃកម្មទាំងឡាយល្អនិងអាក្រក់ ព្រោះសភាវៈនោះ សភាវៈនោះហៅថាវិញ្ញាណ ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមោឃបុរស អ្នកដឹងច្បាស់នូវធម៌យ៉ាងនេះដែលតថាគតសម្តែងហើយ ដល់បុគ្គលណា ម្នាលមោឃ-បុរស ក្រែងតថាគត បានសម្តែងហើយ ដោយអនេកបរិយាយថា វិញ្ញាណកើតឡើងព្រោះអាស្រ័យបច្ច័យ បើវៀរចាកបច្ច័យហើយ ការកើតឡើងនៃវិញ្ញាណក៏មិនមានដូច្នោះទេឬ ។ ម្នាលមោឃបុរស

ហេតុដូចម្តេចក៏បានជាអ្នក ពោលបង្កាច់តថាគត ដោយគំនិតដែលខ្លួនប្រកាន់ខុសវិញ អ្នកឈ្មោះថាគាស់រំលើងនូវខ្លួនឯងផង ឈ្មោះថាសោយនូវអកុសលដ៏ច្រើនផង ម្នាលមោឃបុរស ព្រោះថា គំនិតដែលប្រកាន់ខុសរបស់អ្នកនោះ នឹងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ដើម្បីសេចក្តីទុក្ខ អស់កាលយូរអង្វែង ។

សាតិភិក្ខុ ប្រាកដដោយទិដ្ឋិអាក្រក់របស់លោក ដោយមិនអាចលះបង់បាន ទោះបីព្រះដ៏មានព្រះភាគត្រាស់ហៅលោកថាមោឃបុរសហើយ លោកនៅគិតថា អាត្មានឹងសម្រេចមគ្គផល ដូច្នេះទើបព្រះអង្គទ្រង់ត្រាស់សួរភិក្ខុទាំងឡាយ អំពីសាតិភិក្ខុមិនបានធ្វើឲ្យកក់ក្តៅក្នុងធម្មវិន័យនេះ គឺមិនអាចបានសម្រេចមគ្គផលឡើយ ។ សាតិភិក្ខុ ពោលពាក្យមួលបង្កាច់ព្រះពុទ្ធដីកា គឺជាការប្រហារព្រះជិនចក្រ ជំទាស់នឹងវេសារជ្ជញ្ញាណ ពោលឲ្យអ្នកដទៃយល់ខុសតាម ជាការរារាំងផ្លូវព្រះអរិយៈ ប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ដើម្បីសេចក្តីទុក្ខដល់មហាជន គឺជាមហាចោរក្នុងព្រះពុទ្ធសាសនា ។

ជាបន្ត ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សួរ និងសម្តែងធម៌ចំពោះភិក្ខុទាំងឡាយ ដោយព្រះអង្គទ្រង់លះនូវសាតិភិក្ខុចេញ ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់សួរនិងសម្តែងជាបន្តបន្ទាប់គឺ

-វិញ្ញាណអាស្រ័យបច្ច័យទើបកើតឡើងតាមទ្វារទាំង ៦ ដូច

ភ្លើងអាស្រ័យនឹងវត្ថុណាៗ ទើបឆេះឡើង ក៏ហៅភ្លើងតាមវត្ថុនោះៗ។ ព្រះអង្គទ្រង់ត្រាស់សម្ដែងវិញ្ញាណ ៦ មានចក្ខុវិញ្ញាណជាដើម ប្រៀបទៅនឹងភ្លើង ៦មុខដែលឆេះឡើង មានភ្លើងអុសជាដើម ( ភ្លើងអុស ភ្លើងប៉ុយ ភ្លើងស្មៅ ភ្លើងអាចម៍គោ ភ្លើងអង្កាម ភ្លើងសំរាម ) ។

-ព្រោះអាស្រ័យបច្ច័យ ទើបវិញ្ញាណកើតឡើងដូច្នេះ បានជាមិនមានវិញ្ញាណណាដែលស្ទុះអន្ទោលទៅកើតក្នុងភពនោះៗឡើយ ប៉ុន្តែបដិសន្ធិវិញ្ញាណកើតមាន ព្រោះកម្មជាបច្ច័យ ។ កម្មមិនមែនជាបច្ច័យត្រឹមតែបដិសន្ធិវិញ្ញាណប៉ុណ្ណឹងទេ គឺជាបច្ច័យនៃកម្មជរូប និងវិបាកក្ខន្ធ ទាំងក្នុងបដិសន្ធិកាល និងបវត្តិកាល ទៀតផង ដូច្នេះហើយ ទើបព្រះអង្គទ្រង់ត្រាស់សួរអំពីការកើតឡើងនៃបញ្ចក្ខន្ធ តើអ្នកទាំងឡាយមានឃើញទេ ( **ភូតមិទំ ភិក្ខវេ បស្សថាតិ** ) ។

-**ភូតមិទំ** បានដល់ខន្ធបញ្ចកៈ ដែលកើតឡើង ព្រោះអាស្រ័យបច្ច័យ ព្រះអង្គទ្រង់ត្រាស់បច្ច័យដោយពាក្យថាអាហារ ( **តទាហារសម្ភវំ** ) ។

-**តទាហារសម្ភវន្តិ ភិក្ខវេ បស្សថាតិ** គឺព្រះដ៏មាន-ព្រះភាគត្រាស់សួរថា ពួកអ្នកទាំងឡាយមានឃើញយ៉ាងនេះទេថា កាលបច្ច័យមាន ខន្ធបញ្ចកៈរមែងកើតឡើងដូច្នេះ ?

**-តទាហារនិរោធា យំ ភូតំ តំ និរោធធម្មន្តិ ភិក្ខវេ បស្សថាតិ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយឃើញថា ខន្ធបញ្ចកៈនោះ មានការរលត់ជាធម្មតា ព្រោះការរលត់ទៅនៃអាហារនោះដែរឬទេ ? បទថា **តទាហារនិរោធា** បានដល់ ព្រោះការរលត់ទៅនៃបច្ច័យ ( **តទាហារនិរោធាតិ តស្ស បច្ចយស្ស និរោធា** ) ។

**-វិចិកិច្ឆា** រមែងមានក្នុងអារម្មណ៍ទាំង ៣ មុខនេះ គឺ **ភូតមិទំ ១ តទាហារសម្ភវំ ១ តទាហារនិរោធា ១** ។

**-យថាភូតំ សម្មប្បញ្ញាយ បស្សតោ** បុគ្គលឃើញច្បាស់ដោយបញ្ញាដ៏ប្រពៃតាមពិត ដោយវិបស្សនា រមែងលះវិចិកិច្ឆានោះបាន ។

**-ឥមញ្ចេ តុម្ហេ ភិក្ខវេ ទិដ្ឋឹ ឯវំ បរិសុទ្ធំ ឯវំ បរិយោទាតំ** ។ល។ ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមិនប្រកាន់ដោយអំណាចនៃតណ្ហានិងទិដ្ឋិ ចំពោះវិបស្សនាដ៏បរិសុទ្ធយ៉ាងនេះ ផូរផង់យ៉ាងនេះទេ អ្នកនឹងយល់ច្បាស់នូវធម៌ដែលមានឧបមាដូចជាក្បូន ។

បទថា **ទិដ្ឋឹ** បានដល់វិបស្សនាសម្មាទិដ្ឋិ ( **តត្ថ ទិដ្ឋិន្តិ វិបស្សនាសម្មាទិដ្ឋឹ** ) ។

បទថា **បរិសុទ្ធំ** គឺបរិសុទ្ធព្រោះឃើញសភាវធម៌ ( **សភាវ-ទស្សនេន បរិសុទ្ធំ** ) ។

បទថា **បរិយោទាតំ** គឺផូរផង់ព្រោះឃើញបច្ច័យ ( **បច្ចយ-ទស្សនេន បរិយោទាតំ** ) ។

បទថា **និត្ថរណត្ថាយ នោ គហណត្ថាយ** ដោយសេចក្តីថា ធម៌ដែលព្រះអង្គទ្រង់ត្រាស់សម្តែងមានឧបមាដូចជាក្បូន គឺដើម្បីប្រយោជន៍ក្នុងការរលាស់ចេញចាកឱឃៈ ៤ ពួកអ្នកគប្បីដឹងនូវធម៌នោះ មិនមែនដើម្បីប្រយោជន៍ដល់ការប្រកាន់ដោយអំណាចនៃ **និកន្តិ** គឺសេចក្តីប្រាថ្នា សេចក្តីត្រេកអរនោះឡើយ ។

-ព្រះអង្គទ្រង់សម្តែង **វដ្តកថា** ចាប់ផ្តើមដោយអាហារ ៤ យ៉ាង គឺព្រះអង្គទ្រង់សម្តែងបដិច្ចសមុប្បាទធម៌ និងបដិច្ចសមុប្បន្ន-ធម៌ ។

-ព្រះអង្គទ្រង់សម្តែង **វិវដ្តកថា** ចាប់ពី **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា** ជាដើម រហូតដល់ **កេវលស្ស ទុក្ខ-ក្ខន្ធស្ស និរោធោ ហោតិ** ។

បទថា **កេវលស្ស ទុក្ខក្ខន្ធស្ស** បានដល់ កងទុក្ខទាំងអស់ អធិប្បាយថា កងទុក្ខសុទ្ធៗ វៀរចាកសត្វ ( **សត្តវិរហិតស្សាតិ**

**អន្តោ** ) ។

បទថា **និរោធោ ហោតិ** បានដល់ការមិនកើតឡើង ( **និរោធោ ហោតីតិ អនុប្បាទោ ហោតិ** ) ។

**-អបិ នុ តុម្ហេ ភិក្ខវេ ឯវំ ជានន្តា ឯវំ បស្សន្តា បុព្វន្តំ វា** ។ល។ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ នឹងស្រាវជ្រាវនូវខន្ធ ធាតុ អាយតនៈទាំងឡាយក្នុងអតីតកាល ។ល។ គឺព្រះអង្គទ្រង់ត្រាស់សម្តែងអំពីការមិនប្រព្រឹត្តទៅដោយអំណាចនៃតណ្ហានិងទិដ្ឋិ ក្នុងខន្ធទាំងឡាយគ្រប់កាលទាំងបី ព្រោះភិក្ខុមាននូវវិបស្សនាមគ្គ។

**-សាធុ ភិក្ខវេ ឧបនីតា ខោ មេ តុម្ហេ ភិក្ខវេ ឥមិនា សន្ទិដ្ឋិកេន ធម្មេន** ។ល។ ម្នាលភិក្ខុទាំងឡាយ ពាក្យដែលអ្នកទាំងឡាយពោលនោះត្រូវល្អណាស់ហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយដែលតថាគតនាំចូលទៅកាន់ព្រះនិព្វានដោយធម៌ដែលគួរឃើញច្បាស់ខ្លួនឯង ។ល។ ព្រះអង្គទ្រង់ត្រាស់ **សាធុ ភិក្ខវេ** ត្រង់ដែលភិក្ខុទាំងឡាយមានការចេះដឹងដោយវិបស្សនាមគ្គហើយ ឆ្លើយតបសំណួររបស់ព្រះអង្គ គឺថា មិនចេះតែពោលតាមព្រះសាស្តា ហើយក៏មិនពោលពាក្យដទៃខុសពីព្រះសាស្តា មិនឧទ្ទិសខ្លួនចំពោះសាស្តាដទៃទៀត មិនប្រកាន់វត្តសមាទាន មង្គល

ភ្ជាក់ផ្អើលតាមលទ្ធិដទៃ គឺថា **សាមំ ញាតំ** ដឹងខ្លួនឯងដោយញាណ **សាមំ ទិដ្ឋំ** ឃើញខ្លួនឯងដោយបញ្ញាចក្ខុ **សាមំ វិទិតំ** ធ្វើឲ្យច្បាស់ប្រាកដដោយខ្លួនឯង តើអ្នកទាំងឡាយគប្បីនិយាយនូវអ្វីដែលអ្នកទាំងឡាយបានដឹង បានឃើញ បានច្បាស់ប្រាកដនោះដែរឬទេ ? **ឯវំ ភន្តេ** បពិត្រព្រះអង្គដ៏ចម្រើន ពួកយើងខ្ញុំព្រះអង្គនិយាយដែរ ។

-ព្រះអង្គទ្រង់សម្តែងវដ្តកថាម្តងទៀត ផ្តើមដោយកិរិយាចុះចាប់បដិសន្ធិ ការលេងក្នុងវ័យកុមារ និងការរីករាយភ្លើតភ្លើនក្នុងកាមគុណនៅពេលដែលធំពេញវ័យ ។ ព្រោះមិនដឹងវេទនាតាមពិត ក៏ប្រកាន់ថាខ្លួនអ្នកសោយអារម្មណ៍ តណ្ហាកើតមានព្រោះវេទនាជាបច្ច័យ ឧបាទានកើតមានព្រោះតណ្ហាជាបច្ច័យ ភពកើតមានព្រោះឧបាទានជាបច្ច័យ ។ល។

-ព្រះអង្គទ្រង់សម្តែងវិវដ្តកថា ម្តងទៀតដែរ ដោយផ្តើមពីការត្រាស់ដឹងឡើងនៃព្រះអរហន្តសម្មាសម្ពុទ្ធ ហើយប្រកាសសម្តែងព្រះធម៌ រហូតដល់កុលបុត្រមានសទ្ធាចូលកាន់ផ្នួស បដិបត្តិបង្អោនចិត្តទៅក្នុងព្រះនិព្វាន ជាទីក្ស័យនៃតណ្ហា បានសម្រេចនូវការរលត់ទុក្ខទាំងពួង ។

-ខាងចុងនៃព្រះសូត្រ ព្រះអង្គទ្រង់ត្រាស់ឲ្យភិក្ខុចាំទុកនូវធម៌

បដិបត្តិ ជាការបង្អោនចិត្តទៅរកការអស់តណ្ហា ដែលព្រះអង្គទ្រង់ត្រាស់ដោយសង្ខេបនេះ និងចាំទុកនូវសាតិភិក្ខុកេវដ្តបុត្តនេះ ថាជាអ្នកជាប់ក្នុងសំណាញ់ដ៏ចង្អៀតគឺមហាតណ្ហានេះ ដូច្នេះឯង ។

សូមអនុមោទនា !

# ពាក្យរំលឹក

យើងកើតទុក្ខព្រោះគេមិនស្រឡាញ់យើង គួរពិចារណាថា ការស្រឡាញ់គ្នា ដោយរាគៈជាអកុសល មិនអាចបានគ្នាជាទីពឹងទេ គ្រប់គ្នាមានជរា ព្យាធិ មរណៈ មានសេចក្តីសោក និងមានសេចក្តីសៅហ្មង ដូច្នេះគួរមានមេត្តាចិត្តដល់គ្នាវិញ នាំគ្នាពឹងកុសល រក្សាសីល ធ្វើទាន បានជាយានទៅរកសេចក្តីស្ងប់ ត្រូវចាំថា ជាកល្យាណមិត្តនឹងគ្នា ទើបអាចជួយគ្នាបាន ។

បើដឹងថាខ្លួនជាទីស្រឡាញ់របស់ខ្លួន ត្រូវតែថែរក្សាខ្លួន ឲ្យជាការរក្សាដ៏ល្អ កុំសន្សំរឿងអាក្រក់ដាក់ខ្លួន ត្រូវយល់ថាកិលេសក្នុងចិត្ត

ខ្លួនឯង ដែលប្រមូលរឿងមិនល្អដាក់ខ្លួន ធ្វើឲ្យខ្លួនឯងជាធុងសំរាម ។ ត្រូវចាំថា មានតែខ្លួនឯងម្នាក់ដែលស្រឡាញ់ខ្លួន ក៏អាចជាទីពឹងនៃខ្លួនឯងបានហើយ ប៉ុន្តែជាធម្មតា កាលណាបើយើងស្រឡាញ់ខ្លួន រក្សាខ្លួនបានត្រឹមត្រូវតាមធម៌របស់សប្បុរសហើយនោះ គឺមិនខ្វះអ្នកស្រឡាញ់យើងឡើយ ទាំងមនុស្សទាំងទេវតា ។

ត្រូវប្រយ័ត្នពាក្យសម្ដី ពេលខឹងក៏ត្រូវប្រយ័ត្នពេលស្រឡាញ់ក៏រឹតតែត្រូវប្រយ័ត្ន ប្រយ័ត្នខ្លួនទៅជាអ្នកបោកប្រាស់គេដោយសម្ដីផ្អែមៗ ស្ករអាចឲ្យអ្នកបរិភោគកើតរោគក៏បាន ដូច្នោះត្រូវសម្លឹងឲ្យឃើញប្រយោជន៍ជាមុនសឹមនិយាយ គឺប្រយោជន៍ដែលសម្រេចបានអំពីពាក្យពោលហ្នឹងឯង មិនថាប្រយោជន៍នោះកើតមានដល់អ្នកណាៗឡើយ សូម្បីតែអ្នកដែលស្អប់យើងក៏បាន ។

ជំងឺផ្លូវចិត្តម្យ៉ាងទៀត ព្រោះគិតថាគេមិនឲ្យតម្លៃយើង ខំប្រឹងទៅរករឿងគេ ដើម្បីទាមទារតម្លៃ រឹតតែថោកថែមទៀត ការព្យាបាលរោគមួយនេះ គឺត្រូវចេះគិតឲ្យតម្លៃខ្លួនដោយខ្លួនឯង គឺចំណេះដឹងនិងគុណធម៌ កត្តាពីរយ៉ាងនេះសំខាន់ណាស់ គឺជាអ្នកធ្វើខ្លួនយើងឲ្យបាន

ជាព្រះអរិយបុគ្គលទៀតផង ។ ដុំដីសោះ គេអាចប្រើបាច់ធ្វើឲ្យមាន តម្លៃ មនុស្សយើងសព្វថ្ងៃមានធម៌ មានវិន័យ មានព្រះពុទ្ធសាសនា សម្រាប់ឆ្លាក់ច្នៃជីវិត ដូច្នេះត្រូវតែព្យាយាម កូនព្រះពុទ្ធត្រូវតែឆ្លាត ។

ចំណុចគ្រោះថ្នាក់របស់សត្វលោក ដែលគួរឲ្យភ័យខ្លាចម្យ៉ាង គឺការមិនព្រមទទួលយកនូវសេចក្ដីពិតត្រង់ដែលថា សេចក្ដីស្រឡាញ់ គ្រាន់តែជាភ្ញៀវដែលមកហើយ ដល់ពេលត្រឡប់ទៅវិញតែប៉ុណ្ណោះ នៅមានចំណុចគ្រោះថ្នាក់ម្យ៉ាងទៀត ជាទូទៅសម្រាប់សត្វលោក គឺ នៅត្រង់សេចក្ដីសម្គាល់ថា អាត្មាអញជាអ្នកបាននូវអ្វីៗជាទីស្រឡាញ់ ពេញចិត្តក្នុងលោកនេះ វាជាគ្រោះថ្នាក់ដ៏អាថ៌កំបាំងណាស់ មិនងាយ សត្វលោកបានដឹងឡើយ គឺថាចំណុចដែលត្រូវសង្កេតនៅត្រង់ « អាត្មាអញនៅក្នុងលោកនេះ » ហ្នឹងឯង ។ សេចក្ដីត្រេកអរ ជាមួយនឹងរបស់ក្នុងលោក ធ្វើឲ្យសត្វលោកឃ្លាងពីផ្លូវសតិប្បដ្ឋាន ទាំងដែល សម្បត្តិរបស់ព្រះសម្មាសម្ពុទ្ធនៅមាន ក៏សត្វលោកនៅតែ ស្វែងរក សម្បត្តិរបស់មារដដែល ចំណុចដោះស្រាយគឺត្រូវស្វែងរក ខ្លួនឯង តើ អ្វីជាខ្លួនយើងពិតដោយបរមត្ថ ដែលជាអ្នកបានអ្វីៗក្នុង លោកនេះនោះ ។

មានពាក្យហោរទស្សន៍ទាយលេខទូរស័ព្ទ ថាលេខហ្នឹងអាក្រក់ បានហើយតែប្រែជាបាត់បង់ទៅវិញ ខិតខំឥតប្រយោជន៍ ។ ពាក្យនេះ ជាពាក្យត្រឹមត្រូវចំពោះសង្ខារធម៌ដែលមិនទៀង មានហើយរកមានមិនបាន ពាក្យថា ខិតខំឥតប្រយោជន៍ គឺខិតខំបម្រើតណ្ហាចិញ្ចឹមទុក្ខ ចំណែកលេខទូរស័ព្ទជាបញ្ញត្តិ មិនមែនកុសលធម៌ មិនមែនអកុសលធម៌ ហើយក៏មិនមែនជាអព្យាកតធម៌ដែរ ។ ដំណោះស្រាយចំពោះសង្ខារធម៌ដែលមិនទៀង ជាទុក្ខ ជាអនត្តា គឺកំណត់ដឹងសង្ខារធម៌តាមពិត បង្អោនចិត្តទៅកាន់ព្រះនិព្វាន អស់តណ្ហា ឈ្នះទុក្ខទាំងពួង ។ នៅមានការទាយមួយទៀតថា លេខហ្នឹងធម្មតា មានលាភ មានបង់ មិនបានទទួលផលអ្វីទេ ។ ជាធម្មតានៃលោកធម៌ ៨ គឺ មានលាភ អត់លាភ មានយស អត់យស សរសើរ និន្ទា សុខ ទុក្ខ ទាំងអស់នេះសុទ្ធតែមិនទៀង មិនមានអ្នកណាសប្បាយជាមួយនឹងអ្វីបានរហូតទេ ហើយក៏មិនមានអ្នកណាកើតទុក្ខរហូតដែរ ឯពាក្យថា មិនបានទទួលផលអ្វីឡើយ គឺវាបិតនៅក្នុងន័យដូចជាសត្វជ្រូកដែលខិតខំបរិភោគអាហារអ៊ីចឹង តើធំធាត់សាច់ឈាមបានប្រយោជន៍អ្វីដល់ខ្លួនឯងនោះ នេះជាលោកធម៌ មិនមែនលេខទូរស័ព្ទទេ ។ ឯដំណោះស្រាយ គឺសិក្សាលោកធម៌តាមពិត កំណត់ដឹងនាមរូបដោយបរិញ្ញាបី មិនញាប់ញ័រនឹងលោកធម៌ ជាមង្គលដ៏

ឧត្តម ។ មានលេខខ្លះទៀតថាធម្មតា ចិត្តច្របូកច្របល់ លំបាកសម្រេចចិត្ត ។ តាមពិត ចិត្តបែបនេះ មានតាំងពីមុនប្រើទូរស័ព្ទម្ល៉េះ ចិត្តច្របូកច្របល់ក៏ជាចិត្តមួយបែប អ្នកដែលមានលេខថាល្អណាស់ក៏មានចិត្តបែបនេះដែរ សូម្បីទេវតាក៏នៅតែមានចិត្តច្របូកច្របល់លំបាកសម្រេចចិត្ត ឲ្យតែនៅជាបុថុជ្ជន ព្រោះវាជាមោហមូលចិត្តវិចិកិច្ឆាសម្បយុត្ត មិនមានអធិមោក្ខៈជាតួឲ្យសម្រេចចិត្តឡើយ ម្យ៉ាង-ទៀត ទោះជាមានអធិមោក្ខៈឲ្យសម្រេចចិត្ត ក៏មិនទាន់ប្រាកដថាល្អ វាអាចសម្រេចចិត្តក្នុងលោភៈ ក្នុងទោសៈក៏បានដែរ ។ ដំណោះ-ស្រាយគឺចម្រើនសតិប្បដ្ឋានរលឹកដឹងចិត្តច្របូកច្របល់នោះ គ្រាន់តែជាចិត្តបរមត្ថមួយបែបប៉ុណ្ណោះ មិនមែនជាខ្លួនយើងឡើយ ហើយការសម្រេចចិត្តយ៉ាងណាៗនោះ នៅលើពេលវេលាសមគួរតាមហេតុ រឿងសំខាន់គឺសម្រេចចិត្តមិនធ្វើអំពើអាក្រក់ ។ មានលេខមួយទៀតនោះថាល្អ តែខ្វះទំនុកចិត្តលើខ្លួនឯង ។ វានៅលើសមត្ថភាពក្នុងការងារ រឿងសំខាន់ឲ្យតែមានទំនុកចិត្តចំពោះសេចក្តីល្អ ដែលខ្លួនឯងបានធ្វើ វាគ្មានអ្វីដែលសំខាន់សម្រាប់យើងជាងខ្លួនយើងជាមនុស្សល្អនោះទៀតទេ ប៉ុន្តែសូមកុំឲ្យគិតថា យើងល្អអស់ត្រឹមប៉ុណ្ណឹងហើយ ។

# កើតទុក្ខព្រោះគេមិនស្រឡាញ់

កើតទុក្ខព្រោះគេមិនស្រឡាញ់ មុខគួរឲ្យចាញ់សត្វបក្សា
ត្រឹមស្លាបមួយគូសាងគ្រួសារ ស្រឡាញ់អាត្មារក្សាកូន ។
មើលមេសុនខនិងមេឆ្មា អាឈ្មោលទៅណាដូចស្លាប់សូន្យ
ខ្លួនឯងបំបៅដោះច្រើនកូន ចិត្តមិនស្រពោនស្រពាប់ឡើយ ។
ពិតមែនមនុស្សយើងមិនមែនសត្វ តែបើមិនកាត់ចាញ់សត្វហើយ
កិលេសនាំទុក្ខមិនធូរស្បើយ គេស្អប់ខ្លួនហើយកុំស្អប់ថែម ។
គឺយើងត្រូវចេះស្រឡាញ់ខ្លួន តាំងចិត្តមាំមួនសម្ដីផ្អែម
ទានសីលភាវនាស្ដាប់ធម៌ថែម ព្រះធម៌ផ្អែមល្ហែមបានសុខា ។
ប៉ុន្តែខ្ញុំថាបន្តិចចុះ អស់លោកប្រុសៗមិនមែនឆ្មា
មិនមែនសុនខនោះឡើយណា ត្រូវចេះរក្សាប្រពន្ធកូន ។
ចំណែកស្រីវិញក៏សូមថា ត្រូវធ្វើមាតាធ្វើជីដូន
ចម្លងកូនចៅដូចជាក្បួន មានប្ដីមានកូនកុំភ្លេចខ្លួន ។
មិនថាក្មេងចាស់ប្រុសឬស្រី ចង់មានសិរីកុំចោលក្បួន
ច្បាប់ស្រីច្បាប់ប្រុសឲ្យថែខ្លួន បរមត្ថពោលផ្ទួនថែចិត្តហោង ៕

ដោយ **ប.ស.ទ.**

# ៩ មហាអស្សបុរសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគមមួយឈ្មោះ អស្សបុរនិគម ក្នុងដែនអង្គៈ ។ មនុស្សទាំងឡាយដែលនៅក្នុងនិគមនេះ ជាអ្នកមានសទ្ធាជ្រះថ្លា មានការរាប់អានថាព្រះពុទ្ធជារបស់យើង ព្រះធម៌ជារបស់យើង ព្រះសង្ឃជារបស់យើង គ្រាន់តែឃើញសាមណេរតូចដែលបួសក្នុងថ្ងៃហ្នឹង ក៏ធ្វើដូចជាមួយនឹងព្រះថេរៈដែលមានវស្សាមួយរយអីចឹង ។ មនុស្សទាំងនោះ យកចិត្តទុកដាក់ជាមួយនឹងព្រះសង្ឃដែលនិមន្តបិណ្ឌបាតណាស់ មិនត្រឹមតែប៉ុណ្ណោះ គេនាំគ្នានិយាយអំពីគុណរបស់ព្រះភិក្ខុសង្ឃរឿយៗ នៅកន្លែងធ្វើការក្តី មកអំពីធ្វើការវិញ ពេលល្ងាចបរិភោគអាហារហើយក្តី ចូលទៅកាន់បន្ទប់ដេកក្តី ព្រោះហេតុដូច្នោះ ទើបព្រះដ៏មានព្រះភាគទ្រង់ប្រកបព្រះភិក្ខុសង្ឃទុកក្នុងសេចក្តីគោរពចំពោះបិណ្ឌបាត ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកផងតែងស្គាល់ច្បាស់នូវអ្នកទាំងឡាយ ថាជាសមណៈៗដូច្នេះ ឯអ្នកទាំងឡាយ បើមានអ្នកផងសួរថា លោកទាំងឡាយជាអ្វី ក៏ចូរប្តេជ្ញាថា យើងទាំងឡាយជា

សមណៈ ម្នាលភិក្ខុទាំងឡាយ កាលបើអ្នកទាំងឡាយនោះ មាន ឈ្មោះយ៉ាងនេះ ប្តេជ្ញាយ៉ាងនេះហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយគួរសិក្សាយ៉ាងនេះថា ធម៌ទាំងឡាយណា ដែលធ្វើឲ្យជាសមណៈផង ធ្វើឲ្យជាព្រាហ្មណ៍ផង ពួកយើងនឹងសមាទានប្រព្រឹត្តធម៌ទាំងនោះ ឈ្មោះរបស់ពួកយើងនេះ ក៏នឹងពិតយ៉ាងនេះ ទាំងការប្តេជ្ញាក៏ប្រាកដយ៉ាងនេះ មួយវិញទៀត យើងទាំងឡាយ បរិភោគនូវចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ច័យភេសជ្ជបរិក្ខារ របស់ជនទាំងឡាយណា សក្ការៈទាំងឡាយនោះ ដែលជនទាំងនោះ បូជាដល់យើងទាំងឡាយ នឹងទៅជាសក្ការៈមានផលច្រើន មានអានិសង្សច្រើន ឯបព្វជ្ជារបស់ពួកយើងមិនមែនជាឥតអំពើទេ នឹងមានផលមានសេចក្តីចម្រើន ។

បទថា **យេ ធម្មា សមណករណា ច ព្រាហ្មណករ-ណា ច** ដោយសេចក្តីថា ធម៌ទាំងឡាយណា ដែលបុគ្គលសមាទានឲ្យបរិបូណ៌ហើយ រមែងធ្វើឲ្យជាសមណៈគឺជាអ្នកស្ងប់រំងាប់នូវបាបនិងធ្វើឲ្យជាព្រាហ្មណ៍គឺជាអ្នកមានបាបបណ្តេតចោលហើយ ដូច្នេះឯង ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សម្តែងធម៌ដែលសមណៈគួរធ្វើក្នុងសេចក្តីនេះថា ម្នាលភិក្ខុទាំងឡាយ កិច្ចរបស់សមណៈ ដែលសមណៈគប្បីធ្វើមានបីយ៉ាង គឺការសមាទានអធិសីលសិក្ខា ១ ការ

សមាទានអធិចិត្តសិក្ខា ១ ការសមាទានអធិបញ្ញាសិក្ខា ១ ។ ធម៌ទាំងបីយ៉ាងនេះ ជាធម៌ធ្វើឲ្យជាសមណៈ ប៉ុន្តែក្នុងព្រះសូត្រនេះ ព្រះដ៏-មានព្រះភាគ ទ្រង់ទេសនាពិស្តារហើយ ដោយអំណាចនៃហិរិឱត្តប្បៈជាដើម ។

សូមអនុមោទនា !

## សុខក្នុងចិត្តខ្លួនឯងមិនបាច់សន្សំរឿង

អ្នកណាស្រឡាញ់អ្នកណាស្អប់ ពោលទាស់ពោលគាប់ក៏ដោយចុះ
បើយើងចេះគិតដឹងត្រូវខុស លះបង់កំហុសខំធ្វើល្អ ។
នោះយើងនឹងបានចម្រើនចិត្ត មិនចាំបាច់គិតទាស់តបត
ចាក់ផ្លុះធម៌ពិតសុខបវរ រស់ក្នុងព្រះធម៌ស្ងប់ត្រជាក់ ។
ធម្មទានមានផលតម្កល់ចិត្ត សុខស្ងប់ជ្រៅល្អិតពិតពឹងមគ្គ
ជាយានចម្លងឆ្លងជាក់លាក់ មិនមានជំពាក់កាមលោកីយ៍ ។
ដូច្នេះយើងត្រូវចងចាំទុក មិនត្រូវស្មាញស្មុគរឿងអ្វីៗ
មួយគឺអត់ធន់ពីរឲ្យអភ័យ លះបង់ទីបីសុខស្ងប់ហោង ៕

ដោយ **ប.ស.ទ.**

# ១០-ចូឡអស្សបុរសូត្រ

ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅអស្សបុរនិគម ក្នុងដែនអង្គៈ។ ព្រះអង្គទ្រង់ត្រាស់អំពី **សមណសាមីចិប្បដិបទា** គឺបដិបទាដ៏សមគួរ មានការទំនុកបម្រុងដល់សមណៈទាំងឡាយ ។

បទថា **សមណមលានំ** ជាដើម ដោយសេចក្ដីថា ធម៌ទាំងឡាយនេះ កាលដែលកើតឡើងរមែងធ្វើឲ្យសមណៈទាំងឡាយមានមន្ទិល ដូចជាច្រែះចាប់ដែក ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ជាមន្ទិលរបស់សមណៈ គឺភាពជាសមណៈត្រូវវិនាសខូចខាតដោយការប្រទូស្តអំពីមន្ទិល ។ ព្រះអង្គទ្រង់ត្រាស់មន្ទិលក្នុងព្រះសូត្រនេះមាន ១២ យ៉ាងគឺ

១-អភិជ្ឈា លោភៈសម្លឹងដោយការជាប់ជំពាក់

២-ព្យាបាទ ទោសៈកម្ចាត់បង់ប្រយោជន៍

៣-កោធៈ ខឹងក្រោធ មួម៉ៅ

៤-ឧបនាហៈ ចងគំនុំ គុំស្អប់

៥-មក្ខៈ រមិលគុណ

៦-បឡាសៈ លើកខ្លួន វាយឫកស្មើ

៧-ឥស្សា ច្រណែន ប្រចណ្ឌ

៨-មច្ឆរិយៈ កំណាញ់

៩-សាឋេយ្យៈ អំនួតអួតអាង

១០-មាយា លាក់ពុត

១១-បាបិច្ឆា ប្រាថ្នាបាប

១២-មិច្ឆាទិដ្ឋិ យល់ខុសពីការពិត ។

ព្រះអង្គទ្រង់ត្រាស់អំពីបដិបទាដ៏សមគួររបស់សមណៈ ព្រោះប្រតិបត្តិលះបង់នូវមន្ទិលរបស់សមណៈ នូវទោសរបស់សមណៈ ។ល។ ដូច្នេះហើយ ទ្រង់សម្តែងអំពីព្រហ្មវិហារធម៌ មាន មេត្តាជាដើម រហូតដល់ការអស់អាសវក្កិលេស ។

សូមអនុមោទនា !

# ពាក្យរំលឹក

មនុស្សយើងចេះគិតគូរប្រាក់តិចច្រើនសម្រាប់ធ្វើបុណ្យ ប៉ុន្តែមិនសូវចេះគិតគូរពាក្យសម្ដីដែលត្រូវនិយាយ តាមពិតបុណ្យឬបាបធំៗណាស់នៅនឹងមាត់និយាយ ។

មុននឹងនិយាយត្រូវចេះគិតឲ្យមានប្រយោជន៍ ពាក្យត្រូវនិយាយសឹមនិយាយ មិនចាំបាច់ពោលគ្រប់ពាក្យដែលចង់និយាយទេ ។

មាត់មានគ្រប ដបមានឆ្នុក គឺអត់ធន់ចំពោះចំណង់ដែលចង់និយាយហ្នឹងឯង ។

និយាយពាក្យមានប្រយោជន៍ ទាំងដែលជាពាក្យត្រូវចិត្តអ្នកដទៃ នេះជាសម្ដីទឹកឃ្មុំ ( មធុភាណី ) ។

និយាយពាក្យពិតត្រឹមត្រូវ គោរពពាក្យសន្យា នេះជាសម្ដីផ្កាក្លិនក្រអូប ( បុប្ផភាណី ) ។

និយាយពាក្យមិនពិត វចីទុច្ចរិតផ្សេងៗ នេះជាសម្ដីលាមក ( គូថភាណី ) ។

ធ្លាប់និយាយឲ្យគេខ្លាច គ្រាន់តែហើបមាត់ចង់និយាយ គេភ័យស្រេចទៅហើយ ដូច្នេះ ត្រូវរៀននិយាយពាក្យមានប្រយោជន៍ ជាពាក្យពិត ទាំងដែលគេចូលចិត្តស្ដាប់ បានស្ដាប់ហើយមានសេចក្ដីសុខ ចម្រើនសតិបញ្ញា ។

មិនចាំបាច់រកនឹកពាក្យនិយាយឲ្យគេសើចនោះទេ និយាយឲ្យគេដឹងការពិតនៃជីវិតនេះវិញ ទើបជាពាក្យដែលគេគួរបូជា ។

និយាយលើកឡើងនូវបញ្ហា នាំឲ្យអ្នកស្ដាប់ខ្វាយខ្វល់ កើតទុក្ខ មិនមែនជាការសម្ដែងធម៌ទេ ។

និយាយដោះស្រាយគ្រប់បញ្ហាក្នុងជីវិត អ្នកស្តាប់កើតបញ្ញា បានស្ងប់ចិត្ត នេះជាការសម្តែងធម៌ ។

អ្វីណាដែលអស់ទៅហើយ ក៏អស់ទៅចុះ ទោះជាអស់ទៅបែបណាក៏ដោយ គឺអស់ដូចគ្នាទេ អ្វីដែលសំខាន់សម្រាប់យើងគឺអ្វីណាដែលនៅមាន ។ អ្នកមានបញ្ញារមែងចេះប្រើពេលវេលារបស់ខ្លួនជាមួយនឹងរបស់ដែលនៅមាន ឲ្យបានប្រយោជន៍ច្រើនជាទីបំផុត ដោយមិនរវល់តែគិតស្តាយនូវអ្វីដែលអស់ទៅនោះឡើយ ។

ពាក្យថាអស់ បាលីពោលថា « ខយៈ » នៅក្នុងពួកអនិច្ចំ គឺបានដល់អ្វីៗដែលកើតអំពីបច្ច័យហ្នឹងឯង ។

បើមិនមានតណ្ហាចាប់ប្រកាន់ថា នោះជារបស់យើងទេ សេចក្តីសោកស្តាយថា គេយករបស់យើង ក៏មិនមានដែរ ។

ដោយបរមត្ថសច្ច មិនមានយើង មិនមានអ្នកដទៃទេ គឺមានតែខន្ធ ខាងក្នុង ខាងក្រៅប៉ុណ្ណោះ ដែលកើតហើយ រមែងវិនាស

ទៅវិញ ។

ចង់បានស្រឡាញ់ ... ចម្រើនមេត្តា
ចង់បានបញ្ញា ... រក្សាសតិ
ចង់ឃើញការពិត ... កម្ចាត់ទិដ្ឋិ
បានដល់សន្តិព្រោះអស់ចំណង់ ។

មិនមានមេត្តា ... ខ្វះការស្រឡាញ់
វិវាទឈ្នះចាញ់ ... ព្រោះតែទិដ្ឋិ
បញ្ញាក្រខ្សត់ ... ព្រោះអត់សតិ
ឆ្ងាយពីសន្តិ ... ព្រោះមិនលះបង់ ។

គំនិតមនុស្សយើងសំខាន់ខ្លាំងណាស់ ជាតួរៀបចំជីវិតមកហើយ និងរៀបចំតទៅទៀតយ៉ាងណាៗ ដូច្នេះត្រូវប្រយ័ត្នគំនិតគិតខុសប្រកបដោយភាពល្ងង់ខ្លៅ ត្រូវសិក្សាព្រះពុទ្ធវចនៈឲ្យច្រើន និងអប់រំចិត្តស្ងប់ចម្រើនបញ្ញា សេចក្តីសុខប៉ុន្មានៗ គឺស្ថិតនៅលើគំនិតខ្លួនឯង ដែលនាំមកនូវសេចក្តីសុខស្ងប់ ។ ឧទាហរណ៍ដូចជា ការ

ចេះគិតឲ្យល្មមចិត្តក្នុងជីវិតខ្លួនឯង ដោយមិនចាំបាច់គិតប្រៀបធៀបជាមួយនឹងជីវិតរបស់អ្នកដទៃ ឲ្យកើតទុក្ខខ្លួនឯងឡើយ ។

មនុស្សយើងគួរតែចេះគិតថា បានប៉ុណ្ណឹងហើយ នៅខ្វះអ្វីទៀតសម្បត្តិក្នុងលោកនេះនោះ ទោះជាបានប៉ុន្មានក៏មិនគ្រប់សម្រាប់លោភៈដែរ ដូចភ្លើងមិនឆ្អែតដោយអុស ឬសមុទ្រមិនឆ្អែតដោយទឹកហូរចូលដូច្នោះឯង គួរតែរកភាពគ្រប់គ្រាន់ឲ្យខ្លួនឯងរស់នៅបានសុខទើបគប្បីនឹងខ្លួនឯងជាមនុស្ស ។

មនុស្សយើងមិនមែនល្ងង់ដល់ថ្នាក់ រត់ប្រណាំងជាមួយនឹងស្រមោលខ្លួនឯងដោយគិតថាប្រជែងជាមួយនឹងអ្នកដទៃនោះទេ ប៉ុន្តែត្រង់ដែលមនុស្សយើងប្រជែងលាភយសជាដើម ជាមួយនឹងអ្នកដទៃតាមពិតគឺជាការរត់ដេញតាមពួកកិលេសរបស់ខ្លួនឯង កិលេសនេះឯងហើយដែលធ្វើឲ្យគំនិតគិតថា មានយើងមានអ្នកដទៃ ។ បើយើងរត់ ស្រមោលក៏រត់ ដើរ ឈរ អង្គុយ ដេក ស្រមោលរមែងប្រព្រឹត្តទៅតាមរូបទាំងអស់ តែបើយើងចូលម្លប់នឹងបាត់ស្រមោល យ៉ាងណាកាយ វេទនា ចិត្ត ធម៌ ជាទីតាំងនៃសតិរលឹក សតិប្បដ្ឋានវិបស្សនា មគ្គញ្ញាណ ធ្វើឲ្យសត្វលោកឈប់រត់ដេញតាមកិលេស

ដូច្នោះឯង ។

ទុក្ខក្នុងចិត្តរបស់យើង វានឹងរលាយបាត់អស់ កាលបើយើងដូរការគិតរបស់យើង រឿងនេះ មិនមានការចុះទុនធំដុំអ្វីទេ ប៉ុន្តែយើងនឹងបានការរស់នៅប្រសើរឡើងៗ ដូច្នេះអ្នកប្រាថ្នាការរស់នៅឲ្យសប្បាយចិត្ត ត្រូវហ្វឹកហាត់អប់រំគំនិតតាមធម៌ព្រះសម្មាសម្ពុទ្ធ ។

## កិច្ចការសំខាន់គឺរក្សាចិត្ត

ទុក្ខក្នុងចិត្តកើតពីគំនិត មនុស្សយើងតែងគិតខ្វះស្មារតី
អាងមានទានសីលជាប្រក្រតី រោគចិត្តណាណើមិនដឹងខ្លួន ។
ធ្វើបុណ្យដើម្បីរក្សាចិត្ត ទិសដៅបុណ្យពិតចិត្តមាំមួន
មនុស្សយើងមានចិត្តត្រូវថែថួន មិនមែនរួចខ្លួនត្រឹមសីលទាន ។
ទុក្ខត្រូវរសាយឆ្ងាយពីចិត្ត ព្រោះដូរការគិតគំនិតមាន
គិតរកការពិតចិត្តមានញាណ សុខស្ងប់កើតមានបានសួស្តី ៕

ដោយ **ប.ស.ខ.**

ដឹងខ្លួនថាមានទុក្ខ ត្រូវប្រយ័ត្នចាញ់បោកតណ្ហានាំទៅរកសុខ ត្រូវកំណត់ដឹងទុក្ខឲ្យឃើញថា អ្វីជាតួទុក្ខ ដូច្នេះទើបមិនលុះក្នុងអំណាចនៃតណ្ហា ។

## កំណត់ដឹងទុក្ខទើបរួចពីទុក្ខ

ទុក្ខកៀងសត្វល្វង់ឲ្យលង់ភព ត្រេកអរជ្រប់ងប់ភពមរណា
កំណត់ដឹងទុក្ខទើបសម្មា មិនមែនអត្តាជាទុក្ខទេ ។
ចង់គេចពីទុក្ខដោយល្ងង់ខ្លៅ មិនអាចជួបផ្លូវសុខទំនេរ
តាមពិតទុក្ខនេះសូន្យទទេ អត់យើងអត់គេមានតែខន្ធ ។
អត់មានបញ្ញាប្រាថ្នាសុខ ប្រាកដជួបទុក្ខព្រោះប្រកាន់
សុខព្រោះលះបង់បញ្ចក្ខន្ធ លះក្តីប្រកាន់ដោយបញ្ញា ៕

ដោយ **ប.ស.ទ.**

# ការរស់នៅនៃតណ្ហាឈ្នះទុក្ខទាំងពួង

ទ្រព្យតិចទ្រព្យច្រើនកុំអាលថា    សុខទុក្ខយ៉ាងណានៅលើចិត្ត
ស្កប់ឬមិនស្កប់នេះទើបពិត    មានធម៌ក្នុងចិត្តពិតមិនប៉ោង ។
មិនអាចបានគ្រប់ក្នុងលោភៈ    ទ្រព្យមិនត្រជាក់ក្នុងក្ដីកោង
ក្រោធមិនរំងាប់ពៀរតាមតោង    មោហៈមេខ្លោងមិនខ្លាចបាប ។
មោហៈថយចុះព្រោះបញ្ញា    ក្រោធមិនខ្លាំងក្លាពៀរសូន្យសាប
សង្រួមក្នុងកាមកាត់ក្លិនឆ្អាប    បួសរៀរចាកបាបត្រៃសិក្ខា ។
មាតាបិតាឲ្យជីវិត    គ្រូអប់រំចិត្តឲ្យសិក្សា
ខ្លួនឯងលិខិតឲ្យអាត្មា    បានជាទេវតាឬជាប្រេត ។
សីលសមាធិនិងបញ្ញា    សមណព្រាហ្មណាបាបបណ្ដេត
បណ្ដេញតណ្ហាប្រាថ្នាឆ្អែត    ឃើញផលឃើញហេតុឈ្នះមោហា។
ឈ្នះចិត្តខ្លួនឯងដោយខន្តី    ឈ្នះអ្នកដទៃដោយមេត្តា
មើលឃើញគ្រប់យ៉ាងជាធម្មតា    អស់នូវតណ្ហាឈ្នះទុក្ខហោង ៕

ដោយ **ប.ស.ទ.**

ពាក្យសម្ដីដែលចេញពីមាត់ហើយ យើងមិនអាចប្រើកម្លាំងអ្វី ដំរីដប់ម្ភៃ ឬគ្រឿងចក្រ ដើម្បីអូសទាញឲ្យត្រឡប់មកវិញបានឡើយ ។ ដោយបរមត្ថ វចីវិញ្ញត្តិសទ្ទរូបកើតព្រោះមានចិត្តជាសមុដ្ឋាន ដោយវោហារគឺមនុស្សយើងជាអ្នកបង្កើត ជាអ្នកសាងឡើងបានដោយងាយៗ លើកលែងតែមនុស្សគ ឬឈឺមាត់ ។ បើយើងនិយាយអត់គិត អត់ពិចារណា និយាយតាមតែចិត្តចង់និយាយ វាអាចទម្លាយប្រយោជន៍អ្នកដទៃធំដុំណាស់ អ្នកខ្លះមានក្ដីសង្ឃឹមចំពោះតែរឿងហ្នឹងមួយគត់ ប៉ុន្តែត្រូវរលាយបាត់អស់ ត្រូវខកចិត្តព្រោះតែពាក្យសម្ដីរបស់យើងប៉ុន្មានម៉ាត់ ។ សូម្បីថាពាក្យសម្ដីមិនប្រទូសរ៉ាយអ្វីដល់រាងកាយ ប៉ុន្តែអាចប្រទូស្តដល់ចិត្តអ្នកដែលស្រឡាញ់យើង ឲ្យស្លាប់ទាំងរស់ ឬអាចឲ្យគេធ្វើអត្តឃាតក៏បាន អត់បាយអត់ទឹក ឬឈឺចាប់ក្នុងដើមទ្រូងក៏បានដែរ ។

ពាក្យសម្ដីធ្ងន់ស្រាលអ្វីយ៉ាងណាៗ វានៅលើអ្នកនិយាយ បើមនុស្សឆ្កួតតាមផ្លូវជេរយើង យើងគ្រាន់តែមើលមុខដឹងរឿងហើយ ក៏ដើរចេញទៅ ដោយមិនបានយកចិត្តទុកដាក់អ្វីឡើយ ប៉ុន្តែចំពោះមនុស្សដែលយើងស្រឡាញ់ គ្រាន់តែនិយាយប៉ុន្មានម៉ាត់ប៉ុណ្ណោះ អាចឲ្យយើងហូរទឹកភ្នែក ច្រើនថ្ងៃ ច្រើនខែ សឹងតែរកថ្ងៃត្រឡប់មកល្អ មកស្រួលនឹងគ្នាវិញមិនបានផង នេះជាបទពិសោធន៍នៃការ

រស់នៅជាមួយគ្នា ឲ្យយើងដឹងថា ពាក្យសម្តីវាសំខាន់ខ្លាំងណាស់ ត្រូវតែគិតមុននឹងនិយាយ ។

បើគិតពីកម្លាំងខ្យល់វិញ ខ្យល់មាត់ដែលយើងនិយាយនោះ វាបន្តិចបន្តួចទេ តែដល់អ្នកដទៃចាប់យកមកធ្វើទុកក្នុងចិត្ត វាក៏ក្លាយទៅជាខ្យល់ព្យុះ ខ្យល់កន្ត្រាក់ ញ័រញាក់ក្នុងចិត្ត ក្តុកក្តួលបេះដូង ក្នុងរយៈពេលវេលាទៅតាមរឿង ។

ដូច្នេះ នៅជិតគ្នាឲ្យប្រយ័ត្នពាក្យសម្តី ព្រោះសូម្បីក្រោយមកមានការខមាទោស ឲ្យអភ័យដល់គ្នាហើយក៏ដោយ ប៉ុន្តែការដែលត្រឡប់មករកល្អ ដឹងខ្លួនថាស្និទ្ធស្នាលចំពោះគ្នាដូចមុនទៀត វាជារឿងលំបាក អាចមិនបានជារៀងរហូតទៀតផង ។ ដូចរឿងភិក្ខុពីរអង្គជាសម្លាញ់នឹងគ្នា ដែលទេវតាបានញុះញង់បំបែកដើម្បីពិសោធមើលទីបំផុតក៏ត្រូវបែកគ្នា សូម្បីក្រោយមកដឹងរឿងពិតហើយ ខមាទោសឲ្យអភ័យដល់គ្នាហើយក៏ដោយ ក៏មិនអាចជាសម្លាញ់នឹងគ្នាតទៅទៀតបានដែរ ។

ចំពោះសេចក្តីទុក្ខក្នុងរឿងអ្វីមួយដែលកើតមាន ជាធម្មតាវាតែងតែរលាយអស់ទៅតាមពេលវេលា រហូតដល់រឿងខ្លះបានភ្លេចទៅហើយ ដូច្នេះអ្នកមានសេចក្តីទុក្ខទាំងឡាយ ត្រូវចេះអត់ធន់ រង់ចាំ

ពេលវេលារស់នៅដោយសេចក្តីសុខស្រួលសាថ្មី វាអាចរៀបចំដំណើរជីវិតបានប្រសើរជាងមុនទៀតផង នេះជារដូវកាលនៃជីវិត ដូចជាជីវិតនាងបដាចារជាដើម ។

ត្រូវចេះគិតថា អ្នកដែលមានទុក្ខរាប់លាននាក់ សូម្បីតែទេវតាក៏ចេះកើតទុក្ខដែរ ប៉ុន្តែជោគជ័យគឺនៅត្រង់ឥឡូវនេះយើងកំពុងតែមានជីវិតនៅរស់ យើងបាត់បង់ទីពឹងខាងក្រៅ ដែលធ្វើឲ្យយើងមានឱកាសរកទីពឹងខាងក្នុង គឺពឹងខ្លួនឯង ដែលជាទីពឹងដ៏អស្ចារ្យដែលយើងមិននឹកស្មានដល់ថា ខ្លួនយើងអាចធ្វើទីពឹងឲ្យខ្លួនឯងបានដូច្នេះសោះ ប៉ុន្តែត្រូវមានព្រះធម្មរតនៈជាសរណៈ ។

ពោលដោយបរមត្ថបញ្ចក្ខន្ធជាទុក្ខ តែបើពោលដោយវោហារយើងហ្នឹងហើយជាអ្នកកើតទុក្ខនោះ ព្រោះវាមានយើងឯណាផ្សេងពីបញ្ចក្ខន្ធទៀត ទាំងដែលបញ្ចក្ខន្ធក៏មិនបានទៅព្រះនិព្វានដែរ កើតឡើងហើយ តែងរលត់ទៅវិញ ប៉ុន្តែដំណើរនៃការរួចផុតចាកទុក្ខ គឺកំណត់ដឹងបញ្ចក្ខន្ធ លះសេចក្តីប្រកាន់ថាជាសត្វបុគ្គលតួខ្លួន មិនមានទុក្ខផ្លូវចិត្ត សង្សារទុក្ខក៏មិនមាន នេះជាទីបំផុតទុក្ខគឺព្រះនិព្វាន ។

ទុក្ខក្នុងអនាគតវដ្តសង្សារមិនមានទីបំផុតដែលត្រូវកើតព្រោះតណ្ហាណា កាលដែលតណ្ហានោះអស់ហើយ នេះឯងឈ្មោះថាទុក្ខនិរោធគឺព្រះនិព្វាន ( **និរោធោ ហោតីតិ អនុប្បាទោ ហោតិ** )។

## ភ្លៀងច្រើនប៉ុនណាគង់តែរាំង

ភ្លៀងច្រើនប៉ុនណាគង់តែរាំង ទុក្ខសែនក្លាខ្លាំងគង់រសាយ
ដូច្នេះអ្នកមានទុក្ខទាំងឡាយ នឹងបានសប្បាយពេលបាត់ទុក្ខ ។
ប៉ុន្តែបាត់ទុក្ខមានពីរយ៉ាង បាត់មួយមិនរាងអបាយមុខ
បាត់មួយរកផ្លូវឲ្យបានសុខ កុំឲ្យមានទុក្ខតទៅទៀត ៕

ដោយ **ប.ស.វ.**

## និព្វានបរមសុខលត់ទុក្ខា

ធ្វើខ្លួនឲ្យដូចខ្យល់អាកាស សត្វលោកច្រើនណាស់ដកដង្ហើម
ធ្វើអ្វីពោលអ្វីមេត្រីផ្ដើម ដូចទឹកសន្សើមស្រពដំណាំ ។
កុំឲ្យធ្វើខ្លួនដូចខ្យល់ព្យុះ ខ្យល់កន្ត្រាក់នោះឲ្យបាក់ស្រាំ
ពោលគឺបុគ្គលធ្វើបាបកម្ម សាងទុក្ខប្រចាំដល់អ្នកស្រុក ។
កុំឲ្យយកភ្លើងទៅលត់ភ្លើង ភ្លើងគេភ្លើងយើងគឺភ្លើងទុក្ខ
តែត្រូវយកទឹកជាប្រមុខ និព្វានបរមសុខលត់ទុក្ខា ៕

ដោយ **ប.ស.វ.**

# មិនចេះតែបានតាមចង់

ខ្លះចង់បញ្ឈប់ពេលវេលា ព្រោះសុខរមនាវេលាត្រេក
ខ្លះចង់ត្រឡប់ព្រោះនឹកពេក ខ្លះឃ្លានខ្លះស្រេកចង់បានឆាប់ ។
ចង់ទាំងអស់នេះជិះកឯង វេលាមិនក្រែងតាមប្រញាប់
មិនវិលត្រឡប់មិនចេះស្តាប់ ចង់បានស្រាប់ៗនាំសោកា ។
ឱកាសយើងល្អតែម្យ៉ាងគត់ គឺយើងឈប់រត់ឈប់ប្រហារ
រស់ក្នុងបច្ចុប្បន្នស្តាប់ទេស្នា បានបរិញ្ញាប្រហារបាប ៕

ដោយ **ប.ស.ធ.**

# អ្វីៗកាត់ក្តីរួចស្រេចហើយ

អ្វីៗកាត់ក្តីរួចស្រេចហើយ គ្មានអ្វីនៅឡើយឲ្យសង្ស័យ
ជីវិតរស់នៅប្រចាំថ្ងៃ បានសុខអាស្រ័យដោយបញ្ញា ។
មានទ្រព្យច្រើនហើយនៅឡើយទុក្ខ មានរឿងច្រើនមុខនាំទុក្ខា
ព្រោះហេតុហួងហែងរឿងនោះណា គួរតែសិក្សាត្រង់ចិត្តគិត ។
បើគ្មានចិត្តគិតទុក្ខក៏គ្មាន ក៏ហាមមិនបាននូវគំនិត
តែត្រូវសិក្សារកការពិត និព្វានជ្រៅល្អិតពិតជាត្រើយ ។
ជ្រួតជ្រាបការពិតចិត្តបានស្ងប់ រឿងរ៉ាវគ្រប់សព្វចប់ស្រេចហើយ
មិនមានអ្វីកើតអត់ហេតុឡើយ នេះហើយសាក្សីនៃក្តីពិត ។

កើតទុក្ខមិនសុខឡើងតវ៉ា តណ្ហាប្រឆាំងច្បាំងក្នុងចិត្ត
ទាមទារសូមឲ្យមានការពិត មោហៈក្នុងចិត្តបិទសច្ចៈ ។
កាត់ក្តីអ្វីកើតត្រូវតែអស់ តែមិនព្រមសោះចង់ទុកដាក់
សច្ចៈម្ល៉ឹងហើយនៅថ្នាំងថ្នាក់ ត្រូវជាប់ច្រវាក់អន្ទាក់មារ ។
អរិយសច្ចមានហេតុផល ដឹងហើយអស់ខ្វល់អស់ទាមទារ
អស់នូវតណ្ហានិរោធា មគ្គភាវនាអស់ទុក្ខហោង ។

## ទេរព្រះមហាគន្ធកុដិនៅបាត់ដំបង

ឱព្រះសាស្តាអស្ចារ្យអ្វីម្ល៉េះ រុងរឿងវិសេសវិសាលលោកា
ក្នុងលោកគ្មានពីរប្រៀបដូចសុរិយា ពួកមនុស្សទេវតាជ្រះថ្លាបូជា ។
ទ្រង់ឫទ្ធិទ្រង់ញាណប្រទានទេស្នា បំភ្លឺលោកាទេវតាព្រហ្មា
ប្រកាសសច្ចៈចរណវិជ្ជា អង្គព្រះភគវាជាព្រះសាស្តា ។
បុញ្ញមាកង្ខមានេន ប្រាថ្នាបុណ្យជាក់ដោយចិត្តជ្រះថ្លា
ទេយ្យំ ហោតិ វិជានតា យល់ដឹងច្បាស់ការសច្ចាធ្វើទាន ។
ព្រះមហាគន្ធកុដិដុតមច្ឆរិយៈ ស្រឡាញ់ជឿជាក់តេជះទ្រង់ញាណ
បូជាពុទ្ធគុណបុណ្យទៅនិព្វាន មាសប្រាក់រាប់លានទានជាសារៈ។
ទទតោ បុញ្ញំ បវឌ្ឍតិ បុញ្ញរាសិ រាសីឡើងស័ក្តិ
ចម្រើនដល់អ្នកជឿជាក់ស្មោះស្ម័គ្រ ថ្វាយទានដល់អ្នកអាសវៈមិនមាន ។
ឥមំ មហាគន្ធកុដឹ ត្រិះរិះរំពឹងថ្វាយព្រះទ្រង់ញាណ

កសាងបួនឆ្នាំប្រាក់ចាំតែមាន　　អស់ជិតបីលានដុល្លារយូអេស ។
ស្លស្លាន់លាយមាសចាក់ឆ្លាក់កំពូល　　មានរាងស្រួចមូលស័ក្តិសមអ្វីម្ល៉េះ
មាសច្រើនគីឡូចាំងថ្ងៃភ្លឺថែស　　បុស្បុកវិសេសតម្កល់ព្រះធាតុ ។
ឆត្ររួតបុស្បុកសម្រុកចុងក្រោយ　　ក្បាច់ស្លាន់លាយដោយសាច់មាសសមមាឌ
ពុទ្ធបដិមាតាំងក្រោមព្រះធាតុ　　សុវណ្ណកោដ្ឋទៀតបរមធាតុលង្កា ។
សម្មាសម្ពុទ្ធស្ស ទេមៈ　　យើងខ្ញុំជឿជាក់ដោយចិត្តជ្រះថ្លា
ព្រះពុទ្ធបរមគ្រូនៃមនុស្សទេវតា　　ខ្ញុំសូមថ្វាយមហាប្រាសាទគន្ធកុដិ ។
នឹកព្រះគន្ធកុដិនាវត្តជេតពន　　ព្រៃមិគទាយវ៉នៃទន់ចិត្តលំអុត
លំឱនមនោសារនឹកគុណព្រះពុទ្ធ　　ថ្វាយមហាគន្ធកុដិនៅបាត់ដំបង ។
ថ្វាយទាំងទីដីដែលទើបទិញបាន　　ថ្វាយទាំងសន្តានម្ចាស់ទានសូមឆ្លង
នូវសព្វកិលេសឲ្យអស់សៅហ្មង　　ដល់និព្វានហោងបានឆ្លងភពបី ។
នឹកពុទ្ធគយាពោធិព្រឹក្សា　　ព្រះពុទ្ធមេត្តាតំណាងបារមី
សត្តមហាឋានមហាជោគជ័យ　　នឹកផ្ចិតផែនដីព្រះពុទ្ធប្រាំអង្គ ។
នឹកសុមនកូដព្រះបាទទ្រង់ជាន់　　នឹកដល់ព្រះទន្តទាឋធាតុនៃទ្រង់
ចេតិយត្រៃត្រិង្សទង់ទិព្វរហង់　　ទើបខ្ញុំផ្ចិតផ្ចង់សាងមហាប្រាសាទ ។
ដោយបុណ្យជ្រះថ្លាមហាចេតិយ　　ព្រះរតនត្រៃរូបផ្ទៃព្រះបាទ
មង្គលចក្កវាឡបណ្តាលចិត្តស្អាត　　បុណ្យសាងប្រាសាទសន្តិភាពគ្រប់គ្នា ៕

ដោយ **ម.ស.វ.**



# វត្តគិរីរម្យចាស់

រុក្ខជាតិលូតលាស់ផ្តល់សម្រស់ល្អ ក្រែមម្ស្បៅផាត់ពណ៌លម្អភក្ត្រា
ធ្វើបុណ្យដាក់បាត្រសម្អាតចិន្តា ខិតខំសិក្សាប្រាជ្ញាខ្ពង់ខ្ពស់ ។
អារាមផ្ទូរផង់ព្រះសង្ឃថ្លៃថ្លា គណៈកម្មការរក្សាកេរ្តិ៍ឈ្មោះ
មានប្រជាប្រិយសម្តីពីរោះ ខន្តីខ្ពង់ខ្ពស់ព្រោះមានអំណត់ ។
គិតគូរស្រុះស្រួលសម្រួលចិត្តគ្នា ខិតខំពុះពារការងារហ្មត់ចត់
គិរីរម្យចាស់ផ្លាស់ព្រះនាមវត្ត ឈ្មោះថ្មីប្រាកដជាវត្តមហាវ័ន ។
កុដិរៀបជាជួរគួរឱ្យមនោរម្យ សង់តាមជើងភ្នំជាជុំតាមជាន់
ទឹកចិត្តម្ចាស់ទានពុំមានអាក់អន់ បានកសាងទាន់ជំនាន់កុដិថ្មី ។
ពេលមានទុក្ខសោកមកគិរីរម្យ ព្ញសូរវៃយំបន្ទុំស្មារតី
ថ្វាយបង្គំព្រះគោតមចេតិយ ទទួលពរជ័យព្រះសង្ឃអប់រំ ។
វត្តមហាវ័ន័គយគន់ចាំញាតិ ក្នុងឧទ្យានជាតិភ្នំគិរីរម្យ
ក្នុងស្រុកភ្នំស្រួចសំបូរដោយភ្នំ កំពង់ស្ពឺម្តុំក្នុងឃុំចំបក់ ។
ដើមស្រល់តូចធំដុះជុំអមផ្លូវ ស្លឹកស្រល់មើលទៅដូចសរសៃសក់
ទឹកជ្រោះធំតូចថ្លាដូចកញ្ចក់ ស្រល់ត្រូវខ្យល់បក់ដូចសក់សាយទៅ ។
ឯអាកាសធាតុខួបប្រាំងវស្សា ពុំមានពេលណាថាជាខែក្តៅ

ត្រជាក់រហូតរៀងរាល់រដូវ          អគ្រាត្រយប់ជ្រៅត្រជាក់ស្លឹកដៃ ។
ព្រះសង្ឃច្រើនអង្គគង់ចាំវស្សា          បានឃើញពេលណាជ្រះថ្លាពេកក្រៃ
ល្បីល្បាញសាសនាដោយសារស្នាដៃ          សង្ឃមានវិន័យគណៈកម្មការល្អ ។
ព្រះសង្ឃជាគ្រូគិតគូរមេរៀន          វិន័យដែលមានបង្រៀនបន្ត
មានថ្នាក់មធ្យមឧត្តមបវរ          វិន័យមាំល្អទ្រព្រះសាសនា ។
សូមបុណ្យដែលបានរួមគ្នាកសាង          មានជាភ័ស្តុតាងគឺកុដិសាលា
សូមបានសម្រេចដូចក្តីប្រាថ្នា          កើតជាតិណា ៗ បានសុខសិរី ។
សូមប្រគេនបុណ្យព្រះសង្ឃគ្រប់អង្គ          ដែលខំផ្ចិតផ្ចង់អស់ពីហឫទ័យ
រក្សាអារាមតាមធម៌វិន័យ          សូមបានជោគជ័យគ្រប់អង្គទាំងអស់ ។

ដោយឧបាសក **គុយ សុធន**

# ពាក្យពិតមិនស្លាប់

សំឡេងស្រែកច្រៀងសំនៀងពីរោះ          ពេលមានជម្លោះស្រែកជេររហ៊ុម
ពេលមានជំងឺឈឺចាប់ស្រែកយំ          ពេលរងទុក្ខធំស្រែកសុំជំនួយ ។
អ្នករងរបួសរស់ស្រែកចុកចាប់          ចំណែកអ្នកស្លាប់ឥតស្រែករំអួយ
គួរគិតឱ្យឆ្ងាយរូបកាយតែមួយ          ជីវិតផុយស្រួយថ្ងៃមួយមរណា ។

គ្រប់គ្រងមិនបានស្ទានក៏មិនត្រូវ　　អំពើឃោរឃៅនៅមានខ្លាំងក្លា
ឃើញជួញថ្នាំញៀនក៏ពុំហ៊ានថា　　សរសើរសុរាថាគ្រឿងមនោរម្យ ។
អ្នកមានខ្វាយខ្វល់ឥតយល់អ្នកក្រ　　អ្នកធំឥតធម៌រីកវរសង្គម
ឥតធម៌មេត្តាខ្វះការអប់រំ　　កើតជាគំនុំគុំកួននឹងគ្នា ។
ពេលនេះពាក្យពិតប្រែឥតខ្លឹមសារ　　ពាក្យអ្នកខ្លាំងថាមានខ្លាការពារ
អ្នកខ្លាំងនិងខ្លាមរណាដូចគ្នា　　ពាក្យពិតគ្រប់គ្រាជាពាក្យមិនស្លាប់ ។

ដោយឧបាសក **គុយ សុធន**

# នេះគឺការពិត

កម្លាំងទឹកហូរលាន់សូរសំឡេង　　ពាក្យពោលផ្សេងៗរមែងផ្សាយទៅ
ពាក្យសរសើរជិតពិតស៊ីជម្រៅ　　ឆ្ងាយពីមុខទៅនៅតែកំហុស ។
អ្នកក្រោមត្រូវអស់ទាស់ចិត្តអ្នកលើ　　បើអ្នកធំធ្វើគិតមើលទៅចុះ
នៅនាលោកីយ៍មានអ្វីមិនខុស　　សីលធម៌ធ្លាក់ចុះមានអ្វីត្រូវគ្នា ។
គួរតែស្រុះស្រួលទទួលការពិត　　អ្នកមានជីវិតសុទ្ធតែគ្រាំគ្រា
ទាំងយើងទាំងគេគ្មានទេអ្នកជា　　ពាក្យមិននិន្ទាគ្មានទេក្នុងលោក ។

ដោយឧបាសក **គុយ សុធន**

# នាមពុទ្ធបរិស័ទអ្នកមានឧបការៈ
# ក្នុងការទារធម្មទាន

១. លោកគ្រូ រស់ សូផាត
២. ឧបាសក យន្ត សួន
៣. ឧបាសក គួង លាងផេង
៤. ឧបាសក មួង យេន
៥. ឧបាសក សោម រតនៈ
៦. ឧបាសក អ៊ិត ប្រាំង
៧. ឧបាសិកា ជា សុណារី
៨. ឧបាសិកា ប៊ុត ម៉ាលី
៩. ឧបាសក គុយ សុធន
១០. ឧបាសក វ៉ាន់ ខុនណា
១១. ឧបាសក ជឹម ជំនិត
១២. ឧបាសក ជឹង វ៉េងអ៊ាវ
១៣. ឧបាសក ង៉ូវ គា
១៤. ឧបាសក ហាយ ចំរើន
១៥. ឧបាសក ច័ន្ទ សុខុម
១៦. ឧបាសក អ៊ឹម រ៉ៃយ៉ា
១៧. ឧបាសក ម៉ៅ ម៉ន
១៨. ឧបាសក ម៉ៅ ផុន
១៩. ឧបាសិកា ហួនចាន់បូផា
២០. ឧបាសិកា ហាយច័ន្ទធរី
២១. ឧបាសក គឹម សោភ័ណ
២២. ឧបាសក ហង់ វណ្ណៈ

## សព្វទានំ ធម្មទានំ ជិនាតិ

ធម្មទានឈ្នះអស់ទានទាំងពួង ។

# រាយនាមពុទ្ធបរិស័ទក្នុងសហគមន៍ធម្មទាន
# ឧបត្ថម្ភប្រាក់ផ្សព្វផ្សាយព្រះធម៌ប្រចាំឆ្នាំ

| | | |
|---|---|---|
| ១- | លោក កេត សេរីភ័ក្រ្ត និង អ្នកស្រី ប៉ុល ហគ្គា +បុត្រ ..... | ស.រ.អ. |
| ២- | ឧ.សិ.កេតុ ថូរ និង ឧ.សិ.ស្វាយ សិត ព្រមទាំងបុត្រធីតា ... | ស.រ.អ. |
| ៣- | ឧ.ស.កៅ សេក និង ឧ.សិ.យី សាគុណ ព្រមទាំងបុត្រ+ចៅ | ស.រ.អ. |
| ៤- | ឧ.សិ.គង់ ជាសត្ថា និង ស្វាមី ព្រមទាំងបុត្រ .................. | ស.រ.អ. |
| ៥- | ឧ.សិ.គុជ ឡាំងអេង និង អ្នកស្រី សេង យុវធា + កូនចៅ .. | ស.រ.អ. |
| ៦- | ឧ.ស.គៀង សេរីគង់ និង ឧ.សិ.តាន់ រ៉ានី ព្រមទាំងកូនចៅ . | ស.រ.អ. |
| ៧- | ឧ.សិ.ង៉ែត លេន ព្រមទាំងបុត្រ និងចៅ ...................... | ស.រ.អ. |
| ៨- | ឧ.សិ.ចាន់ នារីសុខ និងក្រុមគ្រួសារ ........................... | ស.រ.អ. |
| ៩- | ឧ.ស.ចាន់ ម៉ល់ និង ឧ.សិ.ជា សុផា ................................. | ស.រ.អ. |
| ១០- | ឧ.សិ.ឆាន់ ហៃគីង ព្រមទាំងបុត្រ និង ចៅ .................... | ស.រ.អ. |
| ១១- | ឧ.ស.ឆាយ អ៊ីវស៊ាង និង ឧ.សិ.ហុង គីមសៃ + បុត្រ ......... | ស.រ.អ. |
| ១២- | ភិក្ខុ ឆុំសារឿន+ភិក្ខុឈួមសម្បូរ+ពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ | ស.រ.អ. |
| ១៣- | ឧ.ស.ជា ស៊ុវត្ថានា និង ឧ.សិ.យុន សូនីម៉ា ព្រមទាំងបុត្រ .. | ស.រ.អ. |
| ១៤- | ឧ.ស.ជិម អេងស្រ៊ន និង ភរិយា ព្រមទាំងបុត្រ +ចៅ ..... | ស.រ.អ. |
| ១៥- | ឧ.សិ.ជុំ ឆដា ( ហៅ លាភ )...................................... | ស.រ.អ. |
| ១៦- | ឧ.សិ.ឈ គីមហោ ព្រមទាំងបុត្រ និងចៅ .................... | ស.រ.អ. |
| ១៧- | ឧ.ស.ឈូ គីមសួ និង ឧ.សិ.ឌឿ សុភា ព្រមទាំងបុត្រ ......... | ស.រ.អ. |
| ១៨- | ឧ.ស.ឈួន ផារិន និង ឧ.សិ.ព្រំ ប្រណីត ...................... | ស.រ.អ. |
| ១៩- | ឧ.សិ.តាន់ ភិចជូ ព្រមទាំងបុត្រធីតា និងចៅៗ ............. | ស.រ.អ. |

២០- ឧ.ស.តាន់ តារាវង្ស និង ឧ.សិ.ជួប វុឌ្ឍី ព្រមទាំងកូនចៅ ... ស.រ.អ.

២១- ឧ.សិ.តូច ចាន់យ៉ា .................................................... ស.រ.អ.

២២- ឧ.សិ.តាំង លេខគៀវ ( ហៅ តាំងហ៊ាង ) ព្រមទាំងកូនចៅ . ស.រ.អ.

២៣- ឧ.ស.តែ ប៊ុនគង់ និង ឧ.សិ.ថោង បូនី ព្រមទាំងបុត្រ+ចៅ ស.រ.អ.

២៤- ឧ.ស.តាំ អាង និង ឧ.សិ.កូយ ឡាំហួង ព្រមទាំងបុត្រ ........ ស.រ.អ.

២៥- ឧ.សិ.ទីន ឈីវ ព្រមទាំងបុត្រ និងចៅ ......................... ស.រ.អ.

២៦- លោកយាយ ទឹម រ៉ុ .................................................... ស.រ.អ.

២៧- ឧ.សិ.ទី គីមជឹង ព្រមទាំងកូនចៅ ................................... ស.រ.អ.

២៨- ឧ.សិ.ទូច ផានី និង ស្វាមី Leslie Mael ព្រមទាំងបុត្រ . ស.រ.អ.

២៩- ឧ.សិ.ប៉ាន សារិទ្ធ ហៅង៉ា ព្រមទាំងកូនចៅ ................... ស.រ.អ.

៣០- ឧ.សិ.ប៊ិត ចងខាំ និង ឧ.សិ.សាន ផល្លីនព្រមទាំងបុត្រ+ចៅ. ស.រ.អ.

៣១- ឧ.ស.ប៊ូ ហោនាង និង ឧ.សិ.អ៊ឹងវិទ្ធារី ព្រមទាំងបុត្រ ...... ស.រ.អ.

៣២- លោក ពេជ្រ សីហា និង អ្នកស្រី ថាប់ សុរត្ន័ ................ ស.រ.អ.

៣៣- ឧ.ស.ភឿក វ៉ាន និង ឧ.សិ.ហ៊ូ អាត់ ព្រមទាំងកូនចៅ ...... ស.រ.អ.

៣៤- ឧ.ស.ម៉ែ គួលអេង និង ឧ.សិ.រស់ កល្យាណ ................... ស.រ.អ.

៣៥- ឧ.ស.យូស៊ាង ងួនលី និង ឧ.សិ. លីម ឃីម + បុត្រ .......... ស.រ.អ.

៣៦- ឧ.សិ.រស់ លីណា និង ឧ.សិ.នឹម វណ្ណី ព្រមទាំងកូនចៅ .... ស.រ.អ.

៣៧- ឧ.ស.លី ឌីន និង ឧ.សិ.ថាច់ លីហ៊ន ................................ ស.រ.អ.

៣៨- ឧ.សិ.លី ប៉ូលីនស៊ីមប៉ូ .............................................. ស.រ.អ.

៣៩- ឧ.ស.វង់ ម៉ៅ និង ឧ.សិ.ឆាន់ កាន់ជួង ព្រមទាំងបុត្រ+ចៅ . ស.រ.អ.

៤០- ឧ.សិ.ស៊ីវ យក់លុយ ព្រមទាំងបុត្រ និងចៅ .................. ស.រ.អ.

៤១- ឧ.ស.ស៊ុន ដារិន និង ឧ.សិ.ទូច ចន្ទី ព្រមទាំងបុត្រ .......... ស.រ.អ.

៤២- ឧ.សិ.សេក ឆវី និងម្តាយ យន់ ល្បៀងស៊ីប ព្រមទាំងកូនចៅ ... ស.រ.អ.

| | | |
|---|---|---|
| ៤៣- | ឧ.ស.សៅ ហ៊ាន និង ឧ.សិ.មាស ម៉ូនីកា ព្រមទាំងបុត្រ ... | ស.រ.អ. |
| ៤៤- | ឧ.ស.សំណាង យឹម និង ឧ.សិ.ឡូរ៉ា យឹម ព្រមទាំងបុត្រ ... | ស.រ.អ. |
| ៤៥- | ឧ.សិ.ស្រង់ អែ និង ឧ.សិ.ស្រង់ ឡេង ព្រមទាំងបុត្រ+ចៅ | ស.រ.អ. |
| ៤៦- | ឧ.ស.ហាក់ ច័ន្ទសុផល និង ឧ.សិ.វ៉ាង ស៊ីណា ព្រមទាំងបុត្រ | ស.រ.អ. |
| ៤៧- | ឧ.សិ.ហេង លាភ ព្រមទាំងបុត្រ និង ចៅ ...................... | ស.រ.អ. |
| ៤៨- | ឧ.ស.ហោ លាន និង ឧ.សិ.ឆឹង អូន .............................. | ស.រ.អ. |
| ៤៩- | ឧ.ស.ឡឹម ក្រហម និង ឧ.សិ.តាំង ធីយន ព្រមទាំងបុត្រ ... | ស.រ.អ. |
| ៥០- | ឧ.សិ.ឡុង អ៊ុម ព្រមទាំងបុត្រ និងចៅ ....................... | ស.រ.អ. |
| ៥១- | ឧ.ស.ឡេង កុយ និង ឧ.សិ.ឈឹម សេន ........................ | ស.រ.អ. |
| ៥២- | ឧ.សិ.ឡាំង គីមឆេង ព្រមទាំងបុត្រ ........................... | ស.រ.អ. |
| ៥៣- | ឧ.ស.អ៊ាបហៃសាន+ឧ.សិ.ឡឹកពេញចិត្ត+ឧ.ស.ឡឹកច័ន្ទដេត | ស.រ.អ. |
| ៥៤- | ឧ.សិ.អ៊ឹង ស៊ីវន ព្រមទាំងបុត្រ និងចៅ ........................ | ស.រ.អ. |
| ៥៥- | ឧ.ស.អ៊ុក សាមឿន និង ឧ.សិ.វួច អ៊ុម ព្រមទាំងកូនចៅ .. | ស.រ.អ. |
| ៥៦- | ឧ.ស.អ៊ុន ផៃត្រី និង ភរិយា ព្រមទាំងបុត្រ .................. | ស.រ.អ. |
| ៥៧- | ឧ.សិ.អូន ញ៉ូ ........................................................... | ស.រ.អ. |
| ៥៨- | លោកគ្រូធម្មបណ្ឌិត អឿ សៅ .................................. | ស.រ.អ. |
| ៥៩- | ឧ.ស.អៀង ឆាយ និង ឧ.សិ. អៀ កេសរ ព្រមទាំងបុត្រ . | ស.រ.អ. |
| ៦០- | ឧ.សិ.អ៊ុំ ស៊ុននី និង កូនចៅ ...................................... | ស.រ.អ. |
| ៦១- | ឧ.សិ.កែវ សុខលាភ ព្រមទាំងបុត្រ .............................. | អូស្ត្រាលី |
| ៦២- | កញ្ញា ខុម គាដារ៉ា ( ហៅ ស្រីណៃ ) .............................. | អូស្ត្រាលី |
| ៦៣- | ឧ.ស.ខុម ចាន់ឌីណា .................................................. | អូស្ត្រាលី |
| ៦៤- | ឧ.ស.ខុម ពុធដានី និង ឧ.សិ.គាប ពុទ្ធាវី ................... | អូស្ត្រាលី |
| ៦៥- | ឧ.ស.ង៉ូវ ឈីវ និង ឧ.សិ.ហេង ពាស៊ីម ព្រមទាំងបុត្រ+ចៅ | អូស្ត្រាលី |

៦៦- ឧ.សិ.ឆេង លុន ព្រមទាំងបុត្រ និងចៅ ........................ អូស្ត្រាលី
៦៧- ឧ.សិ.ជូ រ៉េន .......................................................... អូស្ត្រាលី
៦៨- ឧ.សិ.ឈ គីមស៊ីន និង ក្រុមគ្រួសារកូនចៅ ................... អូស្ត្រាលី
៦៩- ឧ.ស.ឈិត ទ្រី និង ឧ.សិ.បាន់ ណៃហ៊ាង ព្រមទាំងបុត្រ.... អូស្ត្រាលី
៧០- លោក ញាន ហេងម៉ូវ និង អ្នកស្រី ស៊ា ចន្ថា ព្រមទាំងបុត្រ អូស្ត្រាលី
៧១- ឧ.ស.ដែន គង់ហួត និង ឧ.សិ.កាំង គីមស៊ុន ព្រមទាំងបុត្រ អូស្ត្រាលី
៧២- ឧ.ស.ឌុច ផ្លែក និង ឧ.សិ.ហ៊ុន ណូក ............................. អូស្ត្រាលី
៧៣- ឧ.ស.តូ សាវើន និង ឧ.សិ.មាន សុវត្ថិ ព្រមទាំងបុត្រ ........ អូស្ត្រាលី
៧៤- ឧ.សិ.តាំង ស៊ីឃន ...................................................... អូស្ត្រាលី
៧៥- ឧ.ស.ទា សុង និង ឧ.សិ.ង៉ោ ចាន់ខេង ព្រមទាំងកូនចៅ .. អូស្ត្រាលី
៧៦- ឧ.សិ.បាក់ លីឡេងហ៊ាង ព្រមទាំងកូនចៅ ...................... អូស្ត្រាលី
៧៧- ឧ.ស.ប៊ុន ហេង និង ឧ.សិ.ជុំ សុខុម ព្រមទាំងបុត្រ .......... អូស្ត្រាលី
៧៨- ឧ.ស.ប៉ុច រឿត និង ឧ.សិ.ញូង ស៊ាងម៉េង ព្រមទាំងបុត្រ.. អូស្ត្រាលី
៧៩- លោកយាយ ប្រាក់ខាត់+ឧ.ស.ស៊ិន សាន+ឧ.សិ.សម្បត្តិ គង់ អូស្ត្រាលី
៨០- ឧ.សិ.ពុធ សុខង៉ោ+ឧ.សិ.លី វណ្ណា និង ឧ.ស.ខួយ ចេង ... អូស្ត្រាលី
៨១- ឧ.សិ.ម៉េង ប៊ុន្នារី (ហៅស្រីពៅ)និងស្វាមី ព្រមទាំងបុត្រ. អូស្ត្រាលី
៨២- ឧ.ស.យ៉ង់ សិន និង ឧ.សិ.នន់ ហេង ព្រមទាំងបុត្រ+ចៅ. អូស្ត្រាលី
៨៣- ឧ.សិ.យិន មួយឡាង និង ស្វាមី ព្រមទាំងបុត្រ ............... អូស្ត្រាលី
៨៤- លោក យឹម ឡេង និង អ្នកស្រី ប៉ុល និច្ចសីល +បុត្រ........ អូស្ត្រាលី
៨៥- ឧ.ស.រស់ សារ៉េន និង ឧ.សិ.គង់ សារឿង ព្រមទាំងបុត្រ . អូស្ត្រាលី
៨៦- ឧ.ស.រស់ ធារុន និង ឧ.សិ.ហេង សុមានធា .................... អូស្ត្រាលី
